ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ

# ករណីសិក្សា ៖ ខេត្តកណ្តាល

**Implementation of The State Pre-school Curriculum**

**Case Study: Kandal Province**


ដោយ/**By**

**សៀង គឹមឈឿន**

**SEANG KIMCHHOEUN**


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស ៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**


**ឧបត្ថម្ភដោយ ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by Cambodia International Education Support Foundation (CIESF)

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ

# ករណីសិក្សា ៖ ខេត្តកណ្ដាល

**Implementation of The State Pre-school Curriculum**

**Case Study: Kandal Province**


ដោយ/**By**

**សៀង គីមឈឿន**

**SEANG KIMCHHOEUN**


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស ៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**


**សាស្ត្រាចារ្យដឹកនាំ ៖ លោកបណ្ឌិត ស៊ីន សេងហុក**

**សាស្ត្រាចារ្យដឹកនាំរង ៖ លោក ឡេង បូរី**



**ឧបត្ថម្ភដោយ ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by Cambodia International Education Support Foundation (CIESF)

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៦២៩ **អយក.** [illegible]

**(ការសម្ងាត់)**

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វ៉ៃ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម ងៀ សុជន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារៈវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្ដីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ**"ករណីសិក្សាៈខេត្តកណ្ដាល សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានអប់រំ គឺជាស្នាដៃផ្ទាល់របស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់សញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយទេ។ គ្មានសេចក្ដីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវនេះពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

**សៀង គឹមឈឿន**

# លិខិតបញ្ជាក់

លោកបណ្ឌិត **ស៊ន សេងហុក** ជាសាស្ត្រាចារ្យដឹកនាំ

លោក **ឡេង មុរី** ជាសាស្ត្រាចារ្យដឹកនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **សៀង គីមឈឿន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ**" ករណីសិក្សា៖ ខេត្តកណ្ដាល ពិតប្រាកដមែន។

ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

……………………………………… ………………………………………

**លោកបណ្ឌិត ស៊ន សេងហុក**

ប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងអប់រំ យុវជន និងកីឡា

**លោក ឡេង មុរី**

ប្រធានការិយាល័យរដ្ឋបាលនៃវិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះលោកឪពុកអ្នកម្តាយ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងដល់រូបកូនឱ្យបានទទួលការសិក្សារហូតរូបកូនមានថ្ងៃនេះ និងសូមថ្លែងអំណរគុណយ៉ាងច្រើនបំផុតដល់ភរិយាជាទីស្រឡាញ់របស់ខ្ញុំ និងកូនភ្លោះទាំងពីរ ដែលតែងតែផ្តល់កម្លាំងចិត្ត ទំនុកបំរុងទាំងសម្ភារៈ និងថវិកាដល់រូបខ្ញុំ ដើម្បីមានលទ្ធភាពក្នុងការបន្តការសិក្សារហូតពេលនេះ។

សូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ និងមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា Cambodia International Education Support Foundation (CIESF) ដែលបានរៀបចំ ក៏ដូចជាផ្តល់ឱកាសដល់រូបខ្ញុំ ឱ្យបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំ នាពេលកន្លងមក។

ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះគណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុត មកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា។ ជាពិសេសខ្ញុំបាទសូមគោរពថ្លែងអំណរគុណជូនចំពោះលោកបណ្ឌិត **ស៊ន សេខហុក** សាស្ត្រាចារ្យដឹកនាំសរសេរនិក្ខេបបទ ដែលតែងតែចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីជួយពន្យល់ណែនាំ បង្ហាញផ្លូវ ធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំទទួលបានជោគជ័យ និងបញ្ចប់ប្រកបដោយភាពរលូន។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់លោក **ឡេខ មុំរី** សាស្ត្រាចារ្យដឹកនាំរង ដែលតែងតែផ្តល់នូវកម្លាំងចិត្ត ចំណេះដឹង ចែករំលែកបទពិសោធដល់រូបខ្ញុំ ព្រមទាំងមិត្តរួមថ្នាក់ជំនាន់ទី៦ និងមិត្តរួមការងារដែលតែងតែផ្តល់នូវកម្លាំងចិត្ត ធ្វើឱ្យរូបខ្ញុំទទួលបានជោគជ័យនាថ្ងៃនេះ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្តាល ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក ទាំងប្រាំពីរ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ មាតាបិតាកុមារ និងកុមារនៅតាមសាលាគោលដៅទាំងអស់ដែលបានអនុញ្ញាត និងចូលរួមសហការ ធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក/លោកស្រីសាស្ត្រាចារ្យ លោក លោកស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់ សូមទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មូលន័យសង្ខេប


ក្រសួងអប់រំ យុវជន និងកីឡា ជាក្រសួងអាទិភាពក្នុងការកសាងធនធានមនុស្សដើម្បីរួមចំណែកអភិវឌ្ឍប្រទេសជាតិ។ ក្រសួងក៏បានដាក់ចេញនូវគោលនយោបាយជាយុទ្ធសាស្ត្រ វិស័យអាទិភាព និងកំណែទម្រង់ជាច្រើនចំណុច សំដៅលើកកម្ពស់និងពង្រឹងគុណភាពអប់រំក្នុងសតវត្សថ្មី ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍនៃសកលលោក។ ក្នុងនោះដែរ កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល គឺជាចំណុចអាទិភាពមួយដែលក្រសួងបានដាក់ចេញ។ យ៉ាងណាមិញការអនុវត្តកម្មវិធីសិក្សាក៏ឃើញថានៅមានចំណុចខ្វះខាត មិនទាន់បានល្អពេញលេញនៅឡើយទេ ជាពិសេសបញ្ហាប្រឈមនានា ដែលបានរាំងស្ទះដល់ការអនុវត្តកម្មវិធីសិក្សា។ ចំពោះការសិក្សាស្រាវជ្រាវទៅលើប្រធានបទ **«ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ»** ក្នុងខេត្តកណ្ដាលនេះ ធ្វើឡើងក្នុងគោលបំណង ស្វែងយល់អំពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តកម្មវិធីសិក្សា សារៈសំខាន់នៃកម្មវិធីសិក្សា ទស្សនៈរបស់នាយក/នាយិកា គ្រូបង្រៀន និងមាតាបិតាកុមារ ព្រមទាំងសិក្សាអំពីបញ្ហាប្រឈមនានា ដែលត្រូវបំពេញបន្ថែមផងដែរ។ ការស្រាវជ្រាវនេះ ត្រូវបានរៀបចំឡើងដោយប្រើទិន្នន័យបរិមាណវិស័យ និងគុណវិស័យ ក្នុងនោះរួមមាន ៧ក្រុង/ស្រុក ត្រូវជា ១៩ សាលា។ ភាគសំណាកដែលជាក្រុមគោលដៅ គឺសម្ភាសន៍នាយក/នាយិកាសាលា ចំនួន ១៩នាក់ គ្រូមត្តេយ្យសិក្សាចំនួន ៣៧នាក់ មាតាបិតាកុមារចំនួន ២០នាក់ និងធ្វើតេស្តកុមារចំនួន ៣០៣នាក់ សរុបចំនួន ៣៧៩នាក់។ ចំពោះភាគសំណាកកុមារត្រូវបានជ្រើសរើសតាមកម្មវិធី (www.openepi.com) ដោយមានការបង្ហាញពីកម្រិតនៃភាពជឿជាក់រហូតទៅដល់ ៩៥%។

តាមរយៈការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ការអនុវត្តកម្មវិធីសិក្សាតាមសាលាគោលដៅនៅមានភាពខ្វះចន្លោះមួយចំនួន ទោះបីជាមានការប៉ប៉ុនសមត្ថភាពមួយលើករួចហើយក្តី។ បើយើងក្រឡេកមើលទៅលើការអនុវត្តរបស់គ្រូមត្តេយ្យសិក្សានៅតាមសាលារៀនវិញ ឃើញថាការអនុវត្តកម្មវិធីសិក្សារបស់គ្រូនៅមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយទេ ក្នុងនោះរួមមាន ខ្លឹមសារមេរៀននិងរបាយម៉ោងសិក្សា ការរៀបចំសម្ភារឧបទេស និងការអនុវត្តរបស់គ្រូមត្តេយ្យសិក្សា។ ចំពោះខ្លឹមសារមេរៀន គ្រូមត្តេយ្យសិក្សានៅមិនទាន់មានការយល់ដឹងបានច្បាស់លាស់ពីការប្រើប្រាស់សៀវភៅកម្មវិធីសិក្សានៅឡើយទេ។ គ្រូមត្តេយ្យសិក្សាយល់ច្បាស់ពីខ្លឹមសារមេរៀន ២៤%ប៉ុណ្ណោះ ហើយនៅមិនទាន់យល់ច្បាស់ ៧៦%។ ខ្លឹមសារនៃលទ្ធផលរំពឹងទុកមួយចំនួនតាមមុខវិជ្ជានីមួយៗ និងតាមប្រធានបទមួយចំនួន ពិបាករកចំណងជើងមេរៀន ឬខ្លឹមសារមិនសមស្រប ឬខ្លឹមសារស្មួនគ្នា ឬពិបាកក្នុងការរកសម្ភារៈមកបង្រៀន។ ខ្លឹមសារលទ្ធផលរំពឹងទុកមុខវិជ្ជាចិត្តចលភាព នៅមានភាពមិនទាន់សមស្រប ១៣%។ ចំណែករបាយម៉ោងសិក្សាក៏នៅមានបញ្ហាមួយចំនួនតូច ដែលមិនទាន់មានភាពសមស្របលើមុខវិជ្ជាចិត្តចលភាព ២៧% និងមុខវិជ្ជាសិក្សាសង្គម ២៧%។ ការរៀបចំសម្ភារឧបទេសរបស់គ្រូមត្តេយ្យសិក្សានៅមានកម្រិតនៅឡើយ គឺមិនទាន់ឆ្លើយតបគ្រប់មេរៀនទាំងអស់ ក្នុងនោះគ្រូមត្តេយ្យសិក្សាមានសម្ភារឧបទេសក្នុងការបង្រៀនគ្រប់គ្រាន់ ៤៣% មានខ្លះៗ ៥៤% និងមិនមានសម្ភារឧបទេស ៣%។ បើពិនិត្យទៅលើកិច្ចតែងការបង្រៀនឃើញថា គ្រូមត្តេយ្យសិក្សាមានកិច្ចតែងការបង្រៀនគ្រប់មុខវិជ្ជា ១៩% មានកិច្ចតែងការបង្រៀនភាគច្រើន ១១% មានកិច្ចតែងការបង្រៀនខ្លះៗ ៧០%។ ការអនុវត្តការងាររបស់គ្រូក៏នៅមានចំណុចខ្វះខាតមួយចំនួន លើការរៀបចំបំណែងចែកកម្មវិធីសិក្សាលម្អិត និងផែនការបង្រៀនប្រចាំថ្ងៃ ចន្លោះពី ៥% ទៅ ៣០% មិនទាន់ឆ្លើយតបទៅនឹងកម្មវិធី

សិក្សាថ្មី។ ប៉ុន្តែចំណុចដែលគួរឱ្យចាប់អារម្មណ៍នោះ គឺលទ្ធផលនៃការធ្វើតេស្តកុមារអាយុ៥ឆ្នាំបានល្អ។ ប្រសិនបើគ្រូមត្តេយ្យសិក្សាអនុវត្តកម្មវិធីសិក្សាបានល្អប្រសើរជាងនេះ លទ្ធផលនៃការសិក្សារបស់កុមារក៏កាន់តែមានកម្រិតខ្ពស់។ នាយក/នាយិកាសាលា ក៏បានបង្ហាញពីភាពងាយស្រួលក្នុងការអនុវត្តកម្មវិធីសិក្សាដោយផ្អែកលើក្របខណ្ឌកម្មវិធីសិក្សា គឺអភិវឌ្ឍផ្នែកកាយសម្បទា បំណិនសម្បទា និងចរិយាសម្បទា ជាពិសេសមានលទ្ធផលរំពឹងទុករួចជាស្រេច។ ក្នុងនោះដែរ តាមរយៈមតិយោបល់របស់មាតាបិតាកុមារក៏បានបង្ហាញពីភាពរីកចម្រើនរបស់កូនៗ តាមរយៈលទ្ធផលសិក្សា និងការប្រែប្រួលឥរិយាបថនៅក្នុងសង្គម សម្រាប់ជាមូលដ្ឋានគ្រឹះរឹងមាំមុនចូលសាលាបឋមសិក្សា។ ទន្ទឹមនឹងនេះផងដែរ ក៏មានគ្រូមួយចំនួនតូចនៅមិនទាន់ផ្លាស់ប្តូរឥរិយាបថរបស់ខ្លួនក្នុងការបង្រៀន ដោយយល់ថាធ្វើឱ្យមានបន្ទុកការងារកាន់តែច្រើន ដែលនេះជាបញ្ហាមួយទាមទារឱ្យមានជួយជំរុញ ពិនិត្យតាមដាន និងពង្រឹងឆន្ទៈអ្នកអនុវត្តឡើងវិញ។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ យើងអាចសន្និដ្ឋានជារួមបានថា ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ នៅមិនទាន់មានភាពល្អប្រសើរនៅឡើយទេ។ ដូច្នេះស្នើសុំក្រសួងអប់រំ យុវជន និងកីឡា គួរពិនិត្យឡើងវិញ និងកែលម្អខ្លឹមសារលទ្ធផលរំពឹងទុកមួយចំនួនក្នុងកម្មវិធីសិក្សា ពង្រឹងសមត្ថភាពបន្ថែមដល់អ្នកទទួលបន្ទុកការងារអប់រំកុមារតូចគ្រប់លំដាប់ថ្នាក់ ជាពិសេសអ្នកអនុវត្តផ្ទាល់តាមរយៈការប្រជុំបច្ចេកទេស ឬសិក្ខាសាលា ឬវគ្គបំប៉នបច្ចេកទេសផ្សេងៗ ជំរុញឱ្យមានការរៀបចំសៀវភៅសិក្សាគោលទាំង៥ មុខវិជ្ជា (មុខវិជ្ជាចិត្តចលភាព វិទ្យាសាស្ត្រ សិក្សាសង្គម បុរេគណិត និងមុខវិជ្ជាភាសាខ្មែរ) និងសម្ភារឧបទេសសំបូរបែប ជំរុញឱ្យបង្កើនក្របខណ្ឌគ្រូមត្តេយ្យសិក្សានិងការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា (១២ បូក ៤) ការចុះពិនិត្យតាមដាននិងវាយតម្លៃតាមសាលារៀន ដើម្បីជួយតម្រង់ទិសអ្នកអនុវត្តផ្ទាល់នៅតាមមូលដ្ឋានក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា សម្រាប់មត្តេយ្យសិក្សារដ្ឋ ឆ្លើយតបទៅនឹងចក្ខុវិស័យកំណែទម្រង់គុណភាពអប់រំរបស់ក្រសួង។

# Abstract

The Ministry of Education, Youth and Sport is a priority ministry that is active in building human resources in order to contribute to the development of the country. The ministry has also introduced a range of strategic, priority and reform policies which aim at promoting and strengthening the quality of education in the new century in response to global evolutions. The reform of the curriculum and textbooks is a priority of the ministry. However, the implementation of the curriculum has not been fully realized yet, especially the challenges that have hindered the implementation of the state pre-school curriculum in state institutions. For the study on the topic of "**implementation of the state pre-school curriculum**" in Kandal Province, the purpose of the study is to understand the current status of the curriculum, the importance of the curriculum, the views of the directors, teachers, parents and children, as well as the study Challenges that also need to be supplemented. The research was conducted using quantitative and qualitative data, which included 19 schools in seven districts. The target sample consisted of interviewing 19 principals, 37 kindergarten teachers, 20 parents, and 303 children tested on a total of 379. For the sample, children were selected through the program (www.openepi.com) with a reliability rating of 95%.

Research has shown that the implementation of targeted school curriculums still has some shortcomings, despite the fact that it has already been trained. If we look back at the kindergarten teachers 'performance in school, the teachers' curriculum implementation is still not complete, including the content, lessons and time sheets, preparation of materials and the practice of preschool teachers. As for the contents of the lessons, preschool teachers still do not have a clear understanding of the use of textbooks. Pre-school teachers only know about 24% of the content and still do not understand 76%. The content of some of the expected results in each subject and some subjects may be difficult to find their titles or inappropriate contents, duplicate contents, or difficult to find materials to teach. The content of the expected outcome of the Mindfulness Subjects was as low as 13%. There are still some problems with the school schedule which did not fit in 27% of the mobility course and 27% of the social studies. Kindergarten teachers' preparation materials are still limited to all lessons, with 43% of kindergarten teachers having adequate teaching materials, some 54% and no 3%. If looking at lesson plans, 19% of all Kindergarten teachers have lesson plans of all subjects, 11% almost have lesson plans of subjects and 70% have a few of them. There is also a shortage of teachers in the implementation of the curriculum and the daily teaching plans of between 5% and 30% have not yet met the new curriculum. But the interesting thing is that the results of the 5-year-old's test were good. If the preschooler practices the program better, the child's performance will be higher. Lack of textbooks and teacher capacity are still the reasons why curriculum is still limited. Studies show that preschool teachers who receive detailed curriculum support support this work, as they feel it is important to support clear teaching. Principals also demonstrated how easy it is to implement a curriculum based on the framework of the curriculum: development, fitness, fitness, and fitness. In the opinion of parents, children also show their children's progress through learning outcomes and social behavior change for a solid foundation before entering primary school. At the same time, a number of teachers have yet to change their behavior in teaching, in the light of increasing workload.

As a result of the research, we can conclude that overall the implementation of the target kindergarten curriculum has not improved, and we have also identified some challenges that practical stakeholders encountered. Therefore, the Ministry of Education, Youth and Sport should review this curriculum and improve the textbook for future editions in order to improve the effectiveness of the curriculum for public kindergarten in state school in response to the Ministry's quality education reform vision.

# តារាងមាតិកា

សេចក្តីប្រកាសអះអាងរបស់បេក្ខជន....i
លិខិតបញ្ជាក់....ii
សេចក្តីថ្លែងអំណរគុណ....iii
មូលន័យសង្ខេប....iv
Abstract....vi
តារាងមាតិកា....vii
បញ្ជីចំណងជើងតារាង និងក្រាហ្វិក....xi
តារាង....xii
បញ្ជីពាក្យកាត់....xiii
**ជំពូកទី១**....- 1 -
**សេចក្តីផ្តើម**....- 1 -
១.១.សាវតារ....- 1 -
១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ....- 6 -
១៣..គោលបំណងនៃការសិក្សាស្រាវជ្រាវ....- 7 -
១៤..សំណួរស្រាវជ្រាវ....- 7 -
១៥..សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ....- 7 -
១.៦.ដែនកំណត់នៃការសិក្សាស្រាវជ្រាវ....- 8 -
១.៧.វិធីប្រមូលនិងការវិភាគទិន្នន័យ....- 8 -
១.៨.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ....- 9 -
**ជំពូកទី២**....- 10 -
**រំលឹកទ្រឹស្តី**....- 10 -
២១..និយមន័យ....- 10 -
២២..ទស្សនៈផ្សេងៗ ស្តីពីកម្មវិធីសិក្សា....- 10 -
២.២.១.និយមន័យកម្មវិធីសិក្សា....- 10 -
២.២.២.ទស្សនៈផ្សេង ៗនៃកម្មវិធីសិក្សា....- 10 -
២.២.៣.ភាពខ្លាំង និងភាពខ្សោយ នៃការរៀបចំកម្មវិធីសិក្សា....- 11 -

២.៣.ការរៀន និងគោលការណ៍សំខាន់ៗ ក្នុងការអភិវឌ្ឍកម្មវិធីសិក្សា - 12 -
២.៣.១.អត្ថប្រយោជន៍នៃចំណេះដឹងផ្នែកចិត្តសាស្ត្រ និងលំនាំនៃការរៀន - 12 -
២.៣.២.និយមន័យនៃការរៀន - 13 -
២.៣.៣.កត្តាដែលជះឥទ្ធិពលទៅដល់ការរៀន - 13 -
២.៣.៤.បច្ចេកទេសសំខាន់ៗ ក្នុងការរៀន - 14 -
២.៤.ការរៀនរបស់កុមារតូច - 15 -
២.៤.១.ការសង្កេត - 15 -
២.៤.២.ការត្រាប់តាម (មនុស្ស សត្វ រុក្ខជាតិ ធម្មជាតិ) - 16 -
២.៤.៣.ការស្រាវជ្រាវ ការរុករក ការពិសោធ - 16 -
២.៤.៤.ការលេង - 16 -
២.៤.៥.ការអនុវត្តផ្ទាល់ - 16 -
២.៥.គោលការណ៍សំខាន់ៗសម្រាប់អភិវឌ្ឍកម្មវិធីសិក្សា - 17 -
២.៦.ការរៀបចំកម្មវិធីសិក្សា - 17 -
២.៦.១.ចំណុចសំខាន់ៗ ក្នុងការរៀបចំកម្មវិធីសិក្សា - 17 -
២.៧.កម្មវិធីសិក្សាបណ្តាប្រទេសនានា - 20 -
២.៧.១.កម្មវិធីសិក្សាសាលាមត្តេយ្យសិក្សាព្រះរាជាណាចក្រថៃ - 20 -
២.៧.២.កម្មវិធីសិក្សាសាលាមត្តេយ្យសិក្សាប្រទេសជប៉ុន - 25 -
២.៨.ការអភិវឌ្ឍរបស់កុមារតូច - 27 -
២៨.១..ការអភិវឌ្ឍផ្នែករូបរាងកាយ និងសុខភាព - 28 -
២៨.២..ការអភិវឌ្ឍផ្នែកសីលធម៌ និងវប្បធម៌ - 28 -
២៨.៣..ការអភិវឌ្ឍផ្នែកសង្គម និងអារម្មណ៍ - 28 -
២៨.៤..ការអភិវឌ្ឍផ្នែកការយល់ដឹង និងការពិចារណា - 29 -
២៨.៥..ការអភិវឌ្ឍផ្នែកភាសា - 31 -
២.៩.កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ - 33 -
២៩..១.សារតារ - 33 -
២៩..២.គោលដៅរួមនៃការសិក្សា - 34 -
២៩..៣.គោលការណ៍គ្រឹះ - 35 -
២៩..៤.ការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សា - 36 -
២៩..៥.បំណែងចែកម៉ោងសិក្សា - 37 -

២៩..៦.ការណែនាំអនុវត្ត - 37 -
២៩..៧.តារាងលម្អិតលទ្ធផលសិក្សា - 38 -
២.១០.សសរស្តម្ភទាំងប្រាំនៃគុណភាពអប់រំ - 40 -
**ជំពូកទី៣** - 41 -
**វិធីសាស្ត្រស្រាវជ្រាវ** - 41 -
៣.១.ព័ត៌មានទូទៅពីគម្រោងស្រាវជ្រាវ - 41 -
៣.២.ទីកន្លែងសិក្សាស្រាវជ្រាវ - 41 -
៣.៣.ក្រុមគោលដៅ - 41 -
៣.៤.ទំហំសំណាក - 42 -
៣.៥.ឧបករណ៍ស្រាវជ្រាវ - 43 -
៣.៥.១.កម្រងសំណួរសម្រាប់នាយិកាសាលា - 44 -
៣.៥.២.កម្រងសំណួរសម្រាប់គ្រូបង្រៀន - 44 -
៣.៥.៣.កម្រងសំណួរសម្រាប់មាតាបិតា - 44 -
៣.៥.៤.កម្រងសំណួរតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ - 44 -
៣៦..វិធីសាស្ត្រប្រមូលទិន្នន័យ - 45 -
៣.៧.ដំណើរការក្នុងការប្រមូលទិន្នន័យ - 46 -
៣.៨.ការវិភាគទិន្នន័យ - 46 -
៣.៩.ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ - 47 -
**ជំពូកទី៤** - 48 -
**លទ្ធផលនិងការពិភាក្សា** - 48 -
៤.១.ស្ថានភាពសង្គមប្រជាសាស្ត្រ - 48 -
៤.១.១.កម្រិតវប្បធម៌ - 48 -
៤.១.២.កម្រិតវិជ្ជាជីវៈ - 49 -
៤២..ការអនុវត្តការងាររបស់បុគ្គលិកអប់រំ - 49 -
៤.២.១.បទពិសោធការងារ - 49 -
៤.២.២.ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ - 50 -
៤.២.៣.ការរៀបចំបំណែងចែកកម្មវិធីសិក្សាលម្អិត និងផែនការបង្រៀន - 51 -
៤.២.៤.របាយម៉ោងសិក្សា - 52 -
៤.២.៥.ខ្លឹមសារលទ្ធផលរំពឹងទុក - 53 -

៤.២.៦.វិធីសាស្ត្របង្រៀន ..................................................................................... - 54 -
៤.២.៧.គោលការណ៍គ្រឹះក្នុងការបង្រៀនកុមារ .................................................................. - 56 -
៤.២.៨.កិច្ចតែងការបង្រៀន ............................................................................................ - 57 -
៤.២.៩.សម្ភារឧបទេស.................................................................................................. - 58 -
៤.២.១០.ឯកសារសម្រាប់បង្រៀន និងរៀន.......................................................................... - 59 -
៤.២.១១.វង្វាយតម្លៃការសិក្សាកុមារ................................................................................. - 60 -
៤.២.១២.ការប្រើប្រាស់សៀវភៅកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា ...........................................- 61 -
៤.២.១៣.ការពិនិត្យតាមដាននិងវាយតម្លៃពីថ្នាក់ការិយាល័យអប់រំក្រុង/ស្រុក ............................ - 62 -
៤.២.១៤.ការសង្កេតថ្នាក់រៀនពីនាយក/នាយិកា/ប្រធានក្រុមបច្ចេកទេស .................................. - 62 -
៤.២.១៥.លទ្ធផលនៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ ........................................ - 63 -
៤៣..ការវិភាគទិន្នន័យលើកម្រងសំណួរបែបគុណវិស័យ..................................................... - 72 -
៤៣.១..ទស្សនៈមន្ត្រីអប់រំ និងមាតាបិតាសិស្សចំពោះការធ្វើអនុវត្តកម្មវិធីសិក្សា និងបញ្ហាប្រឈមនានា ........................................................................................................... - 72 -
**ជំពូកទី៥** ................................................................................................................. - 75 -
**សេចក្តីសន្និដ្ឋាន និងសំណូមពរ** .................................................................................... - 75 -
៥១..សន្និដ្ឋាន .......................................................................................................... - 75 -
៥.២.សំណូមពរ........................................................................................................... - 76 -
៥៣..សំណូមពរសម្រាប់ការសិក្សាបន្ត................................................................................ - 77 -
ឯកសារយោង.................................................................................................................. - 78 -
ឧបសម្ព័ន្ធទី ១ ៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ....................................- 81 -
ឧបសម្ព័ន្ធទី ២ ៖ ចំណារអនុញ្ញាតឱ្យនិស្សិត ចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅនៅក្នុងខេត្តកណ្តាល............................................................................................................... - 83 -
ឧបសម្ព័ន្ធទី ៣ ៖ កម្រងសំណួរ........................................................................................ - 86 -
កម្រងសំណួរសម្រាប់សម្ភាសគណៈគ្រប់គ្រងសាលា ........................................................... - 86 -
កម្រងសំណួរសម្រាប់មាតាបិតាកុមារ ........................................................................... - 88 -
កម្រងសំណួរសម្រាប់គ្រូបង្រៀន .................................................................................. - 90 -
ឧបករណ៍ធ្វើតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ............................................................. - 96 -
ឧបសម្ព័ន្ធទី ៤ ៖ គណៈកម្មការមេប្រយោគសម្រាប់ការពារនិក្ខេបបទ ....................................... - 105 -
ឧបសម្ព័ន្ធទី ៥ ៖ គណៈកម្មការការពារនិក្ខេបបទ...........................................................- 106 -

ឧបសម្ព័ន្ធទី ៦ ៖ គណៈកម្មការកណ្ដាលសម្រាប់ការពារនិក្ខេបបទ ............................................- 107 -

# បញ្ជីចំណងជើងតារាង និងក្រាហ្វិក


| ល.រ | ចំណងជើងក្រាហ្វិក | ទំព័រ |
|---|---|---|
| | ក្រាហ្វិក 1 ៖ កម្រិតវប្បធម៌គ្រូបង្រៀន | - 48 - |
| | ក្រាហ្វិក ៖ កម្រិតវិជ្ជាជីវៈគ្រូបង្រៀន 2 | - 49 - |
| | ក្រាហ្វិក ៖ រយៈពេលបម្រើការងារក្នុងវិស័យអប់រំ 3 | - 49 - |
| | ក្រាហ្វិក ៖ ការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ 4 | - 50 - |
| | ក្រាហ្វិក ៖ 5ការរៀបចំបំណែងចែកកម្មវិធីសិក្សាលម្អិត | - 51 - |
| | ក្រាហ្វិក ៖ របាយម៉ោងសិក្សាតាមមុខវិជ្ជាប្រចាំឆ្នាំ 6 | - 52 - |
| | ក្រាហ្វិក ៖ របាយម៉ោងសិក្សាតាមមុខវិជ្ជាប្រចាំសប្តាហ៍ 7 | - 53 - |
| | ក្រាហ្វិក ៖ អំពីវិធីសាស្ត្របង្រៀន 8 | - 54 - |
| | ក្រាហ្វិក 9៖ គោលការណ៍គ្រឹះទាំង១០ ក្នុងការបង្រៀននៅមត្តេយ្យសិក្សា | - 56 - |
| | ក្រាហ្វិក 10៖ ការរៀបចំកិច្ចតែងការបង្រៀន | - 57 - |
| | ក្រាហ្វិក ៖ សម្ភារឧបទេសសម្រាប់បង្រៀន 11 | - 58 - |
| | ក្រាហ្វិក 12៖ ឯកសារផ្សេងៗ ក្នុងការងារបង្រៀននិងរៀន | - 59 - |
| | ក្រាហ្វិក 13៖ វង្វាយតម្លៃការសិក្សារបស់កុមារ | - 60 - |
| | ក្រាហ្វិក 14 ៖ ការយល់ដឹងពីការប្រើប្រាស់សៀវភៅកម្មវិធីសិក្សាលម្អិត | - 61 - |
| | ក្រាហ្វិក 15៖ ការចុះពិនិត្យតាមដាននិងវាយតម្លៃពីថ្នាក់ការិយាល័យអប់រំក្រុង/ស្រុក | - 62 - |
| | ក្រាហ្វិក 16 ៖ ការសង្កេតថ្នាក់រៀនពីនាយក/នាយិកា/ប្រធានក្រុមបច្ចេកទេស | - 63 - |

# តារាង

តារាង ៖ 1 បញ្ជីកម្រងសំណួរទាំង២០សម្រាប់អនុវត្តតេស្តជាមួយកុមារអាយុ៥ឆ្នាំ........................ - 45 -
តារាង ៖ លទ្ធផលពណ៌នាពីបុរេតេស្តនិងតេស្តបញ្ចប់នៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ 2... - 63 -
តារាង ៖ លទ្ធផលប្រៀបធៀបពិន្ទុ 3Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ(T-Test)........ - 64 -
តារាង ៖ លទ្ធផលពណ៌នាពីបុរេតេស្តនិងតេស្តបញ្ចប់នៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ 4 សំណួរទី១)ការអភិវឌ្ឍផ្នែករាងកាយនិងសុខភាព វិស័យទី១ -៦( ........ - 64 -
តារាង ៖ លទ្ធផលប្រៀបធៀបពិន្ទុ 5Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ(T-Test) វិស័យទី១ ការអភិវឌ្ឍផ្នែករាងកាយនិងសុខភាពសំណួរទី១)-៦( ........ - 65 -
តារាង ៖ លទ្ធផលពណ៌នាពីបុរេតេស្ត និងតេស្តបញ្ចប់ នៃការអនុវត្តតេស្តវាស់សមត 6្ថភាពកុមារអាយុ៥ឆ្នាំ វិស័យទី២ ការអភិវឌ្ឍផ្នែកសីលធម៌ និងវប្បធម៌សំណួរទី៧)-៩( ........ - 66 -
តារាង ៖ លទ្ធផលប្រៀបធៀបពិន្ទុ 7Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ(T-Test) វិស័យទី២ ការអភិវឌ្ឍផ្នែកសីលធម៌និងវប្បធម៌សំណួរទី៧)-៩(........ - 66 -
តារាង ៖ លទ្ធផលពណ៌នាពីបុរេតេស្ត និងតេស្តបញ្ចប់ នៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ 8 សំណួរទី១០) ការអភិវឌ្ឍផ្នែកសង្គម និងអារម្មណ៍ វិស័យទី៣ -១១( ........ - 67 -
តារាង ៖ លទ្ធផលប្រៀបធៀបពិន្ទុ 9Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ(T-Test) វិស័យទី៣ ការអភិវឌ្ឍផ្នែកសង្គមនិងអារម្មណ៍ សំណួរទី១០)-១១(........ - 67 -
តារាង ៖ លទ្ធផលពណ៌នាពីបុរេតេស្ត និងតេស្តបញ្ចប់ នៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ 10 វិស័យទី៤ ៖ ការអភិវឌ្ឍផ្នែកការយល់ដឹងនិងការពិចារណា សំណួរទី១២)-១៦( ........ - 68 -
តារាង ៖ លទ្ធផលប្រៀបធៀបពិន្ទុ 11Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ(T-Test) វិស័យទី៤ ៖ ការអភិវឌ្ឍផ្នែកការយល់ដឹងនិងការពិចារណា សំណួរទី១២)-១៦(- 68 -
តារាង ៖ លទ្ធផលពណ៌នាពីបុរេតេស្ត និងតេស្តបញ្ចប់ នៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ 12 វិស័យទី៥ ៖ ការអភិវឌ្ឍផ្នែកភាសា សំណួរទី១៧)-២០(........ - 69 -
តារាង ៖ លទ្ធផលប្រៀបធៀបពិន្ទុ 13Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ(T-Test) វិស័យទី៥ ៖ ការអភិវឌ្ឍផ្នែកភាសា សំណួរទី១៧)-២០( ........ - 70 -
តារាង ៖ លទ្ធផលប្រៀបធៀបមធ្យមរវាងកុមារានិងកុមារី 14 ........ - 70 -
តារាង 15 ៖ ពណ៌នាលទ្ធផល Mean Different តាមស្រុកទាំង៥ ........ - 70 -
តារាង ៖ លទ្ធផលប្រៀបធៀប 16Mean Different ជារួម ........ - 71 -
តារាង ៖ លទ្ធផលប្រៀបធៀប 17Mean Different ពីស្រុកមួយទៅស្រុកផ្សេងៗទៀត........ - 71 -

# បញ្ជីពាក្យកាត់

| | | |
|---|---|---|
| គ.ជ.គ.ក | : | គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច |
| នា.អកត | : | នាយកដ្ឋានអប់រំកុមារតូច |
| ម.ត | : | មត្តេយ្យ |

# ជំពូកទី១
# សេចក្ដីផ្ដើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១.សាវតារ

ប្រទេសកម្ពុជាបានឆ្លងកាត់ជាច្រើនសម័យកាលកន្លងមកហើយ ដែលបានធ្វើឱ្យប្រជាជនបានស្គាល់យ៉ាងច្បាស់ពីស្ថានភាពក្នុងសង្គម ក៏ដូចជាបទពិសោធជាច្រើនរួមមាន ការអភិវឌ្ឍ ភាពល្បីល្បាញ ព្រមទាំងទុក្ខសោកផងដែរក្នុងគ្រាកន្លងមក។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ(ប៉ុលពត) ដែលដឹកនាំប្រទេសចាប់តាំងពីឆ្នាំ១៩៧៥-១៩៧៩ បានធ្វើឱ្យប្រទេសជាតិធ្លាក់ចូលយ៉ាងជ្រៅក្នុងស្ថានភាពដ៏លំបាក ការបំផ្លាញដ៏ខ្លាំងក្លាជាងគេបំផុតនោះគឺ សាស្ត្រាចារ្យ វេជ្ជបណ្ឌិត វិស្វករ ស្ថាបត្យករ គ្រូបង្រៀន គ្រូពេទ្យ បញ្ញវន្ត អ្នករាជការ សិស្ស និស្សិត អ្នកចេះដឹង ព្រះសង្ឃ ត្រូវបានសម្លាប់ និងធ្វើទុក្ខទោសយ៉ាងធ្ងន់ធ្ងរ។ បន្ទាប់ពីការដួលរលំនៃអង្គការចាត់តាំងខ្មែរក្រហម ប្រទេសកម្ពុជាបានងើបពីភ្នក់ភ្លើងសង្គ្រាមជាមួយនឹងបាតដៃទទេ ក្នុងនោះស្ថាប័នរដ្ឋមួយចំនួនត្រូវបានរៀបចំឱ្យមានឡើងវិញ ដើម្បីចូលរួមកសាងប្រទេស។ ប្រព័ន្ធអប់រំក៏ត្រូវបានរៀបចំផងដែរ ហើយដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងធនធានមនុស្សឱ្យទទួលបានចំណេះដឹង បន្ទាប់ពីត្រូវបានបំផ្លាញចោលរាបដល់ដីនៅក្នុងសម័យ ប៉ុល ពត។ ដោយសារមានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលរួមជាមួយដៃគូអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល បានធ្វើឱ្យប្រព័ន្ធអប់រំនៅកម្ពុជាមានភាពរីកចម្រើនឡើងវិញជាលំដាប់ ប៉ុន្តែក៏នៅតែមិនទាន់អាចប្រៀបធៀបជាមួយនឹងប្រព័ន្ធអប់រំរបស់ប្រទេសជិតខាងយើងបាននៅឡើយ។ ច្បាស់ណាស់ថាការអភិវឌ្ឍប្រទេសមួយនេះ មិនអាចពឹងផ្អែកទាំងស្រុងទៅលើធនធានធម្មជាតិដែលមានស្រាប់តែមួយមុខនោះទេ ចាំបាច់ត្រូវតែមានការចូលរួមពីធនធានមនុស្សផងដែរ។ រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការវិនិយោគវិស័យនេះ ដោយបានសហការយ៉ាងជិតស្និតជាមួយបណ្តាប្រទេសដៃគូអភិវឌ្ឍនានា និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ក្នុងគោលបំណងពង្រឹងគុណភាពអប់រំនៅកម្ពុជាឱ្យឈានឡើង សមស្របជាមួយនឹងបណ្តាប្រទេសនៅក្នុងតំបន់។ រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យក្នុងរយៈពេលវែងដើម្បីកសាង និងថែរក្សាសង្គមកម្ពុជាឱ្យមានសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍសង្គមប្រកបដោយចីរភាព។ ក្នុងនោះវិស័យអប់រំ គឺជាគន្លឹះដ៏សំខាន់ ក្នុងការកសាងនូវរាល់ហេដ្ឋារចនាសម្ព័ន្ធសង្គម និងមានគុណភាពពិតប្រាកដគឺ ការកសាងធនធានបញ្ញាពោរពេញដោយចំណេះដឹង ចំណេះធ្វើ និងឥរិយាបថល្អក្នុងសង្គម។ (គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុជនកម្ពុជា, ឆ្នាំ២០១១) ដើម្បីចូលរួមចំណែកទ្រទ្រង់ និងបង្កើននូវកំណើនសេដ្ឋកិច្ចជាតិ ក៏ដូចជាក្នុងគ្រួសារឱ្យមានលក្ខណៈល្អប្រសើរ និងប្រកួតប្រជែងទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។ ដើម្បីឆ្លើយតបទៅនឹងនិរន្តរភាពក្នុការកសាងធនធានមនុស្ស ចាំបាច់ត្រូវតែធ្វើការត្រួតពិនិត្យលើផ្នែកពាក់ព័ន្ធទាំងអស់ក្នុងវិស័យអប់រំទាំងមូលដែលមានដូចជា សមត្ថភាពគ្រូបង្រៀនប្រកបដោយគុណភាព ការបង្រៀនសមស្របទៅនឹងកម្មវិធីសិក្សា លទ្ធផលសិក្សារបស់សិស្ស ការត្រួតពិនិត្យ និងវង្វាយតម្លៃលើកិច្ចការបង្រៀន និងការគោរពតាមនូវក្របខ័ណ្ឌគតិយុត្តិផ្សេងៗ សំដៅសម្រេចឱ្យបាននូវគោលនយោបាយអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យអប់រំសិក្សាធិការ គឺជាវិស័យអាទិភាព ព្រមទាំងបានដាក់បញ្ចូលក្នុងមុំទី៤ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នីតិកាលទី៥។ ក្នុងនោះដែរក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវ

គោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកំណត់ចំណុចអាទិភាពផ្សេងៗ ដើម្បីកែលម្អ និងលើកកម្ពស់វិស័យអប់រំ ព្រមទាំងគុណភាពអប់រំនៅគ្រប់ភូមិសិក្សា។

ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ក្រសួងសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការបង្កើនការអប់រំសម្រាប់កុមារកម្ពុជាគ្រប់រូប ការលើកកម្ពស់គុណភាពនៃការសិក្សារបស់សិស្ស និងការផ្តល់សេវាអប់រំប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ក្រសួងបានកែសម្រួលគោលនយោបាយអប់រំបីចំណុចមកពីរចំណុចវិញ ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា ជាពិសេសឆ្លើយតបនឹងអាទិភាពគោលនយោបាយអប់រំនានា ក្នុងការរួមចំណែកអនុវត្តគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ។ គោលនយោបាយអប់រំរយៈពេលមធ្យមពីរគឺ

- គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា
- គោលនយោបាយទី២ ៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រង របស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់

(ក្រសួងអប់រំយុវជននិងកីឡា, ផែនការយុទ្ធសាស្ត្រវិស័យអប់រំ, ឆ្នាំ២០១៩-២០២៣, ទំព័រ ១)

ក្រៅពីនេះ ក្រសួងក៏បានរៀបចំឱ្យមានគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចដែលមានចក្ខុវិស័យ កុមារតូចទាំងអស់ចាប់ពីកកំណើតរហូតដល់អាយុក្រោម ៦ឆ្នាំ ត្រូវទទួលបានសេវាគាំពារ និងអភិវឌ្ឍ ជាពិសេសកុមារតូចរងគ្រោះ កុមារក្រខ្សត់ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ គោលបំណង និងគោលដៅនៃគោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច មាន ៦ ចំណុច ១)ស្ត្រីទាំងអស់ទទួលបាននូវសេវាថែទាំ និងសេវាអប់រំសុខភាព ព្រមទាំងអាហារូបត្ថម្ភនៅពេលមានផ្ទៃពោះ ២)កុមារតូចទាំងអស់ទទួលបានការចុះបញ្ជីកំណើត ការថែទាំ ពិនិត្យសុខភាពជាប្រចាំ ថ្នាំបង្ការគ្រប់គ្រាន់ អាហារូបត្ថម្ភគ្រប់គ្រាន់ និងទទួលបានការហាត់រៀនពីដំបូង ៣)កុមារតូចទាំងអស់មានលក្ខណៈត្រៀមជាស្រេចដើម្បីចូលរៀនថ្នាក់ទី១ នៅអាយុ ៦ឆ្នាំ ៤)បុគ្គលិកបច្ចេកទេស អ្នកថែទាំកុមារតូច មាតាបិតា និងអ្នកអាណាព្យាបាលមានចំណេះដឹងគ្រប់គ្រាន់លើការគាំពារ និងអភិវឌ្ឍន៍កុមារតូច ៥)គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធទាំងអស់សហការគ្នាយ៉ាងជិតស្និត ដើម្បីដោះស្រាយបញ្ហាដែលទាក់ងនឹងការគាំពារ និងអភិវឌ្ឍន៍កុមារតូច និង៦)កុមារតូចចាប់ពីពេលប្រសូតរហូតដល់ពេលចូលរៀន មានការរីកចម្រើនផ្នែករាងកាយ ចំណេះដឹង ប្រាជ្ញា និងអារម្មណ៍ នៅតាមផ្ទះរបស់ខ្លួន ព្រមទាំងតាមមណ្ឌលដែលផ្តល់សេវាសុខភាព អាហារូបត្ថម្ភ អប់រំប្រកបដោយគុណភាព និងនិរន្តរភាព។ (ក្រសួងអប់រំយុវជននិងកីឡា, គោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍកុមារតូច, ២០១០)

ឈរលើមូលដ្ឋានគោលនយោបាយខាងលើក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចរបស់ប្រទេសកម្ពុជា រយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ដែលមានលក្ខណៈរួមបញ្ចូលគ្នា និងមានការសម្របសម្រួលជាមួយគ្នាទៅវិញទៅមកពីគ្រប់

វិស័យដែលពាក់ព័ន្ធ។ ផែនការសកម្មភាពជាតិនេះ មានគោលបំណងផ្តល់នូវការគាំទ្រចំពោះការគាំពារ និង អភិវឌ្ឍន៍កុមារតូចពហុវិស័យបញ្ចូលគ្នា ដល់កុមារតូចចាប់ពីកកំណើតដល់ក្រោម៦ឆ្នាំ រួមនិងមាតាបិតា ឬ អាណាព្យាបាលពាក់ព័ន្ធនឹងការចិញ្ចឹមកូន ការថែទាំកូន ការភ្ញោច ដើម្បីជួយកូនឱ្យទាន់ពេលវេលា ការផ្តល់ អាហារូបត្ថម្ភ ការគាំពារសុខភាព ការអប់រំ និងអនាម័យ សំដៅការពារ និងលើកកម្ពស់ការអភិវឌ្ឍផ្នែក សុខភាពនិងរាងកាយ អភិវឌ្ឍន៍ផ្នែកសីលធម៌និងវប្បធម៌ អភិវឌ្ឍន៍ផ្នែកសង្គមនិងអារម្មណ៍ និងអភិវឌ្ឍន៍ផ្នែក បញ្ញានិងការគិតរបស់កុមារ ជាពិសេសកុមារមកពីគ្រួសារក្រីក្រ កុមារជនជាតិដើមភាគតិច និងកុមារមាន ពិការភាព។ (គណៈកម្មការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច, ២០១៤)

ដោយផ្អែកលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់វិស័យអប់រំកន្លងមក ក្រសួងអប់រំ យុវជន និង កីឡា បានបន្តប្តេជ្ញាចិត្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ទាំង១៥ចំណុច ដោយឈរលើ មូលដ្ឋានសសរស្តម្ភទាំង៤ គឺសសរស្តម្ភទី១ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន សសរស្តម្ភទី២ ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថានសិក្សា សសរស្តម្ភទី៣ ការដាក់ឱ្យអនុវត្តអធិការកិច្ច សសរស្តម្ភទី៤ ការពង្រឹងវង្វាយតម្លៃសិក្សា ដូចជា ការប្រឡង វង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ និងសសរស្តម្ភទី៥ ការកែទម្រង់ឧត្តមសិក្សា។

ក្នុងបរិបទថ្មីរបស់ប្រទេសជាតិ ក្រសួងអប់រំ យុវជន និងកីឡា បានបន្តកែលម្អប្រព័ន្ធអប់រំ កែទម្រង់ កម្មវិធីសិក្សា តាក់តែងសៀវភៅសិក្សាថ្មី បំប៉នសមត្ថភាពជាថ្មីដល់គ្រូបង្រៀន ដើម្បីត្រៀមលក្ខណៈផ្តើម អនុវត្តប្រព័ន្ធអប់រំ១២ឆ្នាំ(៦+៣+៣) នៅក្នុងឆ្នាំសិក្សា១៩៩៦-១៩៩៧ (ការអប់រំនៅកម្ពុជា, កក្កដាឆ្នាំ ១៩៩៩)។ ក្រសួងអប់រំ យុវជន និងកីឡា មានការផ្លាស់ប្តូរគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាចំនួនពីរ លើករួចមកហើយ លើកទី១នៅឆ្នាំ១៩៩៦-២០០១ និងលើកទី២នៅឆ្នាំ២០០៥-២០០៩ (ក្រសួងអប់រំយុវ ជននិងកីឡា, គោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សា, ឆ្នាំ២០០៥-២០០៦)។

តាំងពីឆ្នាំ១៩៧៩ ដល់បច្ចុប្បន្ន ការអភិវឌ្ឍកម្មវិធីសិក្សាមានការផ្លាស់ប្តូរជាបួនដំណាក់កាលគឺ ដំណាក់កាលទី១ ឆ្នាំ១៩៨០ ដល់ឆ្នាំ ១៩៨៧ នាសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា កម្មវិធីសិក្សាមាន បីកម្រិត កម្មវិធីបឋមសិក្សាវិជ្ជាទូទៅ(កម្រិតសិក្សាទី១) កម្មវិធីកម្រិតសិក្សាទី២ និងកម្មវិធីកម្រិតសិក្សាទី ៣។ ដំណាក់កាលទី២៖ ពីឆ្នាំ១៩៨៧ ដល់ឆ្នាំ១៩៩៦ នាសម័យរដ្ឋកម្ពុជា កម្មវិធីសិក្សាត្រូវបានបែងចែកជា កម្មវិធីបឋមសិក្សាចំណេះទូទៅ(កម្រិតសិក្សាទី១) កម្មវិធីកម្រិតសិក្សាទី២ និងកម្មវិធីកម្រិតសិក្សាទី៣។ ដំណាក់កាលទី៣៖ ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០៥ នាសម័យព្រះរាជាណាចក្រកម្ពុជា កម្មវិធីសិក្សារួមមាន កម្មវិធីសិក្សាគោលសម្រាប់បឋមសិក្សា កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាបឋមភូមិ និងកម្មវិធីសិក្សា គោលសម្រាប់មធ្យមសិក្សាទុតិយភូមិ។ ដំណាក់កាលទី៤៖ ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៩ នាសម័យ ព្រះរាជាណាចក្រកម្ពុជាទី២ ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍគោលនយោបាយសម្រាប់អភិវឌ្ឍ កម្មវិធីសិក្សាចំណេះទូទៅ កម្មវិធីគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ (ពីថ្នាក់ទី១ដល់ទី៩) និង កម្មវិធី សិក្សាគោលសម្រាប់មធ្យមសិក្សាទុតិយកភូមិ(ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២)។

ក្នុងឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានអភិវឌ្ឍអភិវឌ្ឍកម្មវិធីសិក្សាបានរៀបចំ ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍ សហស្សវត្សរ៍ និងការអភិវឌ្ឍប្រកបដោយចីរភាព។ កំណែទម្រង់ស៊ីជម្រៅក្នុងវិស័យអប់រំ គឺអភិវឌ្ឍធនធាន មនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា និងកាយសម្បទា ជាកត្តាកំណត់ជោគជ័យនៃការអភិវឌ្ឍ លើវិស័យនានាទាំងអស់។ កម្ពុជាបានឆ្លងកាត់ពីឋានៈនៃប្រទេសមានចំណូលកម្រិតទាប ទៅជាប្រទេសមាន

ប្រាក់ចំណូលកម្រិតមធ្យមកម្រិតទាប ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចចក្ខុវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវកែទម្រង់លើគ្រប់វិស័យ ជាពិសេសវិស័យអប់រំ សុខាភិបាល កសិកម្ម ឧស្សាហកម្ម និងទេសចរណ៍។ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ផែនការអាទិភាពសម្រាប់កែទម្រង់វិស័យអប់រំរបស់ខ្លួន ជាពិសេសកំណែទម្រង់ការអប់រំគ្រូបង្រៀន និងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ដើម្បីធានាឱ្យកម្ពុជាមានធនធានមនុស្សដែលមានសមត្ថភាព សម្រាប់បម្រើការអភិវឌ្ឍគ្រប់វិស័យ។ ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសនេះ ត្រូវបានរៀបចំឡើងដើម្បីអប់រំ និងបណ្តុះបណ្តាលពលរដ្ឋកម្ពុជាឱ្យទៅជាពលរដ្ឋពេញលេញ តាមរយៈការធ្វើឱ្យកម្មវិធីសិក្សាមានលក្ខណៈស្តង់ដាអន្តរជាតិ ទាំងខ្លឹមសារ និងវិធីសាស្ត្ររៀននិងបង្រៀន ព្រមទាំងវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងគោលបំណងធ្វើឱ្យសមត្ថភាពសិស្សឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ នៅកម្រិតជាតិ តំបន់ និងពិភពលោក។ ខ្លឹមសារនៃក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស រួមមាន ១)សេចក្តីផ្តើម ២)ចក្ខុវិស័យនៃក្របខណ្ឌកម្មវិធីសិក្សា ៣)គោលបំណងនៃកម្មវិធីសិក្សា ៤)សមត្ថភាពសំខាន់ៗរបស់សិស្ស ៥)គោលបំណងតាមមុខវិជ្ជា និងមុខវិជ្ជារង ៦)មុខវិជ្ជាសិក្សានិងម៉ោងសិក្សាតាមភូមិសិក្សា ៧)គោលការណ៍នៃការបង្រៀន ៨)ការវាយតម្លៃការរៀននិងបង្រៀន ៩)ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន ១០)ការអនុវត្តក្របខណ្ឌកម្មវិធីសិក្សា (សមត្ថភាពរំពឹងទុក)។ (ក្រសួងអប់រំយុវជននិងកីឡា, ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស, ឆ្នាំ២០១៦)

ដោយឡែកសម្រាប់កម្មវិធីសិក្សានៅមត្តេយ្យសិក្សាក៏មានការផ្លាស់ប្តូរជាបន្តបន្ទាប់ដែរ។ ខាងក្រោមនេះ គឺជាសាវតារនៃកម្មវិធីសិក្សា ផ្នែកមត្តេយ្យសិក្សារដ្ឋរបស់នាយកដ្ឋានអប់រំកុមារតូច។ ក្រោយថ្ងៃរំដោះ ០៧ មករា ១៩៧៩ មត្តេយ្យសិក្សាបានចាប់ដំណើរការស្ថិតនៅក្រោមការគ្រប់គ្រងក្រុមការងារនាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា។ ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨០ កម្មវិធីសិក្សាមិនទាន់បានរៀបចំត្រឹមត្រូវនៅឡើយ។ ខែកុម្ភៈ ឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៩៩ កម្មវិធីសិក្សា និងកាលវិភាគ សម្រាប់មត្តេយ្យសិក្សាទាំង៣កម្រិត(កម្រិតទាប មធ្យម និងកម្រិតខ្ពស់) ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមរៀបចំដោយបែងចែកមេរៀនទៅតាមត្រីមាសទី១ ដល់ត្រីមាសទី៣ ហើយរៀបចំចេញជាសៀវភៅកម្រងអត្ថបទមត្តេយ្យសិក្សាទាំងបីកម្រិត។ ឆ្នាំ២០០០ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំចេញជាពង្រាងណែនាំកម្មវិធីសិក្សាទាំង៣កម្រិត សម្រាប់គ្រូមត្តេយ្យសិក្សា ហើយផ្សព្វផ្សាយឱ្យអនុវត្តហូតដល់ឆ្នាំ២០០៦ ដោយរៀបចំទៅតាមត្រីមាសទី១ ដល់ត្រីមាសទី៣។ ឆ្នាំ២០០៧ មកដល់បច្ចុប្បន្នកម្មវិធីសិក្សាសម្រាប់ថ្នាក់កម្រិតខ្ពស់ និងថ្នាក់កម្រិតមធ្យម ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកែសម្រួលឱ្យមានការខុសប្លែកពីមុន ដោយបែងចែកលម្អិតមេរៀនទៅតាមមុខវិជ្ជាទាំង១០ ចែកទៅតាមថ្ងៃនៃខែនីមួយៗ ដោយរាប់តែចំនួនថ្ងៃដែលត្រូវបង្រៀន ឯថ្នាក់កម្រិតទាបអនុវត្តកម្មវិធីសិក្សាតាមរបៀបឆ្នាំ២០០០ ដដែល។ មត្តេយ្យសិក្សាមានមុខវិជ្ជាចំនួន១០ គឺ ចិត្តចលភាព បុរេសំណេរ បុរេគណិត វិទ្យាសាស្ត្រ ចម្រៀង រឿងនិទាន កំណាព្យ គំនូរ សកម្មភាពកសាង ល្បែង និងមានសកម្មភាពចំនួន២ ត្រូវធ្វើជារៀងរាល់ថ្ងៃនោះ គឺសកម្មភាពប្រចាំថ្ងៃ(ការគួរសមនៅពេលចូលថ្នាក់រៀន ពិនិត្យវត្តមានកុមារប្រចាំថ្ងៃ បង្ហាញកាលបរិច្ឆេទ បង្ហាញពីទម្លាប់ល្អ និងបង្ហាញពីសកម្មភាពដែលត្រូវរៀនក្នុងមួយថ្ងៃ) ការវាយតម្លៃលទ្ធផលសិក្សារបស់កុមារប្រចាំថ្ងៃ សប្តាហ៍ ខែ ត្រីមាស និងអនាម័យទៅផ្ទះ ដែលគ្រូត្រូវអនុវត្តដើម្បីឱ្យកុមារទទួលបានសមត្ថភាព និងចំណេះដឹងពេញលេញទៅតាមស្តង់ដានៃកម្រិតអាយុរបស់កុមារ។ កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សាទាំងបីកម្រិតដំបូងបានរៀបចំបែងចែកមេរៀននៃមុខវិជ្ជាទៅតាមត្រីមាសទី១ ត្រីមាសទី២ និងត្រីមាសទី៣ ដោយបាន

ចងក្រងជាឯកសារពង្រាងលំណែនាំកម្មវិធីសិក្សាទាំងបីកម្រិតថ្នាក់ រួចផ្សព្វផ្សាយឱ្យអនុវត្ត។ នាយក/នាយិកា តាមសាលានីមួយៗ បានយកកម្មវិធីសិក្សារបស់ក្រសួងអប់រំទាំងបីកម្រិតថ្នាក់ មកបែងចែកលម្អិតទៅតាមខែ តាមសប្តាហ៍ ផ្សារភ្ជាប់ទៅនឹងស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាន ដោយមានការចូលរួមពីគ្រូបង្រៀន និងប្រធានក្រុមបច្ចេកទេស រួចផ្សព្វផ្សាយឱ្យគ្រូអនុវត្ត។ កម្មវិធីសិក្សាសម្រាប់កុមារអាយុ៥ឆ្នាំ បានកែសម្រួលនៅឆ្នាំ២០០៧ និងបានរៀបចំបែងចែកមេរៀននៅក្នុងមុខវិជ្ជាទាំង១០ ទៅតាមថ្ងៃនៃខែនីមួយៗ ហើយបានកាត់ថ្ងៃឈប់សម្រាកចេញទាំងអស់ ព្រមទាំងរៀបចំឡើងផ្អែកលើកម្មវិធីសិក្សាចាស់ និងស្តង់ដាសិក្សាសម្រាប់កុមារអាយុ៥ឆ្នាំ ដោយបានកំណត់ឱ្យមានប្រធានបទមួយក្នុង១ខែ ដូច្នេះ កម្មវិធីសិក្សា១០ខែ មានប្រធានបទចំនួន១០ដែរ ព្រមទាំងមានរៀបចំឯកសារសម្រាប់ជំនួយគ្រូ ភ្ជាប់ជាមួយដែលមានខ្លឹមសារក្រៅពីឯកសារគោល។ កម្មវិធីសិក្សានេះ បានផ្សព្វផ្សាយឱ្យអនុវត្តសាកល្បងនៅតាមសាលាមត្តេយ្យសិក្សាទូទាំងប្រទេស រយៈពេល ១ឆ្នាំសិក្សាសិន គឺនៅឆ្នាំ២០០៧។ បានកែសម្រួលឡើងវិញក្រោយពីបានព័ត៌មានត្រឡប់ពីរាជធានី/ខេត្ត រួចផ្សព្វផ្សាយឱ្យអនុវត្តជាផ្លូវការចាប់ពីឆ្នាំ២០០៨ និងបោះពុម្ពប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩។ (នាយកដ្ឋានអប់រំកុមារតូច, បទបង្ហាញស្តីពីទិដ្ឋភាពទូទៅនៃកម្មវិធីសិក្សា) ទោះបីជាកម្មវិធីសិក្សាសម្រាប់កុមារអាយុ៥ឆ្នាំ បានប្រើប្រាស់ទូទាំងប្រទេសរួចហើយក្តី ក៏ការអនុវត្តកម្មវិធីសិក្សាទាំងនោះជួបនូវបញ្ហាជាច្រើន។ តាមរយៈលទ្ធផលការចុះពិនិត្យតាមដាន និងតាមការប្រមូលព័ត៌មាន បានបង្ហាញថា សកម្មភាពបង្រៀន និងរៀនរបស់កុមារភាគច្រើន មិនបានទទួលគុណភាពសិក្សាតាមកម្រិតស្តង់ដាពេញលេញនោះទេ។ ជាពិសេសសកម្មភាព និងពេលវេលាក្នុងកម្មវិធីដែលមានស្រាប់មិនបានជំរុញឱ្យគ្រូមត្តេយ្យសិក្សាធ្វើការសិក្សាស្រាវជ្រាវ ស្រង់បទពិសោធសម្រាប់នាំកុមារទទួលបានការអភិវឌ្ឍតាមស្តង់ដាដែលបានកំណត់។ ម្យ៉ាងទៀត កម្មវិធីសិក្សាដែលមានស្រាប់មិនទាន់មានលក្ខណៈទំនើបកម្មដូចបណ្តាប្រទេសក្នុងតំបន់នៅឡើយ។ (នាយកដ្ឋានអប់រំកុមារតូច, របាយការណ៍ស្តីពីដំណើរការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ, ឆ្នាំ២០១៤) នៅខែមករា ឆ្នាំ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា បានបើកសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការកែលម្អកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ ដែលមានការចូលរួមពីមន្ត្រីទទួលបន្ទុកការងារអប់រំកុមារតូចថ្នាក់មន្ទីរ នាយិកាសាលា ប្រធានក្រុមបច្ចេកទេស អញ្ជើញមកពី១២ខេត្ត នាយកដ្ឋានពាក់ព័ន្ធចំនួន៤ និងដៃគូអភិវឌ្ឍចំនួន១០ ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ មកដល់ឆ្នាំ២០១៦ ក្រសួងក៏បានរៀបចំក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ចាប់ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សា ហើយក៏បានអនុម័តឱ្យប្រើប្រាស់ជាផ្លូវការ ចាប់ពីខែមីនា ឆ្នាំ២០១៧ តទៅ។ បន្ទាប់ពីក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស បានប្រកាសផ្សព្វផ្សាយដាក់ឱ្យអនុវត្តជាផ្លូវការមក នាយកដ្ឋាននីមួយៗ ត្រូវរៀបចំកម្មវិធីសិក្សាលម្អិតរៀងៗខ្លួន ដូច្នេះ ទើបក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងរៀបចំកម្មវិធីសិក្សាផ្នែកមត្តេយ្យសិក្សារដ្ឋ ដែលមានសមាសភាពជាថ្នាក់ដឹកនាំក្រសួង នាយកដ្ឋានជំនាញ និងអង្គការពាក់ព័ន្ធមួយចំនួន។ នៅខែកុម្ភៈ ឆ្នាំ២០១៨ នាយកដ្ឋានអប់រំកុមារតូច បានបើកសិក្ខាសាលាស្តីពីការអនុវត្តសាកល្បងកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ ដើម្បីអភិវឌ្ឍសមត្ថភាពអ្នកជំនាញកុមារតូចថ្នាក់មូលដ្ឋាន ស្តីពីការរៀបចំផែនការបង្រៀនប្រចាំឆ្នាំ ប្រចាំខែ សប្តាហ៍ ប្រចាំថ្ងៃ និងការអនុវត្តសាកល្បងកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ ដល់សាលាមត្តេយ្យសិក្សាធនធានប្រចាំរាជធានី ខេត្ត ចំនួន ២៥។ លុះដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡា បានផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការ កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុជន និងកីឡា។ (នាយកដ្ឋានអប់រំ

កុមារតូច, របាយការណ៍ស្តីពីដំណើរការនៃការរៀបចំកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា, ឆ្នាំ ២០១៨)

### ១.២.ចំណោទបញ្ហានៃការស្រាវជ្រាវ

យោងសមិទ្ធផលដែលសម្រេចបានក្នុងវិស័យអប់រំ និងបញ្ហាប្រឈមនៃការអប់រំមត្តេយ្យសិក្សា បានបង្ហាញថាកុមារនៅតំបន់ជនបទ និងដាច់ស្រយាល ជាពិសេសកុមារក្រីក្រ និងកុមារជួបការលំបាកមានលទ្ធភាពចូលរៀនតិចតួចប៉ុណ្ណោះ។ គុណភាពនៃការអប់រំកុមារតូចជាកង្វល់មួយដ៏ធំធេងផងដែរ។ ការវាយតម្លៃអំណានដំបូងដែលបានធ្វើនៅឆ្នាំ២០១០ និង២០១២ បង្ហាញថា កុមារកម្ពុជាពុំទាន់ត្រៀមខ្លួនឱ្យបានគ្រប់គ្រាន់ដើម្បីចូលរៀននៅបឋមសិក្សាឡើយ។ តេស្តវាយតម្លៃអំណានថ្នាក់ដំបូងឆ្នាំ២០១២ បានបង្ហាញថាសិស្សថ្នាក់ទី១ ពាក់កណ្តាលពុំអាចចំណាំអក្សរណាមួយបានឡើយ និងពីរភាគបីនៃសិស្សថ្នាក់ទី១ ពុំអាចអានពាក្យដែលពួកគេធ្លាប់បានឃើញណាមួយបានឡើយ។ ដូចគ្នានេះដែរសិស្សថ្នាក់ទី២ ពាក់កណ្តាលពុំអាចអានពាក្យដែលពួកគេពុំធ្លាប់រៀនហើយណាមួយបានឡើយ។ បញ្ហាប្រឈមទាក់ទងនឹងលទ្ធភាពចូលរៀន និងគុណភាពអប់រំ អាចបណ្តាលមកពីកង្វះគ្រូបង្រៀន ឬគុណវុឌ្ឍិអ្នកអប់រំកុមារតូច និងកង្វះលិខិតបទដ្ឋានគតិយុត្ត និងការពិនិត្យតាមដានបុគ្គលិកដែលកំពុងចូលរួមអនុវត្តកម្មវិធីអប់រំកុមារតូចគ្រប់រូបភាព ការផ្តល់ថវិកាពុំបានគ្រប់គ្រាន់ ក្របខណ្ឌគោលនយោបាយមិនទាន់ល្អ ការសម្របសម្រួលពុំបានល្អ ក្នុងចំណោមវិស័យនានា ការពិនិត្យតាមដានពុំបានគ្រប់គ្រាន់ និងកង្វះសម្ភារៈសិក្សា។ (ក្រសួងអប់រំយុវជននិងកីឡា, ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ស្តីពីការអប់រំនៅកម្ពុជា, ឆ្នាំ ២០១៩)

យោងទៅលើការវាយតម្លៃបរិស្ថានសាលា ថ្នាក់រៀន និងសម្ភារៈសិក្សារបស់មត្តេយ្យសិក្សារដ្ឋ ចំនួន ៥០ និងថ្នាក់មត្តេយ្យសិក្សាសហគមន៍ ១០០កន្លែង តំណាងទូទាំងប្រទេស។ ជាលទ្ធផលនៃការវាយតម្លៃសាលាមត្តេយ្យរដ្ឋបានបង្ហាញថា ១)បរិវេណនិងសង្ហារិម(លទ្ធផល៥០%) ២)ភាសានិងការពិចារណា (លទ្ធផល៤៤%) ៣)អន្តរកម្មគ្រូនិងកុមារ(លទ្ធផល៣៦%) ៤)រចនាសម្ព័ន្ធនៃកម្មវិធី(លទ្ធផល៤៨%) និង៥)មាតាបិតានិងគ្រូបង្រៀន(លទ្ធផល៤៨%)។ ការអនុវត្តកម្មវិធីសិក្សា និងកាលវិភាគនៅសាលារៀន និងថ្នាក់រៀននៅមត្តេយ្យសិក្សារដ្ឋសម្រាប់ថ្នាក់កម្រិតទាបសម្រេចបាន ៧២.២០% ថ្នាក់កម្រិតមធ្យម ៧៦.៤៥% និងថ្នាក់កម្រិតខ្ពស់សម្រេចបាន៨៧.២៤% នៃកម្មវិធីសិក្សាប្រចាំឆ្នាំ។ សកម្មភាពល្បែងសេរីបានអនុវត្តនៅតាមថ្នាក់រៀនមត្តេយ្យសិក្សារដ្ឋ ១៩ថ្នាក់ ក្នុងនោះ ១០ថ្នាក់ នៅរាជធានីភ្នំពេញ។ បញ្ហាប្រឈមមួយចំនួនទៀតដែលចាំបាច់ត្រូវមានការខិតខំប្រឹងប្រែងដោះស្រាយមានដូចជា៖ ១)សមត្ថភាព និងធនធានក្នុងការអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃនៅមិនទាន់ឆ្លើយតប ២)ចំនួនគ្រូមត្តេយ្យសិក្សាបណ្តុះបណ្តាលថ្មីមិនឆ្លើយតបទៅនឹងតម្រូវការពង្រីកសេវា ៣)អគារ ថ្នាក់រៀន ទាំងថ្នាក់កំពុងដំណើរការ និងថ្នាក់បង្កើតថ្មីមិនទាន់សមស្របនិងគ្រប់គ្រាន់ ៤)សម្ភារៈបរិក្ខា សម្ភារៈបង្រៀននិងរៀន សម្រាប់ដំណើរការថ្នាក់មត្តេយ្យសិក្សាមិនទាន់សមស្របតាមតម្រូវការអភិវឌ្ឍរបស់កុមារតូច។ (ក្រសួងអប់រំយុវជននិងកីឡា, សន្និបាតបូកសរុបលទ្ធផលការងារអប់រំយុវជននិងកីឡាឆ្នាំសិក្សា២០១៥-២០១៦និងទិសដៅឆ្នាំសិក្សា ២០១៦-២០១៧, ឆ្នាំ២០១៧)

ទោះបីកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា បានដាក់ឱ្យប្រើប្រាស់ទូទាំងប្រទេសនៅឆ្នាំ ២០១៨ ក្តី ក៏ការអនុវត្តកម្មវិធីនោះជួបបញ្ហាជាច្រើន។ តាមរយៈលទ្ធផលការចុះពិនិត្យតាមដាន និងតាមការប្រមូលព័ត៌មានបានបង្ហាញថា (១)ការរៀបចំផែនការបង្រៀន៖ មុខវិជ្ជាសិក្សាសង្គមមានសកម្មភាពរងច្រើន

ហើយប្រធានបទខ្លះលទ្ធផលសិក្សាមិនស៊ីគ្នាទៅនឹងម៉ោងសិក្សា ប្រធានបទខ្លះទៀតលទ្ធផលសិក្សាមិនដឹងយកទៅបញ្ចូលទៅក្នុងសកម្មភាពរងណាមួយ និងពិបាករកចំណងជើងមេរៀនសម្រាប់អនុវត្តប្រធានបទ និងខ្លឹមសារមួយចំនួនហាក់បីដូចជាជាន់គ្នាក្នុងមុខវិជ្ជាផ្សេងៗ ហើយពេលវេលានៃការរៀបចំផែនការបង្រៀនប្រចាំខែ សប្តាហ៍ មានរយៈពេលខ្លី មិនបានគិត និងស្រាវជ្រាវឯកសារឱ្យបានជាក់លាក់ច្បាស់លាស់តាមមុខវិជ្ជានីមួយៗ ដូច្នេះការជ្រើសរើសចំណងជើងមេរៀនសម្រាប់អនុវត្តមិនស៊ីគ្នាទៅនឹងលទ្ធផលសិក្សារួមក្នុងកម្មវិធីសិក្សាថ្មី និងមិនទាន់បានតាមលំដាប់ពីងាយទៅលំបាក។ (២)ការអនុវត្តផែនការបង្រៀនៈ កាលវិភាគសិក្សាក្នុងមួយថ្ងៃៗ មានមេរៀនជាប់គ្នាដល់ទៅ៣ម៉ោងសិក្សា ជាមូលហេតុធ្វើឱ្យកុមារធុញទ្រាន់ និងចង់ចេញលេងក្រៅថ្នាក់ ពិបាកក្នុងការគ្រប់គ្រងកុមារ ម៉ោងចេញលេងមានរយៈពេលខ្លី(១០នាទី) ការអនុវត្តកម្មវិធីសិក្សាសាកល្បងអនុវត្តចាប់ពីខែមីនា ប៉ុន្តែយកកម្មវិធីសិក្សាខែវិច្ឆិកាមកបង្រៀន ដូច្នេះ ចំនួនថ្ងៃមិនស្មើគ្នា និងការ ផលិតសម្ភារឧបទេសមិនបានគ្រប់គ្រាន់ទៅតាមមេរៀនក្នុងកម្មវិធីសិក្សា ព្រោះពុំមានធនធានថវិកា និងពេលវេលាគ្រប់គ្រាន់។ (នាយកដ្ឋានអប់រំកុមារតូច, របាយការណ៍បូកសរុបលទ្ធផលស្ដីពីការចុះប្រមូលព័ត៌មាននៃការអនុវត្តកម្មវិធីសិក្សាថ្មីចំនួន៩ខេត្ត, ឆ្នាំ២០១៨)

ដោយសង្កេតឃើញនូវបញ្ហាប្រឈមនានា នៅក្នុងផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ លទ្ធផលសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ទិន្នន័យព័ត៌មាននៃការអនុវត្តសាកល្បងកម្មវិធីសិក្សាថ្មីឆ្នាំ២០១៨ និងដើម្បីបង្កើនគុណភាព ប្រសិទ្ធភាពអប់រំ រួមចំណែកអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ទើបអ្នកសិក្សាស្រាវជ្រាវបានសម្រេចចិត្តជ្រើសរើសប្រធានបទនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ស្ដីពី **"ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ"** នេះឡើង។

## ១.៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ មានគោលបំណងដូចខាងក្រោមៈ

១. សិក្សាពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ

២. សិក្សាពីឥទ្ធិពលនៃកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋទៅលើការអភិវឌ្ឍកុមារតូច

## ១.៤.សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងស្រាវជ្រាវទាំងពីរខាងលើនេះ សំណួរស្រាវជ្រាវត្រូវបានចោទសួរដូចខាងក្រោម ៖

១. តើស្ថានភាពនៃការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋមានលក្ខណៈដូចម្តេចខ្លះ?

២. តើកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋជះឥទ្ធិពលអ្វីខ្លះ ទៅលើការអភិវឌ្ឍកុមារតូច?

## ១.៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងបានជួយពង្រីកចំណេះដឹងបន្ថែម ស្ដីពីកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ បង្ហាញអំពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តកម្មវិធីសិក្សា និងលទ្ធផលសិក្សារបស់កុមារ។ ជាងនេះទៅទៀត លទ្ធផលដែលបានមកពីការសិក្សាស្រាវជ្រាវនេះ នឹងក្លាយជាព័ត៌មានដ៏សំខាន់សម្រាប់ជាជំនួយដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរៀបចំកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋឱ្យកាន់មានភាពល្អប្រសើរថែមទៀត ដើម្បីឆ្លើយតបកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងអប់រំ យុវជន និងកីឡា លើការអភិវឌ្ឍ

កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។ ការសិក្សាស្រាវជ្រាវនេះ គឺជាទុនដ៏ប្រសើរមួយសម្រាប់អ្នកសិក្សាជំនាន់ក្រោយអាចសិក្សាលម្អិតបន្តជាងនេះ និងជាប្រយោជន៍ក្នុងការលើកកម្ពស់គុណភាពអប់រំកុមារតូចនៅកម្ពុជា។

## ១.៦.ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវមានដំណើរការទៅបានល្អ និងវិភាគបានគ្រប់ជ្រុងជ្រោយលើប្រធានបទ **"ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ" ករណីសិក្សា ៖ ខេត្តកណ្តាល** យើងផ្តោតទៅលើកុមារមត្តេយ្យសិក្សាអាយុ៥ឆ្នាំ(ថ្នាក់កម្រិតខ្ពស់) ដែលបានអនុវត្តកម្មវិធីសិក្សាលម្អិតថ្មីចាប់ពីឆ្នាំ២០១៨ តែប៉ុណ្ណោះ។ ដែនកំណត់នៃការសិក្សាស្រាវជ្រាវបានជ្រើសរើសយកសាលាមត្តេយ្យសិក្សារដ្ឋ ដែលបានទទួលការបំប៉នស្តីពីការអនុវត្តកម្មវិធីសិក្សាលម្អិត ដោយក្រសួងអប់រំ យុវជន និងកីឡា ស្ថិតនៅខេត្តកណ្តាល មានសាលាមត្តេយ្យសិក្សារដ្ឋចំនួន១៩ ក្នុងក្រុង/ស្រុក ចំនួន០៧ រួមមាន ៖ ក្រុងតាខ្មៅ ស្រុកកៀនស្វាយ ស្រុកអង្គស្នួល ស្រុកស្អាង ស្រុកកោះធំ ស្រុកល្វាឯម និងស្រុកខ្សាច់កណ្តាល។ នៅក្នុងការសិក្សាស្រាវជ្រាវនេះ យើងបានរៀបចំជាកម្រងសំណួរសម្រាប់សម្ភាសន៍លោក/លោកស្រីជានាយក/នាយិកា គ្រូមត្តេយ្យសិក្សា មាតាបិតាកុមារ និងការធ្វើតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ។ ដូចនេះ ដែនកំណត់នៃការសិក្សាស្រាវជ្រាវយើងជ្រើសរើសយកនាយក/នាយិកា គ្រូមត្តេយ្យសិក្សា ចំនួន ១០០% នៃស្រុកគោលដៅទាំង៧ មាតាបិតាកុមារចំនួន ២០នាក់ និងជ្រើសរើសយកវិភាគសំណាកកុមារអាយុ៥ឆ្នាំ ត្រឹមតែ ៣០៣នាក់ប៉ុណ្ណោះ នៅក្នុងប្រភេទគំរូខាងលើមកធ្វើការវិភាគ។

## ១.៧.វិធីប្រមូលនិងការវិភាគទិន្នន័យ

កាសិក្សាស្រាវជ្រាវនេះ ត្រូវបានប្រើប្រាស់វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ និងធ្វើការវិភាគទិន្នន័យតាមបីដំណាក់កាលដូចខាងក្រោម ៖

**ការប្រមូលទិន្នន័យបឋម ៖**

- បំពេញកម្រងសំណួររបស់នាយក/នាយិកា គ្រូមត្តេយ្យសិក្សា និងមាតាបិតាកុមារ
- តេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ

**ការប្រមូលទិន្នន័យបន្ទាប់បន្សំ ៖**

- ឯកសារពាក់ព័ន្ធ
- ស្នាដៃស្រាវជ្រាវពីមុនៗ

**ការវិភាគទិន្នន័យ ៖**

- ប្រើប្រព័ន្ធ Microsoft Excel
- ប្រព័ន្ធវិភាគទិន្នន័យ SPSS

## ១.៨.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ ត្រូវបានធ្វើការបែងចែកចេញជា ៥ ជំពូកធំៗ ដូចខាងក្រោម ៖

1. **ជំពូកទី១ សេចក្តីផ្តើម** ៖ ជំពូកនេះបង្ហាញពីសាវតារនៃប្រព័ន្ធអប់រំនៅកម្ពុជា គោលបំណងនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ លំនាំនៃការស្រាវជ្រាវ និងសារៈសំខាន់នៃការស្រាវជ្រាវ។
2. **ជំពូកទី២ រំលឹកទ្រឹស្តី** ៖ ក្នុងជំពូកនេះសិក្សាទៅលើទ្រឹស្តី និងបទបញ្ញាត្តិនានា ដែលពាក់ព័ន្ធទៅនឹងចំណុចដែលបានចោទសួរនៅក្នុងចំណោទបញ្ហា។
3. **ជំពូកទី៣ វិធីសាស្រ្តស្រាវជ្រាវ** ៖ ក្នុងជំពូកនេះត្រូវបង្ហាញពីគម្រោងវិភាគ និងវិធីសាស្រ្តស្រាវជ្រាវដែលបញ្ជាក់ពី អត្ថប្រយោជន៍នៃប្រធានបទ វិសាលភាពនៃការសិក្សាស្រាជ្រាវ និងបង្ហាញពីទំនាក់ទំនងរវាងចំណុចនីមួយៗ ដែលបានចោទក្នុងចំណោទបញ្ហាទៅនឹងប្រធានបទ។
4. **ជំពូកទី៤ លទ្ធផលនិងការពិភាក្សា** ៖ ក្នុងជំពូកនេះ ត្រូវលើកឡើងពីលក្ខណៈជាក់ស្តែង ដែលយើងបានធ្វើការសិក្សាស្រាវជ្រាវ ហើយចំណុចដែលត្រូវលើកឡើង គឺត្រូវឱ្យចូលទៅក្នុងចំណុចទាំងអស់ ដែលបានចោទសួរក្នុងចំណោទបញ្ហា។ ការពិភាក្សាលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ វិភាគទៅលើចំណុចខ្លាំងទាំងអស់ដែលកំពុងអនុវត្តជាក់ស្តែង ថាតើវាដូចគ្នាទៅនឹងទ្រឹស្តីដែរឬទេ គឺធ្វើឡើងក្នុងគោលបំណងវិភាគឱ្យឃើញនូវចំណុចខ្វះខាត ដើម្បីធ្វើការកែលម្អឡើងវិញ(គឺវិភាគកម្រងសំណួរ)។
5. **ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងការផ្តល់សំណូមពរ** ៖ ក្នុងជំពូកនេះ ត្រូវធ្វើការបង្ហាញនូវសេចក្តីសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ដែលបានវិភាគ និងផ្តល់យោបល់ទៅលើចំណុចដែលត្រូវកែលម្អ ឬចំណុចខ្វះខាត។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១.និយមន័យ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវលើប្រធានបទ "**ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ" ករណីសិក្សា ៖ ខេត្តកណ្តាល** នេះមានភាពច្បាស់លាស់ និងងាយស្រួលនោះ អ្នកសិក្សាស្រាវជ្រាវបានកំណត់ពាក្យគន្លឹះមួយចំនួនដូចតទៅ ៖

**កម្មវិធីសិក្សា** ៖ គឺជាក្របខណ្ឌអនុវត្តចំណេះដឹង និងបទពិសោធដែលមានឡើង ដើម្បីអភិវឌ្ឍដល់សិស្សានុសិស្សឱ្យមានចំណេះដឹង ជំនាញ និងលក្ខណៈសម្បត្តិដែលបានកំណត់ទុក។ កម្មវិធីសិក្សាប្រៀបដូចជាផែនទីកំណត់ទិសដៅនៃការអភិវឌ្ឍដល់សិស្សានុសិស្សឱ្យឈានដល់មាត្រដ្ឋាន នៃការរៀនសូត្រដែលជាគោលដៅ និងមានការវាយតម្លៃ ការស្វែងយល់ ដើម្បីឱ្យជ្រួតជ្រាបពីការវិវឌ្ឍទៅមុខនៃសិស្សានុសិស្សម្នាក់ៗ ក្នុងការអភិវឌ្ឍឈានទៅដល់ស្តង់ដាដែលបានកំណត់។ (ក្រសួងអប់រំយុវជននិងកីឡា, ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស, ឆ្នាំ២០១៦, ទំព័រ ២៦)

## ២.២.ទស្សនៈផ្សេងៗ ស្តីពីកម្មវិធីសិក្សា

### ២.២.១.និយមន័យកម្មវិធីសិក្សា

កម្មវិធីសិក្សា គឺជាមុខវិជ្ជា «អចិន្ត្រៃយ៍» ដូចជា វេយ្យាករណ៍ អំណាន វោហាសាស្ត្រ តក្កវិជ្ជា គណិតវិទ្យា និងជាសៀវភៅដ៏អស្ចារ្យនៃលោកខាងលិច ដែលបានបញ្ចូលចំណេះដឹងសំខាន់ៗ ហើយល្អបំផុត។ កម្មវិធីសិក្សា គឺជាមុខវិជ្ជាទាំងឡាយដែលមានប្រយោជន៍បំផុត សម្រាប់ការរស់នៅក្នុងសង្គមសម័យបច្ចុប្បន្ន។ កម្មវិធីសិក្សា គឺជាផែនការនៃការសិក្សាទាំងអស់ដែលបានគ្រោងទុកសម្រាប់សាលារៀនប្រកបដោយការទទួលខុសត្រូវខ្ពស់។ កម្មវិធីសិក្សា គឺជាលទ្ធផលសរុបនៃបទពិសោធក្នុងការសិក្សាដែលបានផ្តល់ដល់សិស្ស ដើម្បីឱ្យពួកគេអាចទទួលបាននូវបំណិនទូទៅ និងជំនាញនានា ទៅតាមស្ថានភាពនៃតំបន់(បរិបទ)ដែលត្រូវសិក្សារៀនសូត្រ។ កម្មវិធីសិក្សា គឺជាអ្វីៗ ដែលសិស្សទទួលបានពីការងារដោយកុំព្យូទ័ររបស់ខ្លួន និងពីបណ្តាញនានា ដូចជា អ៊ិនធឺណិត។ កម្មវិធីសិក្សា គឺជាចំណោទបញ្ហារបស់អ្នកជំនាញ និងការស្វែងយល់ពីទិដ្ឋភាពស្មុគស្មាញនៃស្ថានភាពរស់នៅរបស់មនុស្ស។ (វិទ្យាស្ថានជាតិអប់រំ, បទបង្ហាញស្តីពីសេចក្តីផ្តើមអំពីកម្មវិធីសិក្សា, ២០១៨)

### ២.២.២.ទស្សនៈផ្សេង ៗនៃកម្មវិធីសិក្សា

លោក Bonser (1920) បានឱ្យនិយមន័យថា «កម្មវិធីសិក្សា គឺជាបទពិសោធទាំងឡាយដែលអ្នកសិក្សារំពឹងទុកថានឹងទទួលបាននៅក្នុងសាលារៀន»។ ចំណែកលោក Caswell and Campbell (1935) បានឱ្យនិយមន័យថា «កម្មវិធីសិក្សា គឺជាការផ្សំឡើងនូវបទពិសោធទាំងឡាយដែលអ្នកសិក្សាទទួលបានក្រោមការបង្ហាត់បង្រៀនរបស់គ្រូ»។ រីឯលោក Smith, Stanley, and Shores (1957) បានឱ្យនិយមន័យថា «កម្មវិធីសិក្សា គឺជាការតម្រៀបបទពិសោធរបស់សិស្ស ឬនិស្សិត តាមលំដាប់លំដោយដើម្បីអប់រំពួកគេឱ្យចេះពីរបៀបគិត និងរបៀបធ្វើសកម្មភាពនានា។ សន្ធានុក្រមអប់រំនៅឆ្នាំ១៩៥៩ បានផ្តល់និយមន័យកម្មវិធីសិក្សាចំនួនបី៖ ១)កម្មវិធីសិក្សា គឺជាការតម្រៀបមេរៀន ឬការតម្រៀបខ្លឹមសារមេរៀនទៅតាមលំដាប់លំដោយនៃមុខវិជ្ជាដែលត្រូវរៀន ដើម្បីងាយស្រួលក្នុងការវាយតម្លៃការបញ្ចប់ការសិក្សារបស់

សិស្ស ឬដើម្បីងាយស្រួលចេញវិញ្ញាបនបត្រឯកទេសជាក់លាក់ទៅលើមុខជំនាញដែលគេសិក្សា ២)កម្មវិធីសិក្សា គឺជាការរៀបចំខ្លឹមសារមេរៀនទូទៅមួយ ឬជាការរៀបចំសម្ភារៈបង្រៀនជាក់លាក់មួយដែលសាលាគួរតែផ្តល់ទៅឱ្យអ្នកសិក្សា ដើម្បីឱ្យពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបញ្ចប់ការសិក្សា ឬទទួលបានវិញ្ញាបនបត្រ ជំនាញឯកទេស ឬជំនាញវិជ្ជាជីវៈ ៣)កម្មវិធីសិក្សា គឺជាបណ្តុំមុខវិជ្ជា និងបទពិសោធ ដែលអ្នកសិក្សាគួរតែទទួលបានក្រោមការបង្ហាត់បង្រៀនពីគ្រូ។ លោក Gagne នៅក្នុងឆ្នាំ១៩៦៧ បានឱ្យនិយមន័យថា «កម្មវិធីសិក្សា គឺជាការតម្រៀបខ្លឹមសារចំណេះដឹងទៅតាមលំដាប់លំដោយ ដើម្បីផ្តល់សមត្ថភាពចំណេះដឹងបន្ថែម ទៅលើអ្វីដែលអ្នកសិក្សាធ្លាប់មានពីមុនរួចមកហើយ»។ លោក Saylor និង Alexander នៅឆ្នាំ ១៩៧៤ បានឱ្យនិយមន័យថា «កម្មវិធីសិក្សាគឺជាមធ្យោបាយដើម្បីសម្រេចគោលដៅធំៗ ហើយជាប់ទាក់ទងទៅនឹងវត្ថុបំណងច្បាស់លាស់ ដែលគ្រឹះស្ថានសិក្សាផ្តល់ឱ្យអ្នកសិក្សានៃប្រទេសណាមួយ»។ លោក Johoson នៅក្នុងឆ្នាំ១៩៧៧ បានឱ្យនិយមន័យថា «កម្មវិធីសិក្សា គឺជាការតម្រៀបទៅតាមលំដាប់លំដោយនូវលទ្ធផលសិក្សាដែលបានគ្រោងទុក»។

### ២.២.៣.ភាពខ្លាំង និងភាពខ្សោយ នៃការរៀបចំកម្មវិធីសិក្សា

តាមរយៈនិយមន័យទាំងនេះ យើងសង្កេតឃើញមាននិន្នាការពីរ ដែលគេឱ្យនិយមន័យទៅលើកម្មវិធីសិក្សា៖

១. កម្មវិធីសិក្សាដែលផ្តោតលើការធ្វើឱ្យស៊ីជម្រៅលើមុខវិជ្ជាឯកទេសនីមួយៗ

២.កម្មវិធីសិក្សាដែលផ្តោតលើចំណេះដឹងនិងបទពិសោធរបស់អ្នកសិក្សាម្នាក់ៗ

*តើកម្មវិធីសិក្សាដែលផ្តោតលើការធ្វើឱ្យស៊ីជម្រៅលើមុខវិជ្ជាឯកទេសនីមួយៗ មានន័យដូចម្តេច?* គឺមានន័យថា៖

- ជាកម្មវិធីសិក្សាដែលសម្រួចឱ្យមានភាពច្បាស់លាស់ទៅលើមុខវិជ្ជានីមួយៗ
- ជាកម្មវិធីសិក្សាដែលមិនគិតពីអ្នកសិក្សាម្នាក់ៗ ជាមូលដ្ឋានទេ
- ជាកម្មវិធីសិក្សាដែលភ្ជាប់អ្នកសិក្សាទៅនឹងអ្វីដែលសង្គមចង់បាន ទោះបីជា អ្នកនោះមិនត្រូវការ និងមិនពេញចិត្តក៏ដោយ
- ជាកម្មវិធីសិក្សាដែលមានការលើកទឹកចិត្តតែអ្នកសិក្សាណាដែលពូកែ និងមានទេពកោសល្យខ្ពស់ក្នុងការរៀនតែប៉ុណ្ណោះ
- ជាកម្មវិធីសិក្សាដែលបញ្ចុកចំណេះដឹងដល់អ្នកសិក្សា និងយកគ្រូជាមជ្ឈមណ្ឌល
- ជាកម្មវិធីសិក្សាដែលយកសៀវភៅជាមូលដ្ឋាន ហើយវិធីសាស្ត្រក្នុងការបង្រៀន គឺឱ្យអ្នករៀនទន្ទេញចាំមាត់ ឱ្យអ្នករៀនមានការច្បាស់លាស់នឹងជំនាញរបស់ខ្លួន និងឱ្យមានការអភិវឌ្ឍបញ្ញាបែបអរូបី
- ជាកម្មវិធីសិក្សាដែលមិនបានផ្សារភ្ជាប់ចំណេះដឹងទៅនឹងបរិបទ ឬជីវភាពរស់នៅរបស់អ្នកសិក្សា ឬសហគមន៍របស់អ្នកសិក្សានោះទេ
- ជាកម្មវិធីសិក្សាដែលធ្វើឱ្យអ្នករៀនគ្រាន់តែដឹងៗ មិនមានគំនិតបង្កើតថ្មី

- ជាកម្មវិធីសិក្សាដែលវាយតម្លៃសមិទ្ធផលសិក្សារបស់សិស្សផ្អែកតែទៅលើស្តង់ដាតេស្ត និងភាពស៊ីជម្រៅនៃមុខវិជ្ជាតែប៉ុណ្ណោះ
- ជាកម្មវិធីសិក្សាដែលយកការស៊ីជម្រៅលើមុខវិជ្ជា ឬខ្លឹមសារឯកទេសជាការសំខាន់
- ជាកម្មវិធីសិក្សាដែលគ្រូចេះខ្លឹមសារមេរៀនច្បាស់លាស់ តែសិស្សអត់ចេះច្បាស់លាស់
- ជាកម្មវិធីសិក្សាដែលចាត់ទុកសិស្សទាំងអស់ដែលរៀនក្នុងថ្នាក់ជាមួយគ្នាមានចំណេះស្មើគ្នា
- ជាកម្មវិធីសិក្សា ដែលការរៀនផ្តោតតែទៅលើអ្វីដែលមានស្រាប់
- ជាកម្មវិធីសិក្សាដែលប្រើវិធីសាស្ត្របង្រៀនតាមគោលវិធីគ្រូមជ្ឈមណ្ឌល។

*តើកម្មវិធីសិក្សាដែលផ្តោតលើចំណេះដឹង និងបទពិសោធរបស់អ្នកសិក្សាម្នាក់ៗ មានន័យដូចម្តេច?*

គឺមានន័យថា៖

- ជាកម្មវិធីសិក្សាដែលមានលក្ខណៈច្នៃប្រឌិត/បត់បែនបាន និងផ្អែកទៅលើអ្វីដែលមានជាក់ស្តែង
- ជាកម្មវិធីសិក្សាដែលយកសិស្សធ្វើជាមូលដ្ឋាន ដោយគិតថាសិស្សទាំងអស់ពិតជាមិនអាចមានទេពកោសល្យដូចគ្នានោះទេ បើទោះជាពួកគេរៀនថ្នាក់ជាមួយគ្នាក៏ដោយ
- ជាកម្មវិធីសិក្សាដែលជំរុញឱ្យសិស្សមានឱកាសពង្រឹង និងពង្រីកសមត្ថភាពរបស់ពួកគេដូចៗគ្នា ដោយគិតថាអ្នករៀនទាំងអស់នោះសុទ្ធតែអាចធ្វើឱ្យមានការរីកចម្រើនល្អលាស់បាន
- ជាកម្មវិធីសិក្សា ដែលយកគ្រូឱ្យដើរតួនាទីជាអ្នកសម្របសម្រួលដល់ការរៀនសូត្រដោយផ្ទាល់របស់សិស្ស
- ជាកម្មវិធីសិក្សាដែលសិស្សអាចរៀនសូត្របានដោយខ្លួនឯង អាចដោះស្រាយបញ្ហាបានដោយខ្លួនឯង និងអាចអភិវឌ្ឍភាពទទួលខុសត្រូវ ប្រកបដោយគំនិតច្នៃប្រឌិតបានដោយខ្លួនឯង
- ជាកម្មវិធីសិក្សាដែលប្រើវិធីសាស្ត្រភ្ជាប់ជីវភាពរស់នៅរបស់សិស្សទៅនឹងសកម្មភាពរបស់សង្គមនាពេលអនាគត
- ជាកម្មវិធីសិក្សាដែលយកសកម្មភាពរបស់អ្នករៀនម្នាក់ៗ ធ្វើជាមូលដ្ឋាន
- កម្មវិធីសិក្សាដែលចាត់ទុកការអប់រំជាការស្តារ និងអភិវឌ្ឍសង្គម
- ជាកម្មវិធីសិក្សាដែលឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ ឬបាតុភូត ដែលគេអាចសង្កេតបាន
- ជាកម្មវិធីសិក្សាដែលអ្នករៀនត្រូវរៀនឱ្យមានចំណេះដឹង ជំនាញ និងអាចដោះស្រាយបញ្ហារបស់សង្គមបាន។ (វិទ្យាស្ថានជាតិអប់រំ, បទបង្ហាញស្តីពីសេចក្តីផ្តើមអំពីកម្មវិធីសិក្សា, ២០១៨)

## ២.៣.ការរៀន និងគោលការណ៍សំខាន់ៗ ក្នុងការអភិវឌ្ឍកម្មវិធីសិក្សា

### ២.៣.១.អត្ថប្រយោជន៍នៃចំណេះដឹងផ្នែកចិត្តសាស្ត្រ និងលំនាំនៃការរៀន

ចំណេះដឹងផ្នែកចិត្តសាស្ត្រ និងលំនាំនៃការរៀនរបស់សិស្ស ជួយដល់ការអភិវឌ្ឍកម្មវិធីសិក្សាមានអត្ថប្រយោជន៍៣យ៉ាងគឺ៖

- មានអត្ថប្រយោជន៍ក្នុងការជ្រើសរើស និងតម្រៀបខ្លឹមសារមេរៀន

- មានអត្ថប្រយោជន៍ក្នុងការជ្រើសរើសវិធីសាស្ត្ររៀន និងបង្រៀន
- មានអត្ថប្រយោជន៍ក្នុងការធ្វើផែនការសម្រាប់ឱ្យការរៀនមានលក្ខណៈប្រសើរបំផុតនៅពេលអនាគត។

### ២.៣.២.និយមន័យនៃការរៀន

ការរៀនគឺជាលំនាំមួយដែលនាំឱ្យមានការផ្លាស់ប្តូរ ហើយការផ្លាស់ប្តូរនោះបានមកពីការអនុវត្ត ឬក៏បានមកពីបទពិសោធដែលអ្នករៀនបានជួបប្រទះ។ ការរៀនគឺជាការផ្លាស់ប្តូរអាកប្បកិរិយា ឬឥរិយាបថជាវិជ្ជមានហើយជាអចិន្ត្រៃយ៍។ ការរៀនគឺជាការផ្សារភ្ជាប់នូវបទពិសោធរបស់បុគ្គលម្នាក់ៗ ហើយការរៀននេះ វាទាក់ទងទៅនឹងទេពកោសល្យ បញ្ញា ចិត្តចលករ ឬភាពឧស្សាហ៍ព្យាយាមរបស់បុគ្គលម្នាក់ៗ។

### ២.៣.៣.កត្តាដែលជះឥទ្ធិពលទៅដល់ការរៀន

ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែសារពាង្គកាយទាំងអស់ដំណើរការ។ នៅពេលសារពាង្គកាយទាំងអស់ដំណើរការ អ្វីៗនឹងមិននៅដដែលនោះទេ វាប្រាកដជាមានការផ្លាស់ប្តូរ។ ដូច្នេះ ក្នុងការអភិវឌ្ឍកម្មវិធីសិក្សាចំណុចសំខាន់ដែលអ្នកអភិវឌ្ឍកម្មវិធីសិក្សាត្រូវយកចិត្តទុកដាក់គឺ៖

១.កាយសម្បទារបស់អ្នករៀន (ភ្នែក ត្រចៀក បញ្ញា និងសុខភាព ជាដើម)

២.បទពិសោធ និងចំណេះដឹងដែលមានស្រាប់របស់អ្នករៀនមាន

៣.ភាពតស៊ូ និងភាពឧស្សាហ៍ព្យាយាមរបស់អ្នករៀន

៤.អារម្មណ៍ ចិត្តចលករ ការចង់បាន និងគោលដៅរបស់អ្នករៀន

៥.ចំណុចមួយទៀតដែលអ្នកអភិវឌ្ឍកម្មវិធីសិក្សាត្រូវតែដឹងដែរនោះគឺថា៖

- ការរៀនសូត្ររបស់អ្នករៀនគឺវាមានថ្ងៃល្អនិងថ្ងៃមិនល្អ វាមានថ្ងៃចុះនិងថ្ងៃឡើង
- ការរៀនក្នុងដំណាក់កាលដំបូង ជានិច្ចជាកាលតែងតែដំណើរការបានល្អ ដល់ពេលមេរៀនកាន់តែលំបាក ល្បឿននៃការរៀនសូត្រមានការថយចុះ
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែអ្នករៀនអនុវត្តជាប្រចាំ។ សរុបសេចក្តីមកអ្នករៀនត្រូវតែរៀនហើយរៀនទៀត រៀនដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែង។
- ការរៀនអាចមានប្រសិទ្ធភាពទៅបាន លុះត្រាតែចំណេះដឹងថ្មីវាស្រប ឬជួយអភិវឌ្ឍចំណេះដឹងដែលមានស្រាប់ ឬជាការផ្សំចូលគ្នា នូវចំណេះដឹងនិងបទពិសោធដែលគេមានពីមុន។ បើចំណេះដឹងថ្មីធ្វើឱ្យអ្នករៀនមិនយល់ ឬធុញថប់ អ្នករៀនប្រាកដជាមិនយកចិត្តទុកដាក់ ឬបំភ្លេចចោល បើទោះជាគេដឹងថាការទទួលយក ចំណេះដឹងថ្មី ធ្វើឱ្យគេក្លាយទៅជាមនុស្សល្អក៏ដោយ។
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែ អ្នករៀនបានត្រៀមលក្ខណៈជាមុន។ ត្រៀមលក្ខណៈជាមុនបានទាល់តែវាទាក់ទងទៅនឹងសមត្ថភាពរបស់អ្នករៀន ក្នុងការចូលរួមសកម្មភាពដែលគេចង់រៀន។ វាក៏អាស្រ័យទៅលើភាពចាស់ទុំរបស់បុគ្គលម្នាក់ៗ និងក៏អាស្រ័យទៅលើការបណ្តុះបណ្តាលផងដែរ។

- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែមានកត្តាជំរុញពីខាងក្រៅ ដូចជា៖ មានការលើកទឹកចិត្ត មានការផ្ដល់រង្វាន់ពិសេស ឬបានទទួលការសរសើរពីគ្រូបង្រៀន
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែចំណេះដឹង ត្រូវបានគេយកទៅអនុវត្ត ឬប្រើប្រាស់។
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែអ្នករៀនមានទំនុកចិត្តខ្លួនឯង មានគំនិតច្នៃប្រឌិត មានភាពជាអ្នកដឹកនាំ និងមានបំណងប្រាថ្នាចង់បានអ្វីមួយ។
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែមេរៀនដែលបានរៀននោះ វាទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃ។
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែកម្រិតមេរៀននោះ វាត្រូវទៅនឹងសមត្ថភាពរបស់អ្នករៀន
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែមជ្ឈដ្ឋានដែលនៅជុំវិញឱ្យតម្លៃទៅលើការរៀនសូត្រ
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែអ្នករៀនដឹងពីអត្ថប្រយោជន៍ នៃចំណេះដឹងមេរៀននីមួយៗ
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែអ្វីដែលត្រូវរៀន ជាអ្វីដែលអ្នករៀនចង់បានជាអ្វីដែលជាបំណងប្រាថ្នារបស់អ្នករៀន
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែខ្លឹមសារដែលគេត្រូវរៀននោះ វាមិនធ្វើឱ្យអ្នករៀនធុញទ្រាន់
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែមានការសប្បាយក្នុងការរៀន
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែខ្លឹមសារដែលត្រូវរៀននោះវាសមទៅនឹងវ័យរបស់អ្នករៀន
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែខ្លឹមសារដែលត្រូវរៀនមានការចូលរួមចងក្រងពីអ្នករៀន។
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែអ្នករៀនមានចំណាប់អារម្មណ៍ និងមានការចូលរួម
- ការរៀនអាចមានប្រសិទ្ធភាពទៅបានលុះត្រាតែអ្នករៀនចង់រៀនខ្លាំង និងគ្មានការភ័យខ្លាច។ បើការរៀនសូត្រស្ថិតនៅក្នុងសភាពគួរឱ្យភ័យខ្លាច ធ្វើឱ្យសមត្ថភាពនៃការរៀនក៏មានការថយចុះដែរ។ ផ្ទុយទៅវិញបើភាពតានតឹង ឬធុញថប់មានតិចនោះវាជួយឱ្យអ្នករៀនកាន់តែខិតខំប្រឹងប្រែងរៀនឡើងថែមទៀត។

### ២.៣.៤.បច្ចេកទេសសំខាន់ៗ ក្នុងការរៀន

ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការរៀន អ្នករៀនត្រូវមានបច្ចេកទេសរៀន ដូចខាងក្រោម៖

- **ត្រូវរៀនតាមរយៈធ្វើផែនការរៀនសូត្រឱ្យបានច្បាស់លាស់៖** ការធ្វើផែនការរៀនសូត្រអាចចែកចេញជាពីរផ្នែកគឺ ១)រៀនមួយផ្នែកម្ដងៗ ដោយមានការបែងចែកពេលវេលារៀនសូត្រឱ្យ

បានច្បាស់លាស់។ បានសេចក្តីថា មិនងប់ងល់នឹងការរៀនខ្លាំង ២)ការរៀនឱ្យសម្រេចនៅក្នុងពេលតែមួយដោយ ឥតមានការឈប់ ឬឥតមានការសម្រាក។

- **ត្រូវរៀនតាមរយៈមតិផ្តល់យោបល់ត្រឡប់៖** អ្នករៀនរៀនបានជោគជ័យនៅពេលចម្លើយរបស់គាត់មានគេជូនព័ត៌មានថាត្រូវ ឬខុស ហើយកិច្ចការរបស់គាត់ត្រូវគេជូនព័ត៌មានថាសំខាន់ ឬមិនសំខាន់។ ការដឹងពីលទ្ធផលនៃការរៀនធ្វើឱ្យអ្នករៀន រៀនបានកាន់តែលឿន និងធ្វើឱ្យគេកាន់តែមានការចាប់អារម្មណ៍ទៅលើការរៀន។ មានភស្តុតាងជាច្រើនបង្ហាញថា អ្នករៀនមានការរីកចម្រើនខ្លាំង នៅពេលមានគេប្រាប់ពីរបៀបរៀន និងរបៀបលើកកម្ពស់ក្នុងការរៀន។ អ្នករៀនដែលទទួលបានមតិផ្តល់យោបល់ត្រឡប់ជាប្រចាំ តែងតែរៀនបានល្អប្រសើរជាងអ្នករៀនដែលមិនបានទទួលមតិផ្តល់យោបល់ត្រឡប់។
- **ត្រូវរៀនតាមរយៈការរួមបញ្ចូលគ្នា៖** គឺជាការរៀនឱ្យបានទូលំទូលាយដោយមិនផ្តោតតែទៅលើផ្នែកណាមួយនោះទេ គឺផ្តោតទៅលើផ្នែកដែលទាក់ទងទាំងអស់ឧទាហរណ៍ បើឯកទេសប្រវត្តិវិទ្យា គឺមិនមែនរៀនតែមុខវិជ្ជាប្រវត្តិវិទ្យាប៉ុណ្ណោះទេ គឺត្រូវរៀនមុខវិជ្ជាទាំងអស់ដែលទាក់ទងនឹងមុខវិជ្ជាប្រវត្តិវិទ្យា។ ការធ្វើតេស្តសំខាន់ទៅលើការរៀនតាមវិធីនេះ គឺការវាស់ស្ទង់សមត្ថភាពគ្រប់ដណ្តប់រួម។
- **ត្រូវរៀនតាមរយៈការធ្វើពិសោធជាក់ស្តែង៖** ជាការរៀនដែលផ្តោតទៅលើសកម្មភាពផ្ទាល់របស់បុគ្គលម្នាក់ៗ នៅក្នុងក្រុម ដោយចាត់ទុកអ្នករៀនថាជាប្រភពទាញយកចំណេះដឹង
- **ត្រូវរៀនតាមរយៈការរំលឹកឡើងវិញជាញឹកញាប់៖** ការរំលឹកឡើងវិញជាកត្តាមួយដែលមានសារៈសំខាន់បំផុត ព្រោះការរំលឹកកាន់តែច្រើនធ្វើឱ្យយើងចេះកាន់តែច្រើន។ មធ្យោបាយនៃការរំលឹកឡើងវិញមានការទន្ទេញ អាចជួយយើងឱ្យចាំនូវអ្វីដែលបានរៀន ការរៀនឱ្យបានច្រើនសារ អាចជួយយើងឱ្យយល់កាន់តែច្បាស់ ការរំលឹកឱ្យបានទៀងទាត់ព្រោះវាជួយយើងកាត់បន្ថយការភ្លេច។

## ២.៤.ការរៀនរបស់កុមារតូច

កុមារចាប់ផ្តើមរៀនចាប់តាំងពីពេលដែលគេកកើតមកម្ល៉េះ។ កុមារកំពុងមានការរីកលូតលាស់ មិនចង់អង្គុយនៅមួយកន្លែងអស់រយៈពេលដ៏យូរនោះឡើយ។ ពួកគេពោរពេញដោយកម្លាំង ថាមពលភាពចង់ចេះ ចង់ដឹង ចង់រៀនសូត្រនូវអ្វីដែលថ្មីៗ និងពីការទំនាក់ទំនងគ្នាទៅវិញទៅមក ជាមួយអ្នកនៅជុំវិញខ្លួន ជាមួយវត្ថុទាំងឡាយ និងជាមួយព្រឹត្តិការណ៍ផ្សេងៗ នៅក្នុងមជ្ឈដ្ឋានរបស់ពួកគេ។ ដូច្នេះ ពួកគេអាចរៀនតាមរយៈ៖

### ២.៤.១.ការសង្កេត

កុមារស្វែងយល់ដោយសង្កេត និងសិក្សាអំពីអ្វីៗ ដែលជាវត្ថុពិត និងមិនពិតនៅជុំវិញខ្លួនគេ។ គេចង់ដឹង ពិនិត្យ សង្កេត ត្រិះរិះពិចារណា និងសួរសំណួរផ្សេងៗ ដែលពោរពេញទៅដោយចម្ងល់មិនឈប់ឈរលើវត្ថុ មនុស្ស សត្វ ធម្មជាតិ...។ ការផ្តល់ការសង្កេតដល់កុមារ គឺជាមធ្យោបាយមួយដ៏ល្អប្រសើរសម្រាប់ជួយកុមារឱ្យសិក្សា ដើម្បីអភិវឌ្ឍនូវចំណេះដឹង និងបំណិនក្នុងការរស់នៅប្រចាំថ្ងៃរបស់គេ។

### ២.៤.២.ការត្រាប់តាម (មនុស្ស សត្វ រុក្ខជាតិ ធម្មជាតិ)

ចាប់តាំងពីកំណើតមក ពួកគេរៀនត្រាប់តាមសកម្មភាពដដែលៗ តាមរយៈការទំនាក់ទំនងគ្នាទៅវិញទៅមកជាមួយអ្នកនៅជុំវិញខ្លួន ជាមួយវត្ថុទាំងឡាយ និងជាមួយព្រឹត្តិការណ៍ផ្សេងៗ នៅក្នុងមជ្ឈដ្ឋានរបស់ពួកគេ ដូចជាការត្រាប់តាមមនុស្សដែលនៅជុំវិញខ្លួនៈ កុមារថាតាម ការនិយាយ ការរាំ ច្រៀង ការស្លៀកពាក់ ការគេង ការដើរ ការឈរ អង្គុយ ការធ្វើកាយវិការត្រាប់តាមកូនក្រមុំរៀបការ ការលេងធ្វើជាម្តាយបំពេរកូន។ល។ កុមារក៏បានធ្វើត្រាប់តាមសត្វដែរដូចជាៈ ធ្វើចលនាតាមសត្វហើរ (ត្រដាងដៃ) ស្រែកតាមសំឡេងសត្វ(កាបៗអ៊ូកៗម៉ៗ) ធ្វើដំណើរតាមសត្វទា គោ ធ្វើកាយវិការតាមសត្វ (ស្វា ក្រពើ) ព្រមទាំងត្រាប់តាមរុក្ខជាតិ/ ធម្មជាតិ (លើកដៃរេតាមខ្យល់បក់ ទឹករលក ទឹកឡើងទឹកស្រក)។

### ២.៤.៣.ការស្រាវជ្រាវ ការរុករក ការពិសោធ

កុមារតូចមានការឆ្ងល់ច្រើនក្នុងខួរក្បាលរបស់គេ ពោរពេញដោយចម្ងល់ ត្រូវការឱ្យមនុស្សជំជួយបង្ហាញពីហេតុផលជាក់ស្តែង។ មាតាបិតាគួរផ្តល់ឱកាស និងជួយកុមារឱ្យពិសោធ រុករក ស្រាវជ្រាវ ជារបៀបលេង ព្រោះកុមារចូលចិត្តនូវអ្វីដែលថ្មីៗ។ អ្នកមិនគួរខឹងនឹងកូនរបស់អ្នកនៅពេលដែលគេសួរអ្នកច្រើន ឬគេធ្វើឱ្យខូចរបស់ថ្មីដែលទើបនឹងទិញនោះឡើយ។ ឧទាហរណ៍ ប្រសិនបើអ្នកទិញកូនឡាន ឬតុក្កតាឱ្យកុមារលេង កាលណាឮសូរភ្លេង កុមារឆ្ងល់គេចាប់ផ្តើមស្រាវជ្រាវដោយដោះ ហែក កាត់មើល តើសំឡេងនៅត្រង់ណា? តើសំឡេងនោះចេញមកពីប្រភពណា? មូលហេតុអ្វីបានជាឮ? នេះជាការរៀន របស់កុមារតាមរយៈការពិសោធ ការរុករក ស្រាវជ្រាវ។

### ២.៤.៤.ការលេង

នៅតាមផ្ទះកុមារបានលេងល្បែងជាច្រើន ទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេ ល្បែងទាំងអស់នោះភាគច្រើនបានធ្វើឱ្យមានការអភិវឌ្ឍផ្នែកចលនា ការគិត ភាសានិយាយ បានជួយជំរុញកុមារឱ្យរាងកាយមានការលូតលាស់ និងពង្រឹងចំណេះដឹងថ្មីៗ កាន់តែប្រសើរឡើង។ កុមារធាប់មានមិត្តភក្តិណាស់ នៅពេលគេបានជួបគ្នា គេបង្កើតក្រុមដើម្បីលេងល្បែងផ្សេងៗ តាមចំណង់ចំណូលចិត្តរបស់ពួកគេ ដូច្នេះ សម្រាប់កុមារការលេង គឺជាការរៀនហើយការរៀនគឺជាការលេង។

### ២.៤.៥.ការអនុវត្តផ្ទាល់

ការរៀនដែលល្អ គឺការរៀនដែលមានការផ្សារភ្ជាប់ចំណេះដឹងទៅនឹងការអនុវត្តផ្ទាល់ ដូចនេះ មាតាបិតាត្រូវផ្តល់ឱកាសឱ្យកុមារបានអនុវត្តផ្ទាល់ដូចជា ដើម្បីបានដឹងរសជាតិ កុមារត្រូវភ្លក្សតាមរយៈជីវ្ហាវិញ្ញាណ ដឹងក្លិនត្រូវហិតក្លិនតាមរយៈឃានវិញ្ញាណ ដឹងរូបរាងគឺកុមារអាចប៉ះស្ទាបមើលតាមរយៈកាយវិញ្ញាណ នាំកុមារជិះកង់ យោលទោង លោត រត់ លើកជាសំណួរផ្សេងៗ ជំរុញកុមារឱ្យស្តាប់ គិត ឆ្ងល់ និយាយ និងផ្តល់ឱកាសឱ្យកុមារអនុវត្តដើម្បីឱ្យកុមារចេះសម្របសម្រួលផ្នែករាងកាយ ក្រោមការឃ្លាំមើល និងផ្តល់ការណែនាំជាប្រចាំពីមនុស្សធំ។

ការរៀនរបស់កុមារតូចបានចាប់ផ្តើមពីវ័យដំបូងរបស់កុមារ គឺជាពេលវេលាដែលមានសក្តានុពលយ៉ាងខ្លាំងសម្រាប់ការរៀនសូត្រ។ ខួរក្បាលរបស់កុមារតូចមានភាពសកម្ម មមាញឹក និងវិវឌ្ឍយ៉ាងឆាប់រហ័សជាងខួរក្បាលមនុស្សចាស់។ មាតាបិតា អ្នកអាណាព្យាបាល និងអ្នកគ្រប់គ្រងថែរក្សាទាំងអស់ ត្រូវតែដឹងថា ខួរក្បាលដ៏តូច របស់កុមារអាចរីកលូតលាស់បានល្អប្រសើរតាមរយៈ ការលើកទឹកចិត្ត ការហ្វឹកហាត់ និងការភ្ញោច ពីអ្នកដែលនៅជុំវិញ ហើយខួរក្បាលនេះនឹងទៅជាក្រិន គ្មានការលូតសាល់ ក៏ដោយសារតែការសំឡុតគម្រាម ការមិនផ្តល់ឱកាសឱ្យលេង ស្រាវជ្រាវ អនុវត្ត និងការប្រើអំពើហិង្សាតាមគ្រប់រូបភាព។ (នាយកដ្ឋាន

អប់រំកុមារតូច, ឯកសារស្តង់ដាកម្មវិធីគោលសម្រាប់បំប៉នដល់គ្រូមត្តេយ្យសិក្សាសហគមន៍, ឆ្នាំ២០១៤, ទំព័រ ១០-១១)

## ២.៥.គោលការណ៍សំខាន់ៗសម្រាប់អភិវឌ្ឍកម្មវិធីសិក្សា

កម្មវិធីសិក្សាល្អ ដែលអ្នកអភិវឌ្ឍកម្មវិធីសិក្សា ត្រូវចាំក្នុងចិត្តនូវគោលការណ៍សំខាន់ៗ ដូចខាងក្រោម ៖

- ជាកម្មវិធីដែលជំរុញឱ្យមានការរិះរក និងការបង្កើតថ្មី
- ជាកម្មវិធីដែលមានលក្ខណៈប្រជាធិបតេយ្យ និងផ្តោតទៅលើលំនាំនៃការរៀន
- ជាកម្មវិធីដែលចាត់ទុកបុគ្គលម្នាក់ៗ មានសមត្ថភាពផ្សេងៗគ្នា
- ជាកម្មវិធីដែលផ្តោតទៅលើបច្ចេកទេស និងការស្រាវជ្រាវបែបវិទ្យាសាស្ត្រ
- ជាកម្មវិធីដែលតម្រូវឱ្យមានការចងចាំតិច និងការរិះរកច្រើន
- ជាកម្មវិធីសិក្សាដែលតម្រូវឱ្យគ្រូដើរតួនាទីច្រើនមុខ
- ជាកម្មវិធីដែលផ្តោតទាំងទៅលើការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលម្នាក់ៗ និងរបស់ក្រុមទាំងមូល។

## ២.៦.ការរៀបចំកម្មវិធីសិក្សា

### ២.៦.១.ចំណុចសំខាន់ៗ ក្នុងការរៀបចំកម្មវិធីសិក្សា

បញ្ញត្តិនៃការអភិវឌ្ឍកម្មវិធីសិក្សា គឺជាការបង្កើតនូវមុខវិជ្ជាដែលត្រូវរៀន ឬជាការជ្រើសរើសខ្លឹមសារនៃមុខវិជ្ជា ឬជាការអនុម័តទម្រង់នៃសៀវភៅសិក្សា។ ក្នុងការអភិវឌ្ឍកម្មវិធីសិក្សា ចំណុចសំខាន់គឺការជ្រើសរើសមុខវិជ្ជា និងខ្លឹមសារនៃមុខវិជ្ជានីមួយៗ ដែលត្រូវរៀននៅតាមកម្រិតថ្នាក់។ ការអភិវឌ្ឍកម្មវិធីសិក្សាគឺជាកិច្ចការដ៏ស្មុគស្មាញមួយ ដែលទាមទារឱ្យមានការចូលរួមច្រើនក្នុងការសម្រេច។ ការសម្រេចនោះ គឺផ្អែកទៅលើគោលដៅរួមចំណែក ឯសាលាត្រូវធ្វើយ៉ាងណាឱ្យវត្ថុបំណងនៃការបង្រៀនសម្រេចបាននូវគោលដៅរួមទាំងនោះ។ បន្ទាប់មក គឺការសម្រេចជ្រើសរើសវិធីសាស្ត្របង្រៀនដើម្បីធ្វើយ៉ាងណាឱ្យអ្នករៀនអាចយល់ពីខ្លឹមសារមេរៀន និងអាចសម្រេចបាននូវវត្ថុបំណងនៃមេរៀន។ ការអភិវឌ្ឍកម្មវិធីសិក្សាត្រូវតែមានការពិនិត្យតាមដាន និងវាយតម្លៃ ពីអ្វីដែលអ្នកសិក្សាទទួលបាន និងពីប្រសិទ្ធភាពនៃកម្មវិធីសិក្សាក្នុងការសម្រេចឱ្យបាននូវវត្ថុបំណង និងគោលដៅកំណត់។ ការអភិវឌ្ឍកម្មវិធីសិក្សាត្រូវតែមានជំហានមួយច្បាស់លាស់។ ជំហាននៃការអភិវឌ្ឍកម្មវិធីសិក្សារួមមាន៖

- ការវិភាគពីតម្រូវការ
- ការបង្កើតនូវវត្ថុបំណង
- ការជ្រើសរើសមុខវិជ្ជាដែលត្រូវរៀន និងតម្រៀបវាទៅតាមកម្រិតថ្នាក់
- ការជ្រើសរើសបទពិសោធ ឬវិធីសាស្ត្រដែលត្រូវរៀននិងបង្រៀន និងតម្រៀបទៅតាមលំដាប់លំដោយ
- ការកំណត់ពីវិធីសាស្ត្រក្នុងការវាយតម្លៃ និងចំណុចដែលត្រូវវាយតម្លៃ

- **ការវិភាគពីតម្រូវការ៖** អ្នករៀន (មូលដ្ឋានគ្រឹះចំណេះដឹង ជំនាញ តម្រូវការទេពកោសល្យ ចិត្តចលករ បញ្ញា ទម្លាប់ សក្តានុពល)។ ហេតុអ្វីបានជាត្រូវវិភាគចំណុចទាំងអស់នេះ? ពីព្រោះថា ការអភិវឌ្ឍជាអតិបរមាដល់អ្នករៀន គឺជាចំណុចសំខាន់នៃការអប់រំ។ អ្នករៀនដែលទទួលបានការអប់រំពិតប្រាកដ លុះត្រាតែគាត់បានទទួលការរីកចម្រើនផ្នែកបញ្ញា និងសមត្ថភាពច្បាស់លាស់។ ការអភិវឌ្ឍសុខមាលភាពសង្គម វាអាស្រ័យទៅលើការអភិវឌ្ឍជាអតិបរមានូវសក្តានុពលរបស់បុគ្គលម្នាក់ៗ ដែលរស់នៅក្នុងសង្គមនោះ។ វាជាមូលដ្ឋានគ្រឹះសម្រាប់ជ្រើសរើស និងអភិវឌ្ឍបទពិសោធរៀនសូត្ររបស់អ្នករៀនក្នុងកម្មវិធីសិក្សារបស់សាលា។ កម្មវិធីសិក្សារបស់សាលា និងបទពិសោធរៀនសូត្ររបស់អ្នករៀននៅគ្រប់កម្រិតត្រូវតែសមស្របទៅនឹងវ័យ សមត្ថភាព និងលទ្ធភាពរបស់ពួកគេ។ ការវាយតម្លៃពីភាពលូតលាស់ការអភិវឌ្ឍ និងទំហំទទួលបាននូវគោលដៅនៃការអប់រំ ត្រូវតែគិតពីសមត្ថភាពលទ្ធភាពទេពកោសល្យ និងសក្តានុពលរបស់អ្នករៀន។
- **ការបង្កើតនូវវត្ថុបំណង៖** វត្ថុបំណងនៃការអប់រំមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ឧទាហរណ៍៖ **នៅប្រទេសជប៉ុន** ពីឆ្នាំ១៩៤៧-១៩៥៨ វត្ថុបំណងនៃការអប់រំរបស់ជប៉ុន គឺផ្តោតទៅលើគោលវិធីសិស្សមជ្ឈមណ្ឌល សង្កត់ធ្ងន់ទៅលើសកម្មភាពដោះស្រាយបញ្ហាដែលទាក់ទងទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ ជាពិសេសទៅលើបាតុភូតដែលគេបានសង្កេតឃើញ។ ពីឆ្នាំ១៩៥៨-១៩៦៩ វត្ថុបំណងនៃការអប់រំរបស់ជប៉ុន គឺផ្តោតទៅលើការយល់ស៊ីជម្រៅខ្លឹមសារវិទ្យាសាស្ត្រដែលគេតម្រៀបជាប្រព័ន្ធតាំងពីថ្នាក់បឋមរហូតដល់ថ្នាក់វិទ្យាល័យ។ ពីឆ្នាំ១៩៦៩-១៩៧៧ វត្ថុបំណងនៃការអប់រំរបស់ជប៉ុន គឺផ្តោតទៅលើការរិះរកដើម្បីបង្ខិតឱ្យជិតគ្នា រវាងការអប់រំនៅសាលា និងវិទ្យាសាស្ត្រទំនើប ជាពិសេសគឺផ្តល់មូលដ្ឋានគ្រឹះនៃបញ្ញត្តិវិទ្យាសាស្ត្រ។ ការអប់រំគឺផ្តោតទៅលើវិធីវិទ្យាសាស្ត្រតាមរយៈការសង្កេត និងការធ្វើពិសោធ។ ពីឆ្នាំ១៩៧៧-១៩៨៩ វត្ថុបំណងនៃការអប់រំរបស់ជប៉ុន គឺផ្តោតទៅលើការលើកកម្ពស់ភាពសប្បាយនៃការរៀនមុខវិជ្ជាវិទ្យាសាស្ត្រដោយសង្កត់ធ្ងន់ ទៅលើសកម្មភាពជាក់ស្តែង ការបង្កើតថ្មី និងការបណ្តុះគំនិតឱ្យមានការរិះរកជាក់ស្តែង។ ពីឆ្នាំ១៩៨៩-រហូតមកដល់បច្ចុប្បន្ននេះ វត្ថុបំណងនៃការអប់រំរបស់ជប៉ុន គឺផ្តោតទៅលើការកាត់បន្ថយ Stress របស់សិស្ស។ វត្ថុបំណងនៃការអប់រំរបស់ប្រទេស Indonesia, Fiji, Laos P.D.R, and Malaysia, គឺផ្តោតទៅលើការលើកកម្ពស់វប្បធម៌ សីលធម៌ និងគុណធម៌។ វត្ថុបំណងនៃការអប់រំរបស់ប្រទេស New Zealand និងសហរដ្ឋអាមេរិក គឺអប់រំមនុស្សឱ្យចូលរួមអភិវឌ្ឍសេដ្ឋកិច្ច ឱ្យមានការប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ និងលើកកម្ពស់សមិទ្ធផលសិក្សារបស់សិស្ស។ ដោយឡែកវត្ថុបំណងនៃការអប់រំនៅប្រទេស Australia និង Germany, គឺអប់រំមនុស្សឱ្យស្រឡាញ់សង្គម និងអត្តសញ្ញាណជាតិរបស់គេ ជាពិសេសគឺចេះថែរក្សាកេរដំណែលវប្បធម៌ជាតិ។ ចំពោះវត្ថុបំណងនៃការអប់រំនៅប្រទេស Singapore វិញគឺអប់រំមនុស្សឱ្យមានទំនុកចិត្តលើខ្លួនឯង ចេះបែងចែកអ្វីដែលត្រូវនិងអ្វីដែលខុស ឱ្យមានភាពវាងវៃ និងហ៊ានប្រថុយក្នុងការវិនិច្ឆ័យ ឱ្យស្គាល់ពីខ្លួនឯង ឱ្យចេះគិត ចេះវិភាគ និងចេះទំនាក់ទំនងប្រកបដោយភាពទទួលខុសត្រូវ ឱ្យចេះស្វ័យសិក្សាដោយខ្លួនឯង ឱ្យក្លាយទៅជាអ្នកចូលរួមយ៉ាងសកម្មក្នុងការធ្វើការងារជាក្រុម ឱ្យក្លាយទៅជាពលរដ្ឋមានប្រយោជន៍សម្រាប់ Singapore និងសម្រាប់អ្នកដែលរស់នៅជិត

ខាងខ្លួនក៏ដូចជាពិភពលោកទាំងមូល។ សម្រាប់ប្រទេសកម្ពុជាយើងវិញ វត្ថុបំណងនៃការអប់រំគឺមានដូចតទៅ៖ ពីឆ្នាំ១៩៩៦-២០០៤ គឺកសាងមនុស្សពេញលេញ រីកចម្រើនលូតលាស់គ្រប់ផ្នែកព្រមៗគ្នា ដោយមានតុល្យភាពរវាងប្រាជ្ញា ស្មារតី សញ្ចេតនា និងរូបកាយ។ ពោលជានាកសាងពលរដ្ឋថ្លៃថ្នូរ មាន ចំណេះដឹង បំណិន ពិសោធន៍ សីលធម៌ អធ្យាស្រ័យ សហការ សាមគ្គីភាព ឯកភាពជាតិ មនសិការជាតិ ស្រឡាញ់យុត្តិធម៌ គោរពច្បាប់ សិទ្ធិមនុស្ស យល់ដឹងថែរក្សាការពារបរិស្ថាន ចេះផ្សព្វផ្សាយ និងលើកកម្ពស់តម្លៃវប្បធម៌ អរិយធម៌ជាតិ មានម្ចាស់ការទំនុកចិត្តលើខ្លួនឯង ចេះដោះស្រាយបញ្ហាក្នុងជីវភាពរស់នៅ ចេះច្នៃប្រឌិត ចេះធ្វើពលិកម្ម មានស្មារតីទទួលខុសត្រូវខ្ពស់ មានសមត្ថភាពកសាងសុខមាលភាពគ្រួសារ ហើយអាចចូលរួមយ៉ាងសកម្មក្នុងការបង្រួបបង្រួមជាតិ ស្តារនិងអភិវឌ្ឍមាតុភូមិជាទីស្នេហា ដោយផ្អែកលើស្មារតីប្រជាធិបតេយ្យ សេរីពហុបក្ស។ ក្នុងន័យនេះការអប់រំនៅកម្ពុជា ត្រូវជានាបណ្តុះបណ្តាលពលករគ្រប់ជំនាញ កម្រិតបឋម មធ្យម និងឧត្តម ដើម្បីបំពេញតម្រូវការសង្គមជាតិហើយក៏ត្រូវជានាកសាងជួរបញ្ញវន្តជំនាញៗ ក្នុងការគ្រប់គ្រងដឹកនាំ ក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រសម្រាប់អភិវឌ្ឍ ព្រះរាជាណាចក្រកម្ពុជា ក្រោមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ។ ពីឆ្នាំ២០០៥-២០០៩ វត្ថុបំណងនៃការអប់រំគឺអភិវឌ្ឍកោសល្យ និងសមត្ថភាពរបស់សិស្ស ដើម្បីឱ្យគេក្លាយជាមនុស្សពេញលេញរីកចម្រើនលូតលាស់គ្រប់ផ្នែកព្រមៗគ្នា ដោយមានតុល្យភាពរវាងប្រាជ្ញា ស្មារតី សញ្ចេតនានិងរូបរាងកាយ។ **គោលដៅអប់រំជាតិ៖** គឺអភិវឌ្ឍប្រជាពលរដ្ឋឱ្យមានសមត្ថភាពផ្នែកបញ្ញា ស្មារតី ចិត្តគំនិត និងមានសុខភាពល្អ ដោយផ្តោតសំខាន់ទៅលើភាពថ្លៃថ្នូរមានជំនាញច្បាស់លាស់ មានបទពិសោធ មានសីលធម៌ល្អ មានស្មារតីចេះអត់ឱនឱ្យគ្នាទៅវិញទៅមក ចេះសហការគ្នា ចេះរួមរួមគ្នា មានមនសិការស្នេហាជាតិ មានភាពយុត្តិធម៌ ចេះគោរពច្បាប់ និងសិទ្ធិមនុស្ស។ លើសពីនេះទៅទៀត គោលដៅអប់រំជាតិ គឺមានបំណងអប់រំប្រជាពលរដ្ឋឱ្យចេះថែរក្សាបរិស្ថាន ចេះថែរក្សាវប្បធម៌អរិយធម៌ មានទំនុកចិត្តលើខ្លួនឯងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចេះដោះស្រាយបញ្ហារស់នៅប្រចាំថ្ងៃ មានគំនិតច្នៃប្រឌិត និងចូលរួមចំណែកក្នុងការស្តារ និងអភិវឌ្ឍប្រទេសជាតិ ផ្អែកលើលិទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ជាពិសេសគឺជានាការបណ្តុះបណ្តាលឱ្យមានគុណភាព និងជំនាញពិតប្រាកដចាប់តាំងពីបឋមសិក្សា។

**គោលដៅអប់រំនៅចំណោះទូទៅ៖** គឺអប់រំប្រជាពលរដ្ឋឱ្យក្លាយទៅជាមនុស្សមានលក្ខណៈពេញលេញជាប្រជាពលរដ្ឋដែលមានភាពថ្លៃថ្នូរ និងជាកម្លាំងពលកម្ម ប្រកបដោយសមត្ថភាពដូចខាងក្រោម៖

- មានសមត្ថភាពចំណេះដឹង និងជំនាញទូទៅ
- មានសមត្ថភាពលើកកម្ពស់សុខភាពផ្លូវកាយ ផ្លូវចិត្ត សម្រាប់ខ្លួនឯង និងក្រុមគ្រួសារ
- មានទំនុកចិត្តខ្លួនឯងក្នុងការដោះស្រាយបញ្ហាគ្រួសារ និងសង្គម
- មានសមត្ថភាពធ្វើផែនការ និងធ្វើការសម្រេចចិត្តដោយខ្លួនឯងសម្រាប់ភាពជោគជ័យក្នុងជីវិត
- មានស្មារតីអត់ឱន និងចេះគោរពផលប្រយោជន៍អ្នកដទៃ
- មានគំនិតសហគ្រិនភាព និងមានបំណងធ្វើការជាមួយគ្នានិងស្រឡាញ់បច្ចេកវិទ្យាទំនើប

– មានសមត្ថភាពសម្របខ្លួនទៅតាមតម្រូវការនិងការផ្លាស់ប្តូរនៃសង្គម។

ចំពោះគោលការណ៍កម្មវិធីសិក្សានៅកម្រិតភូមិសិក្សានីមួយៗ គឺមានដូចតទៅ៖

– ត្រូវមានទំនាក់ទំនងគ្នាពីកម្រិតថ្នាក់មួយទៅកម្រិតថ្នាក់មួយទៀត
– ត្រូវផ្តល់មូលដ្ឋានគ្រឹះឱ្យបានរឹងមាំ
– ត្រូវឱ្យមានការរៀនពេញមួយជីវិត
– ត្រូវមានការអភិវឌ្ឍសមត្ថភាព
– ត្រូវមានអត្ថប្រយោជន៍

ពីឆ្នាំ២០១៨តទៅ វត្ថុបំណង នៃការអប់រំរបស់យើង៖




## ២.៧.កម្មវិធីសិក្សាបណ្តាប្រទេសនានា

### ២.៧.១.កម្មវិធីសិក្សាសាលាមត្តេយ្យសិក្សាព្រះរាជាណាចក្រថៃ

Early Childhood Curriculum ប្រទេសថៃ ត្រូវបានរៀបចំឡើងនៅឆ្នាំ២០១៧។

- **ទស្សនវិជ្ជានៃការអប់រំកុមារតូច៖** ការរៀបចំកម្មវិធីសិក្សាអប់រំកុមារតូចសម្រាប់ការអភិវឌ្ឍកុមារតាំងពីចាប់កំណើតដល់អាយុ ៦ឆ្នាំ។ មូលដ្ឋានផ្អែកលើវិធីសាស្ត្រនៃការថែរក្សា និងការលើកកម្ពស់ដំណើរការរៀនសូត្ររបស់កុមារ ដែលឆ្លើយតបទៅនឹងធម្មជាតិផ្ទាល់របស់កុមារនីមួយៗ ការអភិវឌ្ឍ និងសក្តានុពល។ វិធីសាស្ត្រក៏បានសង្ខេបពីបរិបទនៃធម្មជាតិរបស់កុមារ។ អ្នកថែទាំ និងគ្រូមត្តេយ្យសិក្សា គួរតែប្រើប្រាស់នូវក្តីស្រឡាញ់ ការគិត និងយកចិត្តទុកដាក់ មូលដ្ឋានគ្រឹះកុមារតូចដើម្បីគុណភាពល្អនៃជីវិតផ្ទាល់ខ្លួន គ្រួសារ សហគមន៍ និងសង្គមជាតិ។
- **បេសកកម្ម៖** កម្មវិធីសិក្សាអប់រំកុមារតូចមានគោលបំណងអភិវឌ្ឍកុមារទាំងអស់លើផ្នែករាងកាយ អារម្មណ៍ សង្គម និងការគិត ប្រកបដោយគុណភាព និងបន្តទៅថ្នាក់លើ។ កុមារទាំងអស់ត្រូវបានផ្តល់ជាមួយភាពសប្បាយរីករាយ និងបទពិសោធនៃការរៀនសូត្រសមស្របតាមកម្រិតអាយុ មានបំណិនជីវិត និងអនុវត្តដោយអនុលោមតាមគោលការណ៍ទស្សនវិជ្ជាសេដ្ឋកិច្ច។

- **គោលការណ៍៖** ខាងក្រោមនេះគឺជាគោលការណ៍ទូទៅចំនួន ៥ នៃកម្មវិធីសិក្សាកុមារភាពដំបូង
    1. ជំរុញដំណើរការរៀន និងការអភិវឌ្ឍកុមារទាំងអស់
    2. ថែរក្សា និងអប់រំកុមារដោយយកចិត្តទុកដាក់លើរបៀបរស់នៅផ្សេងៗគ្នា និងលក្ខណៈបុគ្គលស្របតាមបរិបទសហគមន៍ សង្គម និងវប្បធម៌ថៃ
    3. ការប្រកាន់ខ្ជាប់នូវការអភិវឌ្ឍ និងការអភិវឌ្ឍគំនិតរបស់កុមារទាំងមូលតាមរយៈការលេងប្រកបដោយអត្ថន័យ និងមានសកម្មភាពផ្សេងៗ កុមារធ្វើសកម្មភាពក្នុងបរិស្ថានដើម្បីរៀនសមស្របនឹងអាយុរបស់ពួកគេ និងមានពេលសម្រាកគ្រប់គ្រាន់
    4. ផ្តល់បទពិសោធការសិក្សាសម្រាប់កុមារដើម្បីឱ្យពួកគេមានបំណិនជីវិត និងអាចយកទៅអនុវត្តដោយអនុលោមតាមទស្សនវិជ្ជាសេដ្ឋកិច្ច ធ្វើជាមនុស្សល្អដោយគោរពវិន័យ និងសុភមង្គល
    5. ច្នៃប្រឌិតចំណេះដឹង ការយល់ដឹង និងកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍកុមាររវាងស្ថាប័នអប់រំ និងឪពុកម្តាយ ក្រុមគ្រួសារ សហគមន៍ និងភាគីទាំងអស់ដែលចូលរួមក្នុងការអភិវឌ្ឍកុមារតូច។
- **កម្មវិធីសិក្សាសម្រាប់កុមារអាយុពី ៣ឆ្នាំ ទៅក្រោម ៦ឆ្នាំ**
- **គោលដៅ៖** កម្មវិធីសិក្សាសម្រាប់កុមារអាយុពី ៣ឆ្នាំ ទៅក្រោម ៦ឆ្នាំ មានគោលបំណងគាំទ្រការអភិវឌ្ឍរបស់កុមារសមស្របតាមកម្រិតអាយុពួកគេ សក្តានុពលបុគ្គល និងត្រៀមខ្លួនសម្រាប់ការរៀនសូត្រ។ គោលដៅសម្រាប់ការរៀនសូត្រ និងការអភិវឌ្ឍរួមមានដូចខាងក្រោម៖
    1. អភិវឌ្ឍរាងកាយឱ្យមានការលូតលាស់តាមស្តង់ដាអាយុកុមារនីមួយៗ តាមរយៈទម្លាប់ធ្វើឱ្យមានសុខភាពល្អ
    2. កុមារមានសុខភាពផ្លូវចិត្តគឺល្អ មានសោភណ្ឌ និងសីលធម៌
    3. កុមារមានបំណិនជីវិត និងអនុវត្តទស្សនវិជ្ជាសេដ្ឋកិច្ចគ្រប់គ្រាន់ដោយខ្លួនឯង វិន័យ និងតម្លៃសង្គមផ្សេងៗទៀត
    4. កុមារអភិវឌ្ឍជំនាញនៃការគិត ជំនាញទំនាក់ទំនង និងចំណេះដឹងដែលសមស្របនឹងកម្រិតអាយុពួកគេ។
- **ការអភិវឌ្ឍកុមារតូច**

    ១. ការអភិវឌ្ឍផ្នែករាងកាយ

    ២. ការអភិវឌ្ឍផ្នែកអារម្មណ៍

    ៣. ការអភិវឌ្ឍផ្នែកសង្គម

    ៤. ការអភិវឌ្ឍផ្នែកការយល់ដឹង
- **ចរិតលក្ខណៈស្តង់ដាសិក្សា**

១. ការអភិវឌ្ឍផ្នែករាងកាយ៖ មានចំនួន ២ស្តង់ដាគឺ

- ស្តង់ដាទី១៖ អភិវឌ្ឍរាងកាយឱ្យមានការលូតលាស់តាមស្តង់ដាអាយុកុមារនីមួយៗ តាមរយៈទម្លាប់ធ្វើឱ្យមានសុខភាពល្អ
- ស្តង់ដាទី២៖ អភិវឌ្ឍចលនាសាច់ដុំតូច និងសាច់ដុំធំ បានល្អ សម្របសម្រួល និងធ្វើឱ្យកម្លាំងកើនឡើង

២. ការអភិវឌ្ឍផ្នែកអារម្មណ៍៖ មានចំនួន៣ស្តង់ដាគឺ

- ស្តង់ដាទី៣៖ សុខភាពផ្លូវចិត្តល្អ និងកុមារមានភាពសប្បាយរីករាយ
- ស្តង់ដាទី៤៖ អារម្មណ៍ទាំងអស់ត្រូវបានសម្តែងចេញតាមរយៈ សិល្បៈ តន្ត្រី និងចលនា
- ស្តង់ដាទី៥៖ សីលធម៌ និងអារម្មណ៍ល្អត្រូវបានបង្ហាញ

៣. ការអភិវឌ្ឍផ្នែកសង្គម៖ មានចំនួន ៣ស្តង់ដាគឺ

- ស្តង់ដាទី៦៖ កុមារមានបំណិនជីវិត និងអនុវត្តទស្សនវិជ្ជាសេដ្ឋកិច្ចគ្រប់គ្រាន់
- ស្តង់ដាទី៧៖ ធម្មជាតិ បរិស្ថាន និងវប្បធម៌ត្រូវបានលើកតម្កើង និងមានមោទកភាព ដែលកើតជាជនជាតិថៃ
- ស្តង់ដាទី៨៖ កុមារទទួលបានភាពរីករាយជាមួយអ្នកដទៃ និងជាសមាជិកល្អនៃសង្គម ប្រជាធិបតេយ្យក្រោមរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ

៤. ការអភិវឌ្ឍផ្នែកការយល់ដឹង៖ មានចំនួន៤ស្តង់ដាគឺ

- ស្តង់ដាទី៩៖ ភាសាត្រូវបានប្រើដើម្បីប្រាស្រ័យទាក់ទងប្រកបដោយអត្ថន័យនៅក្នុង សមស្របតាមស្តង់ដារអាយុ
- ស្តង់ដាទី១០៖ កុមារអភិវឌ្ឍជំនាញនៃការគិតសម្រាប់ជាមូលដ្ឋានគ្រឹះនៃការរៀនសូត្រ
- ស្តង់ដាទី១១៖ ការស្រមើស្រមៃ និងការគិតបែបច្នៃប្រឌិតត្រូវបានបង្ហាញ
- ស្តង់ដាទី១២៖ អាកប្បកិរិយាវិជ្ជមានចំពោះការរៀនសូត្រត្រូវបានបង្ហាញហើយអាច ស្វែងរកចំណេះដឹងថ្មីៗ សមស្របតាមកម្រិតអាយុកុមារ។
- ស្តង់ដាទី១៖ អភិវឌ្ឍរាងកាយឱ្យមានការលូតលាស់តាមស្តង់ដាអាយុកុមារនីមួយៗ តាមរយៈទម្លាប់ធ្វើឱ្យមានសុខភាពល្អ

ស្តង់ដាទី១៖ អភិវឌ្ឍរាងកាយឱ្យមានការលូតលាស់តាមស្តង់ដាអាយុកុមារនីមួយៗ តាមរយៈទម្លាប់ធ្វើឱ្យមានសុខភាពល្អ

| សូចនាករ | លក្ខខណ្ឌគួរឱ្យចង់បាន | | |
|---|---|---|---|
| | ៣-៤ឆ្នាំ | ៤-៥ឆ្នាំ | ៥-៦ឆ្នាំ |
| 1.1 ទម្ងន់និងកម្ពស់យោងទៅតាមលក្ខណៈវិនិច្ឆ័យអាយុ | 1.1.1 ទម្ងន់ និងកម្ពស់យោងទៅតាមលក្ខណៈវិនិច្ឆ័យអាយុពីនាយកដ្ឋានសុខភាព | 1.1.1ទម្ងន់ និងកម្ពស់យោងទៅតាមលក្ខណៈវិនិច្ឆ័យអាយុពីនាយកដ្ឋានសុខភាព | 1.1.1ទម្ងន់ និងកម្ពស់យោងទៅតាមលក្ខណៈវិនិច្ឆ័យអាយុពីនាយកដ្ឋានសុខភាព |
| 1.2 មានសុខភាពល្អនិងទម្លាប់ល្អ | 1.2.1 ហូបអាហារដែលមានសុខភាពល្អ ផឹកទឹកស្អាត តាមការណែនាំ | 1.2.1 ហូបអាហារដែលមានសុខភាពល្អ ផឹកទឹកស្អាត ដោយខ្លួនឯង | 1.2.1 ហូបអាហារច្រើនមុខដែលមានសុខភាពល្អ ផឹកទឹកស្អាត ដោយខ្លួនឯង |
| | 1.2.2 លាងដៃមុនហូប និងបន្ទាប់ពីប្រើប្រាស់បង្គន់ តាមការណែនាំ | 1.2.2 លាងដៃមុនហូប និងបន្ទាប់ពីប្រើប្រាស់បង្គន់ ដោយខ្លួនឯង | 1.2.2 លាងដៃមុនហូប និងបន្ទាប់ពីប្រើប្រាស់បង្គន់ ដោយខ្លួនឯង |
| | 1.2.3 សម្រាក ឬគេងតាមកាលវិភាគ | 1.2.3 សម្រាក ឬគេងតាមកាលវិភាគ | 1.2.3 សម្រាក ឬគេងតាមកាលវិភាគ |
| | 1.2.4 អនុវត្តនិងធ្វើលំហាត់ប្រាណតាមកាលវិភាគ | 1.2.4 អនុវត្តនិងធ្វើលំហាត់ប្រាណតាមកាលវិភាគ | 1.2.4 អនុវត្តនិងធ្វើលំហាត់ប្រាណតាមកាលវិភាគ |
| 1.3 រក្សាខ្លួន និងសុវត្ថិភាពពីគ្រោះថ្នាក់ | 1.3.1 លេង និងធ្វើសកម្មភាពផ្សេងៗប្រកបដោយសុវត្ថិភាពតាមការណែនាំ | 1.3.1 លេង និងធ្វើសកម្មភាពផ្សេងៗប្រកបដោយសុវត្ថិភាពដោយខ្លួនឯង | 1.3.1 លេង និងធ្វើសកម្មភាពផ្សេងៗប្រកបដោយសុវត្ថិភាពដោយខ្លួនឯង |

| ស្តង់ដា | សូចនាករ | លក្ខខណ្ឌគួរឱ្យចង់បាន | | |
|---|---|---|---|---|
| | | ៣-៤ឆ្នាំ | ៤-៥ឆ្នាំ | ៥-៦ឆ្នាំ |
| ទី១ | ៣ | ៦ចំណុច | ៦ចំណុច | ៦ចំណុច |
| ទី២ | ២ | ៧ចំណុច | ៧ចំណុច | ៧ចំណុច |
| ទី៣ | ២ | ៣ចំណុច | ៣ចំណុច | ៣ចំណុច |
| ទី៤ | ១ | ៣ចំណុច | ៣ចំណុច | ៣ចំណុច |
| ទី៥ | ៤ | ៥ចំណុច | ៥ចំណុច | ៥ចំណុច |
| ទី៦ | ៣ | ៦ចំណុច | ៦ចំណុច | ៦ចំណុច |
| ទី៧ | ២ | ៥ចំណុច | ៥ចំណុច | ៥ចំណុច |
| ទី៨ | ៣ | ៦ចំណុច | ៦ចំណុច | ៦ចំណុច |
| ទី៩ | ២ | ៤ចំណុច | ៤ចំណុច | ៤ចំណុច |
| ទី១០ | ៣ | ៨ចំណុច | ៨ចំណុច | ៨ចំណុច |
| ទី១១ | ២ | ២ចំណុច | ២ចំណុច | ២ចំណុច |
| ទី១២ | ២ | ៤ចំណុច | ៤ចំណុច | ៤ចំណុច |
| ១២ | ២៩ | ៥៩ | ៥៩ | ៥៩ |

- **មាតិកាសម្រាប់ការសិក្សា**
  - សិក្សាពីខ្លួនឯង
  - មនុស្ស និងទីកន្លែងនានា ជុំវិញកុមារ
  - ធម្មជាតិ និងបរិស្ថាន
  - វត្ថុផ្សេងៗ ជុំវិញខ្លួនកុមារ
- **ការផ្តល់បទពិសោធ**
  - គោលការណ៍ក្នុងការផ្តល់បទពិសោធ
  - ការណែនាំក្នុងការផ្តល់បទពិសោធ
  - ការផ្តល់នូវសកម្មភាពប្រចាំថ្ងៃ
- **ដំណើរការការអភិវឌ្ឍរបស់កុមារ**
  - វាយតម្លៃសុក្រឹត ឬផែនការសម្រាប់វាយតម្លៃជាប្រព័ន្ធ
  - វាយតម្លៃផ្នែកទាំង៤នៃការអភិវឌ្ឍ
  - វាយតម្លៃកុមារម្នាក់ៗ ជាបន្តបន្ទាប់នៅពេញមួយឆ្នាំសិក្សា

- ប្រើអំណះអំណាងត្រឹមត្រូវ ខ្លឹមសារនៃការវាយតម្លៃត្រូវសមស្របនឹងបរិបទដែលកុមារមានទំនាក់ទំនងនឹងសកម្មភាពប្រចាំថ្ងៃដោយប្រើវិធីសាស្ត្រ និងឧបករណ៍សមស្រប ដោយមិនគួរប្រើក្រដាសតេស្ត ឬជាការសរសេរអក្សរបែបការប្រឡងឡើយ
- សង្ខេបព័ត៌មាននៃការវាយតម្លៃ និងប្រើប្រាស់លទ្ធផលនៃការវាយតម្លៃសម្រាប់ការអភិវឌ្ឍកុមារទៅថ្ងៃអនាគត

• **ការផ្សារភ្ជាប់រវាងការអប់រំនៅមត្តេយ្យសិក្សានិងថ្នាក់ទី១នៅបឋមសិក្សា**
  - អ្នកគ្រប់គ្រងរដ្ឋបាលអប់រំ
  - គ្រូមត្តេយ្យសិក្សា
  - គ្រូបឋមសិក្សា
  - មាតាបិតាកុមារ ឬអាណាព្យាបាលកុមារ

    (Thailand, 2017)

### ២.៧.២.កម្មវិធីសិក្សាសាលាមត្តេយ្យសិក្សាប្រទេសជប៉ុន

កម្មវិធីសិក្សាសាលាមត្តេយ្យសិក្សាប្រទេសជប៉ុន ត្រូវបានសេចក្តីប្រកាសព័ត៌មានលេខ ២៦ របស់ក្រសួងអប់រំ វប្បធម៌ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ កម្មវិធីសិក្សាសាលាមត្តេយ្យសិក្សា(តាមសេចក្តីប្រកាសលេខ ១៧៤ នៃក្រសួងអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ឆ្នាំ១៩៩៨) ដែលត្រូវបានធ្វើការកែប្រែពង្រឹងឡើងវិញនូវច្បាប់អប់រំសាលា ដោយអនុលោមទៅតាមមាត្រាលេខ ៣៨ (ក្រសួងអប់រំ វិទ្យាសាស្ត្រ និងបទបញ្ញត្តិវប្បធម៌ ចុះលេខ១១ ឆ្នាំ១៩៤៧) និងត្រូវបានដាក់ឱ្យប្រតិបត្តិច្បាប់ថ្មីនេះ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩។ កម្មវិធីសិក្សានេះ ត្រូវបានបែងចែកជា ៣ជំពូក គឺ៖

ជំពូកទី១ ការចាត់ចែងទូទៅ មាន៣ផ្នែកគឺ៖

- ផ្នែកទី១ ទស្សនៈគ្រឹះនៃការអប់រំសាលាមត្តេយ្យសិក្សា
- ផ្នែកទី២ ការរៀបចំកម្មវិធីសិក្សា
- ផ្នែកទី៣ សកម្មភាពអប់រំក្រៅកម្មវិធីសិក្សា

ជំពូកទី២ គោលដៅ និងខ្លឹមសារ មាន៖

- សុខភាព
- ការទំនាក់ទំនងរបស់មនុស្ស
- បរិយាកាស
- ភាសា
- ការសម្តែង

ជំពូកទី៣ ការពិចារណានៅក្នុងការរៀបចំវិធីសាស្ត្របង្រៀន និងសកម្មភាពអប់រំក្រៅកម្មវិធីសិក្សា៖

- ផ្នែកទី១ ការពិចារណានៅក្នុងការរៀបចំវិធីសាស្ត្របង្រៀន
- ផ្នែកទី២ សកម្មភាពអប់រំក្រៅកម្មវិធីសិក្សា

ក្នុងជំពូកទី១ ផ្នែកទី១«ទស្សនៈគ្រឹះនៃការអប់រំសាលាមត្តេយ្យសិក្សា» ការអប់រំចំពោះវ័យកុមារភាពគឺមានសារៈសំខាន់ក្រៃលែង ក្នុងការបណ្តុះគ្រឹះក្នុងអំឡុងពេលនៃការកសាងអត្តចរិតរបស់កុមារ

យូរអង្វែង និងជាទិសដៅមូលដ្ឋានរបស់ការអប់រំដល់កុមារវ័យក្មេង តាមរយៈបរិយាកាសរបស់ពួកគេផ្ទាល់ ដោយឱ្យកុមារចេះចាប់យកការពិចារណាអំពីតម្រូវការ ពិតដែលមាននៅក្នុងវ័យនេះ ដើម្បីឈានទៅសម្រេចគោលបំណងដូចមានចែងនៅក្នុងមាត្រា២២ នៃច្បាប់អប់រំសាលា។ នៅក្នុងទិសដៅនេះ គ្រូបង្រៀនត្រូវខិតខំប្រឹងប្រែងខ្នះខ្នែងបង្កើតភាពទុកចិត្តជាមួយកុមារ និងបង្កើតបរិយាកាសអប់រំឱ្យកាន់តែល្អប្រសើរថែមទៀត។ ចំណុចដែលត្រូវធ្វើការអប់រំកុមារតូចមាន៖

- លើកទឹកចិត្តកុមារឱ្យចេះធ្វើសកម្មភាពដោយស្ម័គ្រចិត្ត ចេះដឹកនាំជីវិតក្នុងវ័យរបស់ពួកគេដោយផ្អែកលើគំនិតចេះគិតគូរ ប្រើប្រាស់បទពិសោធដែលចាំបាច់ដល់ការ លូតលាស់របស់កុមារឆ្លងកាត់ការបង្ហាញសមត្ថភាពប្រកបដោយឥរិយាបថ និងអារម្មណ៍នឹងនរ
- ការសម្រេចនូវគោលបំណងប្រកបដោយជោគជ័យយ៉ាងទូលំទូលាយ តាមរយៈការបង្រៀនល្បែងផ្សេងៗ អត្ថន័យនៃល្បែងប្រកបដោយស្ម័គ្រចិត្តដែលបណ្តុះគ្រឹះ ដល់កុមារធ្វើឱ្យមានលំនឹងរវាងការលូតលាស់កម្លាំងកាយ និងបញ្ញា
- បំណងប្រាថ្នាដើម្បីអនុវត្តការងារនេះ ឆ្លើយតបទៅតាមបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗ សំអាងលើគំនិតលូតលាស់របស់កុមារភាព ដែលត្រូវបានទទួលជោគជ័យទៅតាមដំណើរការផ្សេងៗ នៃកម្លាំងរាងកាយនិងបញ្ញា បទពិសោធរបស់កុមារម្នាក់ៗ

ផ្នែកទី២ «ការរៀបចំកម្មវិធីសិក្សា» សាលាមត្តេយ្យសិក្សាទាំងឡាយ ត្រូវបង្កើតមូលដ្ឋានគ្រឹះសម្រាប់កុមារ ដោតផ្តោតទៅលើការសប្បាយរីករាយក្នុងការរស់នៅ ឈានទៅសម្រេចគោលបំណងនៃការអប់រំ ដែលមានចែងក្នុងមាត្រា២៣ នៃច្បាប់អប់រំសាលា។ កុមារសប្បាយរីករាយនឹងបទពិសោធរបស់សាលាមត្តេយ្យសិក្សាដែលបានកំណត់នៅក្នុង Basic Ideals of Kindergarten Education ក្នុងគម្រោងផ្នែកទី១ នៃជំពូកនេះ។ ការងារទាំងនេះត្រូវ សហការជាមួយនឹងឪពុកម្តាយរបស់កុមារផងដែរ។

- សាលាមត្តេយ្យនានា គួរតែបង្កើតគោលដៅ និងខ្លឹមសារជាក់លាក់ ដែលអនុវត្តកម្មវិធីសិក្សាតាមការពិសោធរបស់កុមារម្នាក់ៗ និងចំពោះការលូតលាស់របស់កុមារ។ សាលាមត្តេយ្យសិក្សាគួរមានវិធានការណ៍ឱ្យមានទស្សនៈវិស័យសម្រាប់រយៈពេលយូរអង្វែង។
- ចំនួនអប្បបរមានៃសប្តាហ៍ក្នុងមួយឆ្នាំៗ នៃការអប់រំសាលាមត្តេយ្យសិក្សាផ្អែកលើកម្មវិធីសិក្សាមានចំនួន ៣៩សប្តាហ៍ លើកលែងកាលៈទេសៈពិសេស។
- សាលាមត្តេយ្យសិក្សាមានស្តង់ដា ៤ម៉ោង ក្នុង១ថ្ងៃ។ ទោះបីយ៉ាងណា ក៏សាលាមត្តេយ្យសិក្សាទាំងឡាយគួរតែផ្តល់ឱ្យមានឱកាសផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងកម្រិតនៃការលូតលាស់កម្លាំងកាយ និងបញ្ញាតាមរដូវកាលនៃឆ្នាំ។

ផ្នែកទី៣ «សកម្មភាពអប់រំក្រៅកម្មវិធីសិក្សា» ជាតម្រូវការរបស់ឪពុកម្តាយ និងសហគមន៍ សាលាទាំងឡាយគួររៀបចំឱ្យមានសកម្មភាពអប់រំក្រៅកម្មវិធីសិក្សាទៀត សម្រាប់អ្នកចង់ចូលរួមដូចជា នៅក្នុងសេវាកម្មនានា ដោយអនុលោមទៅតាមមាត្រា២២ និង២៣ នៃច្បាប់អប់រំសាលា និងនៅក្នុងផ្នែកទី១ នៃជំពូកនេះ Basic Ideals of Kindergarten Education។ ដើម្បីសម្រេចបានតាមគោលដៅរបស់សាលាមត្តេយ្យសិក្សា សាលាគួរតែធ្វើការគាំទ្រការ អប់រំកុមារភាពតាមផ្ទះ និងតាមសហគមន៍។

ជំពូកទី២ គោលបំណង និងខ្លឹមសារ ពណ៌នាអំពីគោលដៅនៃការអប់រំសាលាមត្តេយ្យសិក្សា ដោយឈរលើមូលដ្ឋានអប់រំ ចិត្ត ឆន្ទៈ អាកប្បកិរិយា ។ល។ ខ្លឹមសារដែលត្រូវបញ្ជ្រាប ដល់ការលូតលាស់របស់កុមារតូចមាន៖

- សុខភាព គឺការបង្កើតសុខភាពរាងកាយ និងបញ្ញា ដោយលើកតម្កើងសមត្ថភាពកុមារឱ្យចេះថែរក្សាសុខភាព និងសុវត្ថិភាពដោយភាពម្ចាស់ការ
- ការទំនាក់ទំនងរបស់មនុស្ស គឺការបង្កើតសេចក្ដីសង្ឃឹមលើខ្លួនឯង និងលើកតម្កើងសមត្ថភាពទំនាក់ទំនងជាមួយអ្នកដទៃ ដើម្បីចូលរួម និងធ្វើការគាំទ្រគ្នាទៅវិញទៅមក
- បរិយាកាស គឺការលើកតម្កើងសមត្ថភាពកុមារទាក់ទងទៅនឹងបរិយាកាសជាមួយនឹងការចង់ដឹងចង់ឃើញ និងការពិនិត្យយ៉ាងម៉ឺងម៉ាត់ ផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ
- ភាសា
- ការសម្ដែង គឺការរីកចម្រើននូវមនោសញ្ចេតនាជាច្រើន និងសមត្ថភាព ដើម្បីធ្វើការបង្ហាញពីខ្លួនគេផ្ទាល់ និងការបញ្ចូលនូវគំនិតច្នៃប្រឌិតតាមការសម្ដែងចេញពីការពិសោធ ការគិតគូរ ដោយចេះប្រើពាក្យពេចន៍របស់ខ្លួនគេផ្ទាល់

ជំពូកទី៣ ផ្នែកទី១ ការពិចារណានៅក្នុងការរៀបចំវិធីសាស្ត្របង្រៀន គឺសាលាមត្តេយ្យសិក្សាគួរតែបង្កើតនូវតុល្យភាពរវាងប្រព័ន្ធតែមួយ និងផលប្រយោជន៍នៃផែនការបង្រៀន ហើយចែកចាយការអប់រំដែលអាចការប្រែប្រួលបានតាមតំបន់។ ចំណុចទូទៅសម្រាប់ការពិចារណាមាន ១)ផែនការបង្រៀនជាក់ស្ដែង ២)ផែនការបង្រៀនត្រូវមានគោលបំណង និងខ្លឹមសារជាក់ស្ដែងស្របនឹងបរិយាកាសសិក្សាសមរម្យ ៣)សកម្មភាពកុមារតូចគួរតែជាសកម្មភាពសមរម្យធ្វើឱ្យមានការលូតលាស់គ្រប់ដំណាក់ ៤)គ្រូបង្រៀនគួរតែលើកតម្កើងកុមារនៅក្នុងតុល្យភាពរវាងការលូតលាស់ផ្នែករាងកាយនិងបញ្ញា តាមរយៈការពិសោធជាច្រើន និងទំនាក់ទំនងយ៉ាងទូលំទូលាយ ៥)វិធីបង្រៀនគួរតែអនុវត្តតាមការបង្កើតផែនការបង្រៀនប្រចាំឆ្នាំ ខែ សប្ដាហ៍ និងប្រចាំថ្ងៃ ៦)សកម្មភាពកុមារគួរតែមានសកម្មភាពជាបុគ្គល ក្រុមតូច និងក្រុមធំ ៧)ជំរុញសកម្មភាពស្ម័គ្រចិត្តរបស់កុមារតាមវិធីផ្សេងៗ ៨)ពង្រីកទំនាក់ទំនងជាមួយ គ្រួសារ សហគមន៍ តាមរយៈកិច្ចសហការ ៩)បង្ហាញភាពពិតពីការអប់រំនៅសាលាដល់គ្រួសារកុមារ។ ក្នុងផ្នែកទី២ សកម្មភាពអប់រំក្រៅកម្មវិធីសិក្សា គឺថ្លែងពីតម្រូវការទាំងឡាយរបស់ឪពុកម្ដាយ និងសហគមន៍ សកម្មភាពអប់រំបានផ្ដល់ឱ្យនៅក្នុងម៉ោង ក្រៅកម្មវិធីសិក្សា ចំពោះ អ្នកដែលចង់ចូលរួមតាមកម្រិតប្រាជ្ញា និងថាមពលរបស់កុមារ។ (ក្រសួងអប់រំវប្បធម៌កីឡាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា, ២០០៨)

## ២.៨.ការអភិវឌ្ឍរបស់កុមារតូច

កុមារតូចដែលចាប់ពីកកំណើតរហូតដល់អាយុក្រោម ៦ឆ្នាំ តែងមានការអភិវឌ្ឍលើផ្នែករាងកាយ ស្មារតី ដែលជាតម្រូវការចាំបាច់សម្រាប់កុមារ។ ផ្នែកទាំងនេះតែងលូតលាស់ទន្ទឹមគ្នា ហើយជះឥទ្ធិពលឱ្យគ្នាទៅវិញទៅមក។ កុមារមានការអភិវឌ្ឍឆាប់រហ័សផ្នែកខួរក្បាលនៅឆ្នាំដំបូងនៃជីវិតរបស់គេ។ បទពិសោធជាច្រើនបានបង្ហាញថា ជីវិតដំបូងរបស់កុមារត្រូវផ្ដោតលើការថែទាំការជួយទំនុកបម្រុងពីក្រុមគ្រួសារ និងសង្គមឱ្យទទួលបាននូវសេវានានា ដូចជា អាហារូបត្ថម្ភ ការថែទាំសុខភាព ការផ្ដល់ឱកាសរៀនសូត្រ ការការពារពីគ្រោះថ្នាក់ផ្សេងៗ។ (ក្រសួងអប់រំយុវជននិងកីឡា, គោលនយោបាយជាតិស្ដីពីការគាំពារនិងអភិវឌ្ឍកុមារតូច, ២០១០)ក្នុងការអភិវឌ្ឍកុមារ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ការអភិវឌ្ឍកុមារមាន៥ផ្នែក គឺ អភិវឌ្ឍន៍រាងកាយ និងសុខភាព ភាសា បញ្ញានិងការគិត សង្គមនិងអារម្មណ៍ និងអភិវឌ្ឍន៍សីលធម៌និងវប្បធម៌។ (នាយកដ្ឋានអប់រំកុមារតូច, ស្តង់ដាសិក្សាសម្រាប់កុមារអាយុ៥ឆ្នាំ, ២០១៧) ក្នុងការអភិវឌ្ឍកុមារ

នេះ យើងផ្តោតតែលើកុមារអាយុ៥ឆ្នាំ ដែលជាចំណុចដៅនៅក្នុងការសិក្សាស្រាវជ្រាវនេះ ហេតុនេះ យើងសូមលើកយកការអភិវឌ្ឍផ្នែកទាំង៥នេះមកសិក្សា។

យោងតាមស្តង់ដារសិក្សាកុមារអាយុ៥ឆ្នាំ ដែលក្រសួងអប់រំ យុវជន និងកីឡា បានចុះធ្វើតេស្តស្តង់ដា ដើម្បីកំណត់ការអភិវឌ្ឍផ្នែកទាំង៥ របស់កុមារតាមកម្រិតអាយុ បានបង្ហាញថាកុមារអាយុ៥ឆ្នាំ មានការអភិវឌ្ឍ ៥ផ្នែក ដូចខាងក្រោម៖

### ២.៨.១.ការអភិវឌ្ឍផ្នែករូបរាងកាយ និងសុខភាព

ការអភិវឌ្ឍផ្នែករាងកាយ កុមារអាយុ៥ឆ្នាំ មានការគ្រប់គ្រងផ្នែករាងកាយដ៏ល្អ ពេលនេះកុមារអាចប្រើបានទាំងចលនាតូច និងចលនាធំ។ ចលនាតូច កុមារអាចប្រើប្រាស់កន្ត្រៃកាត់អ្វីៗ តាមតម្រូវការ។ គេអាចប្រើម្រាមដៃ ចង្អុល ដៃ ជើង ឆ្វេង ស្តាំ មុខ ក្រោយ លើ ក្រោម ។ រីឯចលនាធំ កុមារអាចដើរ រត់ លោតលូន ឡើងបានយ៉ាងស្ទាត់ជំនាញ និងអាចដើរថយក្រោយ លោតផ្លោះ លោតអន្ទាក់ យោលទោង បង្វិលខ្លួន និងចេះសម្របសម្រួលផ្នែករាងកាយបានយ៉ាងល្អ ដូចជា ជិះកង់ ហែលទឹក ជាដើម។ នៅក្នុងអាយុនេះផងដែរ កុមារមានបំណិនផ្ទាល់ខ្លួនរបស់គេ ដូចជា អាចស្លៀកពាក់ដោយខ្លួនឯង ចេះសិតសក់ ញ៉ាំអាហារដោយខ្លួនឯង អាចប្រើប្រាស់បន្ទប់ទឹកដោយខ្លួនឯង។ (ក្រសួងអប់រំយុវជននិងកីឡា, កម្មវិធីសិក្សាកុមារអាយុ៥ឆ្នាំ, ឆ្នាំ២០០៧)

### ២.៨.២.ការអភិវឌ្ឍផ្នែកសីលធម៌ និងវប្បធម៌

#### ២.៨.២.១.ការអភិវឌ្ឍផ្នែកសីលធម៌

កុមារអាចយល់ដឹងពីតម្លៃរបស់មនុស្ស គឺកុមារបង្ហាញការយល់ដឹងពីតម្លៃរបស់មនុស្ស ព្រមទាំងគោរព និងឱ្យតម្លៃលើភាពផ្សេងគ្នា និងភាពដូចគ្នារបស់មនុស្ស ដោយមានការទទួលស្គាល់នូវលទ្ធភាពផ្ទាល់ខ្លួន និងលទ្ធភាពរបស់អ្នកដទៃ ដោយនិយាយសាកសួរ មិនចំអក និងកុមារអាចប្រាប់ពីរបៀបគោរពមនុស្សចាស់ដូចជា សំពះ ដើរឱនចំពោះមនុស្សចាស់ ចេះឆ្លើយ បាទ ចាស អរគុណ សុំទោស ជម្រាបសួរ ជម្រាបលា សួស្តី។ (ក្រសួងអប់រំយុវជននិងកីឡា, កម្មវិធីសិក្សាកុមារអាយុ៥ឆ្នាំ, ឆ្នាំ២០០៧)

#### ២.៨.២.២.ការអភិវឌ្ឍផ្នែកវប្បធម៌

កុមារអាចចូលរួមលើកតម្កើងវប្បធម៌របស់ខ្មែរ ដោយប្រាប់ឈ្មោះរបស់របរជារបស់ខ្មែរ ដូចជា សម្លៀកបំពាក់ប្រពៃណី មានសំពត់ហូល ផាមួង សារុង ក្រមា... និងអាចប្រាប់ឈ្មោះពិធីបុណ្យជាតិផ្សេងៗ ដូចជា បុណ្យចូលឆ្នាំ ភ្ជុំបិណ្ឌ ពិធីរៀបអាពាហ៍ពិពាហ៍ និងប្រាប់ឈ្មោះទីកន្លែងសំខាន់ៗ ដែលជារមណីយ៍ដ្ឋានល្បីៗ របស់ប្រទេស ហើយកុមារក៏ចេះច្រៀងបទគោរពទង់ជាតិបានទៀតផង។ (ក្រសួងអប់រំយុវជននិងកីឡា, កម្មវិធីសិក្សាកុមារអាយុ៥ឆ្នាំ, ឆ្នាំ២០០៧)

### ២.៨.៣.ការអភិវឌ្ឍផ្នែកសង្គម និងអារម្មណ៍

#### ២.៨.៣.១.ការអភិវឌ្ឍផ្នែកសង្គម

កុមារក្នុងវ័យនេះ អាចបង្ហាញជំនាញបំណិនរស់នៅក្នុងសង្គម និងមានទំនាក់ទំនងវិជ្ជមានជាមួយមនុស្សធំបានដូចជា កុមារអាចធ្វើទំនាក់ទំនងដោយគោរពមនុស្សពេញវ័យដែលខ្លួនស្គាល់នៅក្នុងសហគមន៍ និងប្រាប់ឈ្មោះមនុស្សពេញវ័យដែលខ្លួនអាចសុំឱ្យគេជួយ កុមារអាចបង្ហាញបំណិនរស់នៅក្នុងសង្គម និងទំនាក់ទំនងវិជ្ជមានជាមួយមិត្តភក្តិក្នុងវ័យប្រហាក់ប្រហែលគ្នាដូចជា ធ្វើទំនាក់ទំនងដោយមិនបំពានទៅលើមិត្តភក្តិ ជួយដោះស្រាយបញ្ហារបស់មិត្តភក្តិ ផ្តល់និងស្តាប់យោបល់មិត្តភក្តិ។ កុមារក៏អាចបង្ហាញការយល់ដឹងអំពីទង្វើ និងលទ្ធផលដោយអាចពន្យល់បានពីអំពើរបស់ខ្លួនដែលធ្វើឱ្យអ្នកដទៃមានអារម្មណ៍បែបណា កុមារក្នុងវ័យនេះអាចបង្ហាញការពេញចិត្ត និងភាពផ្សេងៗគ្នា ដូចជា លេងជាមួយកុមារដទៃដោយមិនរើសអើង

ហើយគេក៏អាចបង្ហាញភាពយុត្តិធម៌នៅក្នុងក្រុម និងទទួលស្គាល់សមត្ថភាពមិត្តភក្តិនៅក្នុងក្រុម។ (ក្រសួងអប់រំយុវជននិងកីឡា, កម្មវិធីសិក្សាកុមារអាយុ៥ឆ្នាំ, ឆ្នាំ២០០៧)

### ២.៨.៣.២.ការអភិវឌ្ឍផ្នែកអារម្មណ៍

ទាក់ទងនឹងការអភិវឌ្ឍផ្នែកអារម្មណ៍ កុមារបង្ហាញចេញពីការយល់ដឹងពីខ្លួនឯង ដូចជាកុមារអាចបង្ហាញ ឬសម្តែងនូវអារម្មណ៍តាមរយៈទឹកមុខជាមួយនឹងពាក្យ ដោយប្រាប់ពីអ្វីដែលខ្លួនរីករាយ ខឹង និងកើតទុក្ខ។ ជាមួយគ្នានេះ កុមារអាចសម្រួលអារម្មណ៍ និងសង្កត់ចិត្តរបស់ខ្លួនដោយគ្រប់គ្រងអារម្មណ៍អត់ធ្មត់ មិនងាយខឹង និងអាចទទួលយកភាពជោគជ័យ និងបរាជ័យដែលខ្លួនបានធ្វើ។ កុមារក៏អាចសម្តែងអារម្មណ៍តាមស្ថានភាពគឺសម្តែងអារម្មណ៍ផ្ទាល់ខ្លួនដូចជា ខឹង ស្រឡាញ់ ស្អប់តាមរយៈកាយវិការ ទឹកមុខ ពាក្យសំដី និងការលេង។ (ក្រសួងអប់រំយុវជននិងកីឡា, កម្មវិធីសិក្សាកុមារអាយុ៥ឆ្នាំ, ឆ្នាំ២០០៧)

### ២.៨.៤.ការអភិវឌ្ឍផ្នែកការយល់ដឹង និងការពិចារណា

វ័យសំខាន់បំផុតសម្រាប់ការរស់រាន ការលូតលាស់ និងការអភិវឌ្ឍរបស់កុមារតូច មានតាំងពីមុនពេលកើតរហូតដល់ពេលបញ្ជូនទៅសាលារៀន ពោលគឺក្នុងអំឡុងវ័យពី ៣ទៅ ៤ឆ្នាំដំបូង កុមារមានការរីកចម្រើនខ្លាំងបំផុតនៃជីវិតរបស់ពួកគេ គឺជាពេលវេលាដែលខួរក្បាលមានការរីកលូតលាស់ និងសម្របទៅតាមបរិស្ថានជុំវិញយ៉ាងឆាប់រហ័ស។ បន្ទាប់ពីកុមារអាយុ ៣ឆ្នាំ កុមារចាប់ផ្តើមរៀនសូត្រយ៉ាងច្រើន។ កុមារមានការរីកលូតលាស់ផ្នែករាងកាយទន្ទឹមគ្នានឹងការរីកលូតលាស់ផ្នែកបញ្ញាស្មារតីដែរ។ ក្នុងនោះការលូតលាស់ផ្នែកខួរក្បាលគួរឱ្យចាប់អារម្មណ៍។ ឥទ្ធិពលនៃបរិស្ថានជុំវិញចំពោះជីវិតដំបូង ការអភិវឌ្ឍខួរក្បាលមានរយៈពេលយូរអង្វែង។ បរិស្ថានជុំវិញមិនត្រឹមតែមានឥទ្ធិពលលើចំនួនកោសិកាខួរក្បាល និងចំនួនតភ្ជាប់នៃកោសិកាខួរក្បាលប៉ុណ្ណោះទេ ថែមទាំងមានឥទ្ធិពលលើរបៀបនៃដំណើរការខួរក្បាល និងជាអ្នកធ្វើឱ្យកុមារមានទំនាក់ទំនងជាមួយអ្នកដទៃទៀតផង។ ខួរក្បាលប្រើបទពិសោធដែលបានមកពីពិភពខាងក្រៅដើម្បីជុសខាត់របៀបនៃដំណើរការរបស់ខួរក្បាល។ (ក្រសួងអប់រំយុវជននិងកីឡានិងអង្គការunicef, ២០១០, pp. 14-15)

ដោយសារកុមារមានការអភិវឌ្ឍឆាប់រហ័សនៅក្នុងវ័យដំបូងនេះហើយ ទើបក្រសួងអប់រំ យុវជន និងកីឡា(នា.អកត) បានរៀបចំស្តង់ដាសិក្សាកុមារអាយុ ៣ឆ្នាំ ៤ឆ្នាំ និង៥ឆ្នាំឡើង ដើម្បីវាស់វែងសមត្ថភាពកុមារ។ ខាងក្រោមនេះជាការអភិវឌ្ឍផ្នែកបញ្ញា ការគិត ដែលបានកំណត់ក្នុងស្តង់ដាសិក្សាកុមារអាយុ៥ឆ្នាំ។

កុមារអាយុ៥ឆ្នាំ អាចបង្ហាញពីការយល់ដឹងហេតុ និងផល ដោយគេអាចប៉ាន់ស្មាន និងទាយទុកនូវអ្វីដែលជាចុងបញ្ចប់នៃសាច់រឿង និងទស្សន៍ទាយទុកនូវបាតុភូតនានា ដូចជា អាចនឹងមានភ្លៀងពេលគេឮផ្គរលាន់ និងគេអាចបញ្ជាក់ពីសកម្មភាពដែលអាចជះឥទ្ធិពលលើវត្ថុនានា ឧទាហរណ៍៖ នៅពេលទាត់បាល់បាល់នឹងរមៀល។ កុមារក៏អាចបង្ហាញពីការគិត ដោះស្រាយបញ្ហាដូចជា៖ បើគ្មានកន្ត្រៃកាត់ក្រដាស គេអាចបត់ក្រដាសរួចហែកតាមស្នាមបត់ ជាមួយគ្នានេះដែរកុមារអាចបង្ហាញពីគោលវិធីវិជ្ជមាន និងជាចំហ ដើម្បីដោះស្រាយបញ្ហា ឬគេអាចធ្វើការជាក្រុមជាមួយមិត្តភក្តិដើម្បីដោះស្រាយបញ្ហា។ បន្ថែមលើនេះ កុមារអាយុ៥ឆ្នាំ អាចបង្ហាញពីនិមិត្តសញ្ញានានាដែលតំណាងគ្រោះថ្នាក់ ដូចជា សញ្ញាក្បាលខ្មោច សញ្ញាគ្រាប់មីន សញ្ញាហាមដក់បារី ជាដើម។ (ក្រសួងអប់រំយុវជននិងកីឡា, កម្មវិធីសិក្សាកុមារអាយុ៥ឆ្នាំ, ឆ្នាំ២០០៧) ក្រៅពីអភិវឌ្ឍន៍ការគិតពិចារណាខាងលើ កុមារអាយុ៥ឆ្នាំ ស្គាល់ និងយល់លេខ តារាង ស្គាល់ចំនួន ធ្វើលេខសាមញ្ញៗ អាចដាក់បន្ថែមនូវវត្ថុរូបីដើម្បីតាង និងរាប់ចំនួនសរុប និងអាចដកវត្ថុរូបីចេញពីក្រុមមួយ និងរាប់ចំនួនវត្ថុដែលនៅសល់។ កុមារក៏អាចស្គាល់បញ្ញត្តិរង្វាស់ដោយគេចេះធ្វើការប្រៀបធៀបខ្ពស់ ទាប វែង ខ្លី តូច ធំ ធ្ងន់ ស្រាល។ គេអាចយល់ពីបញ្ញត្តិនៃការវាស់វែងដោយប្រើខ្សែ ឬម្រាមដៃ ស្គាល់ពីទិសនៃលំហ ប្រាប់

ឈ្មោះរាងធរណីមាត្រសាមញ្ញៗ ដូចជា រាងការេ ត្រីកោណ ចតុកោណកែង គេអាចរៀបផ្គុំវត្ថុនានា ដើម្បីបង្កើតជារូបរាងផ្សេងៗ ដូចជា រូបមនុស្ស សត្វ... និងអាចកំណត់ទីតាំងវត្ថុមួយធៀបនឹងផ្ទះដោយប្រើពាក្យខាងលើ ខាងក្រោម ពីមុខ ពីក្រោយ ខាងក្នុង ខាងក្រៅ ខាងឆ្វេង ខាងស្តាំ។ ការយល់ដឹងរបស់កុមារលើផ្នែកវិទ្យាសាស្ត្រ គេអាចសង្កេត និងស្វែងយល់ ដោយធ្វើការពិសោធ និងស្វែងយល់ដោយប្រើសម្ភារៈផ្សេងៗ ក្នុងការលេងដូចជា ទឹក ខ្សាច់ ថ្នាំពណ៌ ស្រូវ អង្ករ ជាដើម។ កុមារអាចប្រាប់ឈ្មោះបន្លែ ផ្លែឈើ ក្លិន រសជាតិ រូបរាងកាយ តាមរយៈការហិត ការភ្លក្ស ប្រាប់ ស្ទាប សង្កេត មើល។ កុមារអាចរៀបរាប់ពីលក្ខណៈនៃវត្ថុមានជីវិត និងគ្មានជីវិតដោយប្រៀបធៀបលក្ខណៈដូចគ្នា និងខុសគ្នានៃមនុស្ស សត្វ រុក្ខជាតិ។ ចំពោះការយល់ដឹងផ្នែកសង្គម កុមារក្នុងវ័យនេះ អាចបែងចែកភាពខុសគ្នារវាងព្រឹត្តិការណ៍ដែលកើតឡើងនៅអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ដូចជា កុមារអាចរៀបរូបភាពតាមលំដាប់លំដោយនៃពេលវេលា។ ក្នុងនោះផងដែរ គេក៏អាចប្រាប់ឈ្មោះថ្ងៃនៃសប្តាហ៍តាមលំដាប់លំដោយ អាចកំណត់ពេលវេលា ដូចជា ម្សិលមិញ ថ្ងៃនេះ និងថ្ងៃស្អែក កុមារអាចប្រាប់ពីកិច្ចការដែលគេបានធ្វើ អ្វីដែលគេមិនបានធ្វើ និងអ្វីដែលគេនឹងត្រូវធ្វើ។ កុមារអាចយល់ដឹងពីបរិស្ថានធម្មជាតិ គ្រោះធម្មជាតិនិងវិធីការពារផងដែរ។ គេក៏ស្គាល់ពីប្រភេទក្រដាសប្រាក់រៀលរបស់ខ្មែរ ស្គាល់ពីមុខរបររបស់ឪពុកម្តាយ ក្រុមគ្រួសារ អាចប្រាប់បានពីទីកន្លែងសំខាន់ៗនៅក្នុងភូមិដូចជាសាលារៀន មន្ទីរពេទ្យ វត្តអារាម ផ្សារ...។ ចំពោះផ្នែកសិល្បៈច្នៃប្រឌិត គឺគេផ្តោតសំខាន់លើសកម្មភាពកសាង គំនូរ ចម្រៀង តន្ត្រី។ គេអាចបង្កើតរូបភាពផ្សេងៗ តាមរយៈការគូររូប ការផាត់ពណ៌ ការកាត់ ការហែក និងការបិទដើម្បីបង្ហាញព្រឹត្តិការណ៍នានា និងអារម្មណ៍ និងអាចពន្យល់ពីអ្វីដែលគេបានបង្កើត។ កុមារអាយុ៥ឆ្នាំក៏អាចសម្តែងចលនាច្នៃប្រឌិត និងពិសោធន៍ ផ្នែករបាំដោយរាំជាចង្វាក់ប្រពៃណី។ (ក្រសួងអប់រំយុវជននិងកីឡា, កម្មវិធីសិក្សាកុមារអាយុ៥ឆ្នាំ, ឆ្នាំ២០០៧)

ស្របនឹងការអភិវឌ្ឍផ្នែកបញ្ញា ស្មារតី នេះដែរ គរុវិទូអាល្លឺម៉ង់ Friedrich Froebel (1782-1852) បានត្រួសត្រាយក្នុងការអភិវឌ្ឍសាលាមត្តេយ្យ លោកជឿជាក់ថា អត្តខាងក្នុងរបស់កុមារគ្រប់រូបមានផ្ទុកទៅដោយខ្លឹមសារខាងស្មារតី ដែលភ្ញោចដល់ការសិក្សាសកម្មដោយខ្លួនឯង។ ដូច្នេះហើយ ទើបគាត់បានរៀបចំសាលាមត្តេយ្យដែលជាបរិស្ថាន បានត្រៀមរៀបចំរួចជាស្រេច ដើម្បីពង្រីកស្មារតីខាងក្នុងរបស់កុមារតាមរយៈស្វ័យសកម្មភាព។ កម្មវិធីសិក្សាក៏រាប់បញ្ចូលផងដែរនូវកម្មវត្ថុ ដែលទាក់ទងនឹងនិស្ស័យជាមួយទម្រង់អចលនៈ ដូចជា ដុំមូល គូប ស៊ីឡាំង ដែលមានបំណងនាំទៅដល់ញាណដ៏ពេញលេញ ដែលបញ្ញត្តិមូលដ្ឋានតំណាងដោយវត្ថុ។ ជាមួយគ្នានេះដែរ Froebel ក៏បានបញ្ជាក់ពីបុគ្គលិកលក្ខណៈគ្រូបង្រៀន នៅមត្តេយ្យសិក្សាថាមានសារៈសំខាន់បំផុត។ គ្រូមត្តេយ្យគួរតែគោរពសេចក្តីថ្លៃថ្នូរនៃបុគ្គលិកលក្ខណៈមនុស្ស និងធ្វើបដិរូបកម្ម តម្លៃវប្បធម៌ខ្ពង់ខ្ពស់បំផុត ដើម្បីឱ្យកុមារអាចគ្រាប់តាមតម្លៃទាំងនោះ។ ជាពិសេសគ្រូមត្តេយ្យគួរតែមានភាពរួសរាយ មានទំនាក់ទំនងល្អ និងស្មោះត្រង់(So Suthy (M.ed) p.៩៥)។ លោក Froebel ក៏បានបែងចែកផងដែរ ពីកម្មវិធីសិក្សានៅសាលាមត្តេយ្យថា កម្មវិធីសិក្សាត្រូវទាក់ទងនឹងការងារហត្ថកម្ម ទាក់ទងនឹងសាសនា និងការបង្រៀនអំពីសាសនាទាក់ទងនឹងវិទ្យាសាស្ត្រធម្មជាតិ និងគណិតវិទ្យា ភាសាទាក់ទងនឹងសិល្បៈ(គួយ សូគាន p.៥៦)។

ក្នុងន័យនេះ ឃើញថាកុមារតូចផ្ចិតយកការសិក្សាបានឆាប់រហ័សណាស់ ដោយសារការអភិវឌ្ឍខួរក្បាល។ ប៉ុន្តែក៏មានផលប៉ះពាល់ជាអវិជ្ជមានផងដែរ ក្នុងករណីដែលកុមារជួបប្រទះនឹងភាពតានតឹងផ្លូវចិត្ត។ ហេតុនេះកុមារត្រូវមានទំនាក់ទំនងជាវិជ្ជមានជាមួយពិភពខាងក្រៅ គឺសាលារៀននេះហើយ។ ម្យ៉ាងទៀត កុមារតូចក្នុងអំឡុងអាយុក្រោម ៦ឆ្នាំ គេមិនអាចបង្ខំឱ្យធ្វើកិច្ចការហួសសមត្ថភាពរបស់គេទេ គឺធ្វើឱ្យគេតានតឹងផ្លូវចិត្ត និងមិនចង់ទៅសាលារៀន។ ដូចនេះ សាលាមត្តេយ្យត្រូវតែជាទីមេត្រីនិងមានកម្មវិធីសិក្សា

សមស្របនឹងកម្រិតអាយុរបស់គេ ដែលមានស្តង់ដាសិក្សាជាខ្នាតសម្រាប់វាស់វែង និងតម្រូវតាមចំណង់ចំណូលចិត្តរបស់កុមារ ព្រមទាំងស្របនឹងបរិស្ថាននៃការរស់នៅផងដែរ។

តាមទស្សនៈនេះឃើញថា កុមារត្រូវតែចូលរៀននៅសាលាមត្តេយ្យដើម្បីរៀបចំខ្លួនជាស្រេច មុនចូលសាលាបឋមសិក្សា ព្រោះថាគ្រូមត្តេយ្យត្រូវតែផ្តល់គំរូល្អដល់កុមារ និងពង្រឹងស្វ័យភាពដល់កុមារឱ្យគេស្គាល់នូវបញ្ញត្តិងាយៗ។ មិនតែប៉ុណ្ណោះកម្មវិធីសិក្សាត្រូវតែមានមុខវិជ្ជាជាច្រើន ហើយមានទំនាក់ទំនងគ្នារវាងមុខវិជ្ជានីមួយៗ ផងដែរ។

**២.៨.៥.ការអភិវឌ្ឍផ្នែកភាសា**

ក្នុងវ័យ ៥ឆ្នាំ កុមារអភិវឌ្ឍផ្នែកភាសា គឺគេអាចប្រើប្រាស់ប្រយោគពេញលេញ និងស្មុគស្មាញ ដើម្បីសំដែងនូវគំនិតរបស់គេ។ កុមារចេះកត់ត្រានូវគំនិតនានា តាមរយៈការគូរ ចេះរាប់ចំនួន រៀបរាប់រាងធរណីមាត្រផ្សេងៗ ដូចជា ការេ ត្រីកោណ រង្វង់។ មិនតែប៉ុណ្ណោះ កុមារអាចប្រើប្រយោគដើម្បីនិទានរឿងវែងៗ ជូនដល់ក្រុមគ្រួសារ និងមិត្តភក្តិ ស្តាប់ និងចេះនិយាយប្រាប់ឈ្មោះខ្លួនឯង ឈ្មោះក្រុមគ្រួសារប្រាប់អ្នកដទៃ។ បន្ថែមលើនេះ កុមារក៏អាចនិយាយប្រាប់អ្នកដទៃពីអាសយដ្ឋានដែលខ្លួនរស់នៅផងដែរ។ កុមារក៏អាចប្រើប្រាស់សំណួរដើម្បីសួរទៅកាន់អ្នកដទៃ និងទទួលព័ត៌មានពីអ្នកដទៃបានល្អផងដែរ ហើយក៏អាចប្រាប់រឿងរ៉ាវដោយប្រើប្រាស់ពាក្យពេចន៍ផ្ទាល់ខ្លួន បង្ហាញពីអារម្មណ៍ និងសេចក្តីត្រូវការ និងចេះរង់ចាំវេនដើម្បីនិយាយរួមទាំងចូលរួមសន្ទនាជាមួយមនុស្សជុំវិញខ្លួនដោយនិយាយយ៉ាងស្ទាត់ជំនាញ និងច្បាស់លាស់មិនចាកប្រធាន ប្រើឃ្លាប្រយោគល្អៗ ត្រឹមត្រូវទៅតាមស្ថានភាព និងអាចប្រើប្រាស់ឃ្លាប្រយោគពី ៤ទៅ ៥ពាក្យបានត្រឹមត្រូវ។ (ក្រសួងអប់រំយុវជននិងកីឡា, កម្មវិធីសិក្សាកុមារអាយុ៥ឆ្នាំ, ឆ្នាំ២០០៧)

សរុបមក តាមរយៈការអភិវឌ្ឍផ្នែកសំខាន់ៗ ទាំង៥ ដែលបានរៀបរាប់ខាងលើបង្ហាញថាកុមារអាយុ ៥ឆ្នាំ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការត្រៀមខ្លួនចូលរៀននៅសាលាបឋមសិក្សា ប្រកបដោយលក្ខណៈពេញលេញប្រសិនបើគេបានអន្តរាគមន៍ពីក្រុមគ្រួសារ និងគ្រូមត្តេយ្យ។ ហេតុនេះនៅសាលាមត្តេយ្យ គ្រូត្រូវយល់ដឹងពីការអភិវឌ្ឍតាមស្តង់ដារបស់កុមារ ត្រូវរៀបចំបរិស្ថានសិក្សាប្រកបដោយប្រសិទ្ធភាព និងត្រូវមានកម្មវិធីសិក្សាមួយស្របតាមការអភិវឌ្ឍរបស់កុមារ និងឆ្លើយតបទៅនឹងស្តង់ដាសិក្សារបស់កុមារអាយុ៥ឆ្នាំ។

ជាមួយគ្នានេះដែរ នៅក្នុងទស្សនវិជ្ជាអប់រំរបស់លោក Jan Komensky(១៥៩២-១៦៧០)ដែលគេទទួលស្គាល់ថាជា Comenius ជាអាចារ្យ និងគរុវិទូនៃមនុស្សអន្តរកាល រវាងគរុវិទូមនុស្សនិយមមុនសម័យ។ ទស្សនវិជ្ជាអប់រំរបស់គាត់ គឺការបណ្តុះបណ្តាលការយល់ដឹងសកល ដោយសង្កត់ធ្ងន់ទៅលើការសិក្សាតាមរយៈសរីរាង្គឥន្ទ្រីយ៍។ លោកបាននិពន្ធសៀវភៅរូបភាពដំបូងគេបង្អស់សម្រាប់បង្រៀនកុមារ។ គរុវិទូរូបនេះបានគោរពតម្រូវការ និងចំណូលចិត្តរបស់កុមារ។ គាត់បានជំរុញឱ្យគ្រូបង្កើតមេរៀន និងសម្ភារៈសិក្សាឱ្យបានសមស្របតាមដំណាក់កាលនៃការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ និងបានផ្តល់ដំបូន្មានថាការសិក្សារបស់កុមារមានប្រសិទ្ធភាពបំផុត គឺនៅពេលដែលពួកគេត្រៀមខ្លួនរួចជាស្រេច ដើម្បីសិក្សានូវបំណិន ឬមុខវិជ្ជាណាមួយ។ គាត់បានផ្តល់ដំបូន្មានបន្ថែមថា គ្រូត្រូវចេះរៀបចំមេរៀនជាជំហានតូចៗ ដែលធ្វើឱ្យកុមារទទួលបាននូវចំណេះដឹងយ៉ាងងាយស្រួល និងធ្វើឱ្យការសិក្សារបស់គេប្រព្រឹត្តទៅបានល្អមានការកើនឡើង និងមានភាពរីករាយ( So Suthy (M.ed)p.៩៥)។

ការបង្ហាញនូវទស្សនៈនេះ ឃើញថាកុមារតូចអាចរៀនបាននៅក្នុងវ័យនេះ តាមរយៈរូបភាព ការរៀបចំមេរៀនមានលក្ខណៈតូចៗ សាមញ្ញ ព្រមទាំងគោរពតាមតម្រូវការ និងចំណូលចិត្តរបស់កុមារ។ ក្នុងន័យនេះ គឺត្រូវតែរៀបចំឱ្យមានកម្មវិធីសិក្សាមួយស្របតាមកម្រិតអាយុរបស់កុមារ។ លោក Jean-Jacqes Rousseau (1712-1778) គរុវិទូបារាំងមានកំណើតនៅស្វីស ក៏បានបង្ហាញនូវទស្សនៈរបស់គាត់ដោយ

ណែនាំឱ្យធ្វើការអប់រំត្រូវគោរពបុគ្គលិកលក្ខណៈរបស់កុមារ មានន័យថាអ្នកអប់រំត្រូវស្គាល់ចិត្តសាស្ត្រ និងការលូតលាស់របស់កុមារ ទើបអាចសម្របសម្រួលវិធីសាស្ត្រអប់រំរបស់ខ្លួនសមស្របនឹងកម្រិតរបស់កុមារ។ គំនិតសំខាន់មួយទៀតរបស់ Rousseau គឺថាកម្មវិធីសិក្សាគួរតែឆ្លុះបញ្ចាំងដល់ចំណូលចិត្ត និងតម្រូវការរបស់កុមារ កម្មវិធីសិក្សាត្រូវផ្អែកលើធម្មជាតិរបស់កុមារ ឬចំណាប់អារម្មណ៍ កម្មវិធីសិក្សាត្រូវសង្កត់ធ្ងន់ទៅលើមុខវិជ្ជាណាដែលជួយកុមារឱ្យមានប្រយោជន៍ កម្មវិធីសិក្សាត្រូវសង្កត់ធ្ងន់លើមូលដ្ឋានវិទ្យាសាស្ត្រ។ ដូច្នេះគេត្រូវគិតពីកម្មវិធីសិក្សា(គួយ សូគាន ,p.៤៦)។ លោក John Dewey (១៨៥៩-១៩៥២) ជាទស្សនវិទូអាមេរិកាំងដ៏សំខាន់ម្នាក់។ សៀវភៅរបស់លោកមានចំណងជើងថា "កុមារ និងកម្មវិធីសិក្សា" បានផ្តល់នូវមគ្គុទ្ទេសន៍ និងការប្រតិបត្តិដែលត្រូវបានគេប្រើប្រាស់នៅសាកលវិទ្យាល័យ Chicago Laboratory School កុមារត្រូវបានគេមើលឃើញថា ជាមនុស្សសកម្មក្នុងសង្គមដែលចង់ចេះចង់ដឹងដើម្បីស្វែងរក និងទទួលបានការគ្រប់គ្រងទៅលើបរិស្ថានតាមការធ្វើអន្តរកម្មជាមួយពិភពលោក កុមារត្រូវប្រឈមមុខទាំងបញ្ហាសង្គម និងបុគ្គល។ ការជួបប្រទះបញ្ហាទាំងអស់នេះ ត្រូវភ្ញោចកុមារឱ្យចេះប្រើប្រាស់បញ្ញារបស់ពួកគេ ដើម្បីដោះស្រាយការលំបាក និងចំណេះដឹងរបស់ពួកគេ តាមរបៀបមួយជាឧបករណ៍ និងសកម្មភាព(So Suthy(M.ed) p.៩៩)។ កម្មវិធីសិក្សារបស់Dewey រួមមានសកម្មភាពនិងលំនាំសិក្សាមានចំនួន៣កម្រិតៈ

1) កម្រិតទី១ គឺការចូលក្នុងគម្រោងការកម្រិតសកម្មភាព ធ្វើឱ្យកុមារចូលរួមក្នុងគម្រោងការដែលក្នុងនេះគេស្រាវជ្រាវរុករកក្នុងបរិស្ថាន និងរៀបចំគំនិតរបស់គេទៅជាទម្រង់រូបី។ សកម្មភាពដំបូងទាំងនោះ បានអភិវឌ្ឍបំណិនចលករ និងសរីរាង្គឥន្ទ្រីយ៍ និងលើកទឹកចិត្តដល់សង្គមនីយកម្មតាមរយៈគម្រោងសហការក្រុម។
2) កម្រិតទី២ ពង្រីកកម្រិតនៃកាល និងលំហសិស្ស តាមរយៈគម្រោងការដែលជាប់ពាក់ព័ន្ធពួកគេខាងប្រវត្តិវិទ្យានិងភូមិវិទ្យា។
3) កម្រិតទី៣ គឺវិទ្យាសាស្ត្រ បាននាំកុមារឱ្យមានទំនាក់ទំនងទៅនឹងមុខវិជ្ជាផ្សេងៗ ដូចជា គីមីវិទ្យា ជីវវិទ្យា និងវិទ្យាសាស្ត្រសង្គមដែលពួកគេអាចប្រើប្រាស់ជាប្រភពព័ត៌មានដើម្បីដោះស្រាយបញ្ហា។

កម្រិតកម្មវិធីសិក្សាទាំង៣នេះ ធ្វើឱ្យការសិក្សាមានចលនាពីសាមញ្ញទៅដល់ការសង្កេតបរិស្ថានដោយយកចិត្តទុកដាក់ដើម្បីធ្វើផែនការសកម្មភាព ហើយជាចុងបញ្ចប់ដើម្បីឆ្លុះបញ្ចាំង និងធ្វើតេស្តទៅលើផលនៃសកម្មភាព(So Suthy (M.ed) p.១០០)។

តាមទ្រឹស្តីរបស់ Dewey បញ្ជាក់ថា កុមារត្រូវការចង់ចេះ ចង់ដឹង និងស្វែងយល់ ហេតុនេះចាំបាច់ត្រូវឱ្យគេចូលសាលាមត្តេយ្យ និងមានកម្មវិធីសិក្សាមួយច្បាស់លាស់ ដើម្បីភ្ញោចបញ្ញារបស់គេ ឱ្យមានការលូតលាស់ ព្រមទាំងត្រូវសិក្សាពីមុខវិជ្ជាច្រើនដែលជាបុរេមុខវិជ្ជា ដើម្បីជាមូលដ្ឋានគ្រឹះទៅសិក្សានូវមុខវិជ្ជាផ្សេងៗ នៅថ្នាក់បន្តបន្ទាប់ និងត្រូវមានការគាំទ្រពីគ្រូ ដោយមានការប្រតិបត្តិជាក់ស្តែង និងអនុវត្តប្រកបដោយប្រសិទ្ធភាព។

លោកស្រី Marria Montessori (១៨៧០-១៩៥២) ជាស្ត្រីជនជាតិអ៊ីតាលីមុនគេ ដែលបានក្លាយជាអ្នកអប់រំផ្នែកខាងស្ត្រី និងជាស្ត្រីវេជ្ជបណ្ឌិត។ ទស្សនៈរបស់លោកស្រីបានសន្និដ្ឋានថា កុមារមានតម្រូវការខាងក្នុងដើម្បីធ្វើកិច្ចការដែលពួកគេបានចាប់អារម្មណ៍ ការផ្តល់សម្ភារៈត្រឹមត្រូវ និងច្បាស់លាស់ កុមារមិនចាំបាច់ត្រូវការនូវរង្វាន់ និងទណ្ឌកម្ម ដែលផ្តល់តាមរយៈគ្រូនោះទេ។ លោកស្រីយល់ថាកុមារចូលចិត្តធ្វើការងារច្រើនជាងការលេងដែលជាសមត្ថភាពកើតឡើងបន្តគ្នា ក្នុងរយៈពេលនៃការប្រមូលផ្តុំ។ ពួកគេត្រូវការបរិស្ថានមួយដែលរៀបចំមានសណ្តាប់ធ្នាប់។ ហេតុនេះ កម្មវិធីសិក្សារបស់លោកស្រី បានឆ្លុះបញ្ចាំងទៅលើ

របៀបរៀបចំបរិស្ថាន(គួយ សូគាន p.៦០)។ ចំណែក លោក Ralph Tyler បានអះអាងថា ការអភិវឌ្ឍកម្មវិធីសិក្សាត្រូវគិតជាមួយនឹងសំណួរ៤ ដែលមានឥទ្ធិពលលើការសិក្សាកម្មវិធីសិក្សា៖

1) តើសាលារៀនគួរស្វែងរកគោលដៅអប់រំមួយណានៅក្នុងការរក្សាទៅមុខ?
2) តើវិធីណាដែលអាចឱ្យបទពិសោធសិក្សាដែលត្រូវជ្រើសរើសថាមានប្រយោជន៍ក្នុងការរក្សានូវគោលដៅទាំងនោះ?
3) តើបទពិសោធសិក្សា ត្រូវរៀបចំដោយរបៀបណា សម្រាប់ការបង្រៀនមានប្រសិទ្ធភាព?
4) តើគេអាចវាយតម្លៃប្រសិទ្ធភាពនៃបទពិសោធសិក្សាដោយរបៀបណា? (Tyler 1949 P.5-6)

ក្នុងន័យនេះ ចង់បញ្ជាក់ថា កម្មវិធីសិក្សាមិនត្រូវនៅទ្រឹងមួយកន្លែងទេ គឺត្រូវការអភិវឌ្ឍ។ ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាត្រូវគិតទៅដល់គោលដៅអប់រំមួយដែលមានការវិវឌ្ឍ ត្រូវរៀបចំកម្មវិធីសិក្សាបែបណាដើម្បីឱ្យមានប្រសិទ្ធភាព និងអាចវាយតម្លៃប្រសិទ្ធភាពនោះបាន។

តាមរយៈការរៀបរាប់ខាងលើ ឃើញថាការអប់រំកុមារតូច ចាំបាច់ត្រូវមានសាលាមត្តេយ្យដែលជាទីកន្លែងសម្រាប់ឱ្យពួកគេត្រៀមខ្លួនជាស្រេច ដើម្បីចូលរៀននៅសាលាបឋមសិក្សាប្រកបដោយគុណភាព។ ដើម្បីរៀនគេត្រូវការកម្មវិធីសិក្សាមួយច្បាស់លាស់ មានការអភិវឌ្ឍ និងមានប្រសិទ្ធភាព និងដែលស្របនឹងតម្រូវការរបស់ពួកគេ ឱ្យស្របនឹងអាយុនិងការយល់ដឹង មានទំនាក់ទំនងនឹងមុខវិជ្ជាជាច្រើននៅថ្នាក់បន្តបន្ទាប់។ ដូចនេះ កុមារតូចត្រូវត្រៀមនូវបុរេមុខវិជ្ជាដែលជាពហុមុខវិជ្ជា ដោយផ្ដោតខ្លាំងលើមូលដ្ឋានវិទ្យាសាស្ត្រព្រោះកុមារត្រូវការភាពជាក់ស្ដែង។

## ២.៩.កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ

### ២.៩.១.សាវតារ

ការអប់រំចាប់ផ្ដើមពីកុមារតូច ជាការអប់រំដែលមានសារៈសំខាន់បំផុត ក្នុងការបណ្ដុះស្មារតីជាមូលដ្ឋាននៃការបង្កើតចរិតលក្ខណៈមនុស្សពេញលេញ។ ការបណ្ដុះសញ្ញាណបំណិនសិក្សាពេញមួយជីវិត ការបង្កើតបរិស្ថានសិក្សារួម និងមធ្យោបាយមានប្រសិទ្ធភាពជាច្រើន នឹងធ្វើឱ្យសម្រេចបាននូវគោលដៅរួមនៃលទ្ធផលសិក្សារបស់កុមារ។ សេវាអប់រំកុមារតូចដែលមានមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សាឯកជន និងកម្មវិធីអប់រំតាមផ្ទះ ទទួលកុមារអាយុ៣ឆ្នាំ បាន ២១.៨០% កុមារអាយុ៤ឆ្នាំបាន ៣៩.៩០% និងកុមារអាយុ៥ឆ្នាំបាន ៦៨.៥០% នៅឆ្នាំ២០១៧-២០១៨។

ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ដល់ការសិក្សានៅមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសហគមន៍ ជាពិសេសតំបន់ជួបការលំបាក។ កម្មវិធីសិក្សានៅមត្តេយ្យសិក្សាត្រូវបានកែលម្អឡើងវិញនៅឆ្នាំ២០០៧ ដោយបានរៀបចំតម្រង់តាមស្តង់ដាអភិវឌ្ឍសិក្សារបស់កុមារតូច ដែលមាន៥ផ្នែកសំខាន់ៗគឺ ការអភិវឌ្ឍរាងកាយនិងសុខភាព ការអភិវឌ្ឍសីលធម៌និងវប្បធម៌ ការអភិវឌ្ឍសង្គមនិងអារម្មណ៍ ការយល់ដឹងនិងការពិចារណា និងការអភិវឌ្ឍផ្នែកភាសា។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលបានឯកភាពគោលនយោបាយជាតិស្ដីពីការគាំពារ និងអភិវឌ្ឍកុមារតូច ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០ ព្រមទាំងបានឯកភាពរៀបចំយន្តការអន្តរក្រសួងក្នុងការអនុវត្តគោលនយោបាយជាតិនេះផងដែរ។

ស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព(SDG-4) "ធានាការអប់រំបរិយាប័ន្ន សមធម៌ គុណភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា" ជាពិសេសក្នុងចំណុចដៅ ៤.២ បានកំណត់ត្រឹមឆ្នាំ២០៣០ ធានាថាកុមារទាំងអស់ទទួលបានការអប់រំកម្រិតមត្តេយ្យសិក្សា ការថែទាំ ការអភិវឌ្ឍ

កុមារតូចប្រកបដោយគុណភាព ដើម្បីពួកគេបានត្រៀមខ្លួនជាស្រេចចូលរៀននៅកម្រិតបឋមសិក្សា។ ឆ្លើយតបនឹងចំណុចដៅខាងលើនេះ រាជរដ្ឋាភិបាលអាណត្តិទី៥ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវផែនការកែទម្រង់ស៊ីជម្រៅលើវិស័យអប់រំ ក្នុងនោះក្របខ័ណ្ឌកម្មវិធីសិក្សាថ្មីមួយត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៦ ដោយបានដាក់បញ្ចូលការអប់រំនៅមត្តេយ្យសិក្សាផងដែរ ។ ដើម្បីផ្សារភ្ជាប់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ទៅនឹងការអប់រំនៅបឋមសិក្សា ក្របខ័ណ្ឌកម្មវិធីសិក្សាថ្មីនេះ បានសម្រួលខ្លឹមសារកម្មវិធីសិក្សាដែលកំពុងអនុវត្តមាន ១០មុខវិជ្ជាមកជា ៥មុខវិជ្ជាវិញ គឺចិត្តចលភាព បុរេគណិត ភាសាខ្មែរ វិទ្យាសាស្ត្រ និងសិក្សាសង្គម ។

### ២.៩.២.គោលដៅរួមនៃការសិក្សា

ការសិក្សារៀនសូត្ររបស់កុមារបានចាប់ផ្តើមឡើងពីការប្រើប្រាស់ញាណ និងចិត្តចលភាព តាមរយៈការលេង និងសកម្មភាពដោយផ្ទាល់របស់កុមារ។ ការផ្សារភ្ជាប់ការលេងរបស់កុមារទៅនឹងការច្នៃប្រឌិតតាមរយៈវិធីសាស្ត្រខុសៗគ្នា វានឹងផ្តល់នូវមូលដ្ឋានចំណេះដឹង និងជំនាញមួយចំនួន ដូចជាសមត្ថភាពគិតពិចារណា វិនិច្ឆ័យ ម្ចាស់ការ ការចូលរួមសហការ និងការដោះស្រាយបញ្ហាជាដើម។ សញ្ញាណនៃមុខវិជ្ជាមួយចំនួនត្រូវបានដាក់បញ្ចូលក្នុងគោលដៅសិក្សានៅមត្តេយ្យសិក្សា ដើម្បីផ្សារភ្ជាប់ចំណេះដឹង និងបំណិន ទៅបឋមសិក្សាពោរពេញដោយសក្តានុពល។ នៅពេលបញ្ចប់មត្តេយ្យសិក្សា កុមារនឹងមានសមត្ថភាព៖

- ការត្រិះរិះពិចារណា និងដោះស្រាយបញ្ហា៖ ១)សម្តែងអារម្មណ៍ និងចេះសង្កត់ចិត្តរបស់ខ្លួន ២)ការយល់ដឹងហេតុនិងផល ៣)ការគិតនិងវិភាគគ្រប់ជ្រុងជ្រោយ ៤)គោលវិធីជាវិជ្ជមាន និងជាចំហដើម្បីដោះស្រាយបញ្ហា។
- ចិត្តចលភាព៖ ១)ការហ្វឹកហាត់បង្កើនកម្លាំង និងការសម្របសម្រួលរវាងចលនាសាច់ដុំដៃ និងសាច់ដុំភ្នែក ២)ការហ្វឹកហាត់បង្កើនកម្លាំង និងការសម្របសម្រួលរវាងចលនាសាច់តូចនិងសាច់ដុំធំ ៣)ការបង្កើនកម្លាំង និងការប្រឈមទប់ទល់ឧបសគ្គក្នុងពេលធ្វើសកម្មភាព។
- វិទ្យាសាស្ត្រ៖ ១)ចំណេះដឹងមូលដ្ឋានអំពីក្រុមអាហារ និងអាហារូបត្ថម្ភ ២)ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារ និងសង្គម ៣)ការយល់ដឹងពីការប្រតិបត្តិខ្លួនដើម្បីសុវត្ថិភាព ៤)ការស្វែងយល់ដោយការសង្កេត ៥)អ្វីៗដែលគ្មានជីវិត និងមានជីវិត ៦)លក្ខណៈមេឃ និងអាកាសធាតុ ៧)លក្ខណៈរូបធាតុ ៨)អំពីរាងកាយផ្ទាល់ខ្លួន ៩)ការប្រើប្រាស់សម្ភារៈតាមបច្ចេកវិទ្យា ១០)ការយល់ដឹងពីហេតុ និងផល ១១)ចំណេះដឹងអំពីសហគមន៍។
- សិក្សាសង្គម៖ ១)ការយល់ដឹងពីតម្លៃនិងចរិតលក្ខណៈមនុស្ស ២)ការលើកតម្កើងវប្បធម៌របស់ខ្លួន ៣)អត្តសញ្ញាណរបស់ខ្លួន ៤)បំណិនរស់នៅក្នុងសង្គម និងទំនាក់ទំនងវិជ្ជមានជាមួយមនុស្សជុំវិញ ៥)បំណិនរស់នៅក្នុងសង្គម និងទំនាក់ទំនងល្អជាមួយមិត្តភក្តិដែលមានវ័យប្រហែលគ្នា ៦)ការយល់ដឹងអំពីទង្វើ និងលទ្ធផល ៧)ការពេញចិត្ត ចំពោះលក្ខណៈផ្សេងគ្នារបស់បុគ្គល ៨)ស្គាល់ពីអារម្មណ៍មួយចំនួន ៩)សម្តែងអារម្មណ៍ និងចេះសង្កត់ចិត្តរបស់ខ្លួន ១០)គោលវិធីជាវិជ្ជមាន និងចំហដើម្បីដោះស្រាយបញ្ហា ១១)ការយល់ដឹងអំពីបរិស្ថានធម្មជាតិ និងវិធីការពារ ១២)ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព ១៣)ការយល់ដឹងពីភាពផ្លាស់នៃវត្ថុ

តាមចង្វាក់ និងការគូរគំនូរ ១៤)ចំណេះដឹងបច្ចេកទេស ចលនាការច្នៃប្រឌិត និងបទពិសោធផ្នែកតន្ត្រី។

- បុរេគណិតៈ ១)ស្គាល់ និងយល់លេខតាង និងការគណនាលេខសាមញ្ញៗ ២)ការគិត និងវិភាគគ្រប់ជ្រុងជ្រោយ ៣)បញ្ញត្តិស្តីពីរង្វាស់រង្វាល់ ៤)បញ្ញត្តិនៃរូបរាង និងលំហ ៥)ចំណាត់ក្រុមនិងលំដាប់លំដោយ ៦)ភាពខុសគ្នារវាងព្រឹត្តិការណ៍ដែលកើតឡើងក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ៧)ចំណេះដឹងនៃបញ្ញត្តិសេដ្ឋកិច្ចសាមញ្ញមួយចំនួន។
- ភាសាខ្មែរៈ ១)ស្តាប់គេនិយាយ និងមានសមត្ថភាពស្តាប់ដោយធ្វើតាមការណែនាំងាយៗ ២)សន្ទនាដោយប្រើពាក្យ ឬឃ្លាសមស្របទៅតាមវ័យ(ភាសាបង្ហាញអារម្មណ៍និងមនោសញ្ចេតនា) ៣)ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ ៤)ទំនាក់ទំនងដោយប្រើពាក្យសម្តី ៥)ទំនាក់ទំនងដោយប្រើកាយវិការ និងនិមិត្តសញ្ញា ៦)និមិត្តសញ្ញាតំណាងឱ្យមនុស្ស សត្វ ឬវត្ថុនានា ៧)ការប្រើញាណដើម្បីអភិវឌ្ឍបំណិនសមត្ថភាពទាំង៦ ៨)ការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង ៩)ការយល់ដឹងអំពីបញ្ញតិនៃសំណេរ ១០)ការយល់ដឹង និងការពេញចិត្តអំពីការអាន ការប្រើប្រាស់ឯកសារសំណេរឯកសារផ្សេងៗ ១១)ការយល់ដឹងអំពីគោលការណ៍អក្ខរក្រម ១២)បំណិនសរសេរកាន់តែប្រសើរឡើង ១៣)ការយល់ដឹងពីការប្រើភាសាខុសគ្នាសម្រាប់ប្រាស្រ័យទាក់ទងគ្នាក្រៅពីភាសាផ្ទាល់ខ្លួន។

### ២.៩.៣.គោលការណ៍គ្រឹះ

កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា គឺជាអភិក្រមសមស្របតាមការអភិវឌ្ឍ ដែលគិតគូពីការលើកកម្ពស់ការរៀនសូត្រដ៏សកម្ម ការប្រើប្រាស់មជ្ឈដ្ឋានសិក្សា ការរៀបចំផែនការ និងការពិនិត្យឡើងវិញព្រមទាំងបង្កលក្ខណៈឱ្យកុមារអភិវឌ្ឍទៅតាមភាពសមស្រប ទៅតាមតម្រូវការពិសេស និងដោយឡែករបស់ពួកគេ។ កម្មវិធីសិក្សានេះ បានរៀបចំឡើងឈរលើគោលការណ៍សំខាន់ៗ ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សា ដែលមានការអភិវឌ្ឍផ្នែកកាយសម្បទា វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ការអភិវឌ្ឍចំណេះដឹង និងជំនាញ ក៏ជាចំណុចចាប់ផ្តើមនៃការទទួលយករបស់កុមារមុននឹងមានការប្រែប្រួលផ្នែកកាយសម្បទា និងចរិយាសម្បទា។ បំណិនជាច្រើនរបស់កុមារដូចជា បំណិនដោះស្រាយបញ្ហា អន្តរបុគ្គល ទំនាក់ទំនង និងបរិស្ថានជាដើម ត្រូវបានដាក់បញ្ចូលសមស្របតាមការអភិវឌ្ឍរូបរាងកាយ អាយុ និង វប្បធម៌របស់កុមារ។ កម្មវិធីសិក្សានេះ បានបំផុសគំនិតច្នៃប្រឌិត ការប្រើប្រាស់សម្ភារឧបទេស សម្ភារៈរូបវន្ត ការប្រើប្រាស់ពេលវេលាសិក្សា និងការណែនាំក្នុងការរៀន និងបង្រៀន ដើម្បីធ្វើឱ្យសម្រេចគោលដៅសិក្សាប្រកបដោយគុណភាព។ គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងសកម្មភាពរៀន និងបង្រៀន ដោយសម្របសម្រួលលើកទឹកចិត្ត ប្រើប្រាស់សម្ភារៈសមស្រប ជំរុញការរៀនសូត្ររបស់កុមារឱ្យមានភាពរស់រវើក និងសម្រេចគោលដៅសិក្សាស្របតាមអាយុរបស់កុមារ។ ការរៀបចំបរិស្ថានសាលារៀន ថ្នាក់រៀន ផែនការបង្រៀន ការតាមដានការរៀនសូត្ររបស់កុមារ និងយន្តការនានា ដើម្បីពង្រឹងប្រសិទ្ធភាពការងារក៏ជាគោលដៅសំខាន់សម្រាប់កម្មវិធីសិក្សាផ្នែកមត្តេយ្យសិក្សានេះផងដែរ។គោលការណ៍គ្រឹះសម្រាប់អនុវត្តកម្មវិធីសិក្សាផ្នែកមត្តេយ្យសិក្សាមានៈ

1. ការរៀន និងបង្រៀនត្រូវអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌល
2. ការសិក្សារបស់កុមារត្រូវធ្វើឡើងតាមការលេង និងសហការ
3. កុមារត្រូវបានផ្តល់ទំនុកចិត្ត ការលើកទឹកចិត្ត និងការទទួលខុសត្រូវក្នុង ការរៀនសូត្រប្រកបដោយសុវត្ថិភាព និងភាពកក់ក្តៅ

4. អន្តរកម្មនៃការសិក្សាប្រកបដោយគុណភាពកុមារនឹងទទួលបានចំណេះដឹង បំណិន និង ឥរិយាបថថ្មីៗ បន្ថែមទៀតពីបរិស្ថានសិក្សារបស់កុមារ
5. កុមារជាអ្នកកសាងសមត្ថភាពដោយខ្លួនឯង គ្រូជាអ្នកណែនាំ និងសម្របសម្រួល ដើម្បីឱ្យកុមាររៀនសូត្របានល្អប្រសើរ
6. ការរៀបចំកិច្ចតែងការបង្រៀន ត្រូវធ្វើតាមគោលវិធីចម្រុះ
7. បង្កើតយន្តការតាមដានការរៀនសូត្ររបស់កុមារប្រកបដោយប្រសិទ្ធភាព
8. ការបង្រៀន និងរៀនត្រូវដំណើរការស្របតាមអាយុ វប្បធម៌ និងសមធម៌
9. ការរៀន និងបង្រៀនត្រូវមានលក្ខណៈជាក់ស្តែង និងវិទ្យាសាស្ត្រ
10. សាលារៀន និងគ្រូបង្រៀនត្រូវធ្វើអន្តរកម្មជាមួយអាណាព្យាបាល សហគមន៍ និងរដ្ឋអំណាច ដើម្បីធានាគុណភាព និងប្រសិទ្ធភាព។

### ២.៩.៤.ការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សា

ជាទូទៅការវាយតម្លៃមានច្រើនបែបច្រើនយ៉ាង និងមានគោលបំណងផ្សេងៗគ្នា។ ដោយឡែកការវាយតម្លៃនៅមត្តេយ្យសិក្សាមានគោលបំណងដូចតទៅ៖

- វាស់កម្រិតចំណេះដឹង បំណិន ឬសមត្ថភាពរបស់សិស្ស ក្រោយពីបានសិក្សាចប់មេរៀន ជំពូក ប្រធានបទ ឬកម្មវិធីសិក្សាតាមកម្រិតថ្នាក់ តាមមុខវិជ្ជា ឬតាមភូមិសិក្សានីមួយៗ
- វាស់កម្រិតនៃការប្រែប្រួល ឬការរីកចម្រើនផ្លូវចិត្ត និងគុណតម្លៃនានា ដូចជា តម្លៃសីលធម៌ ឥរិយាបថ សាមគ្គីភាព ព្រហ្មវិហារធម៌។ល។
- ឆ្លុះបញ្ចាំងពីលទ្ធផលនៃការរៀន និងបង្រៀន ដោយផ្តល់ព័ត៌មានត្រឡប់ក្នុងការជួយគ្រូ សិស្ស មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និងគណៈគ្រប់គ្រង ដើម្បីលើកកម្ពស់គុណភាពនៃការរៀន និងបង្រៀនឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពខ្ពស់។

សម្រាប់ការវាយតម្លៃនៅមត្តេយ្យសិក្សា មានលក្ខណៈពិសេសដោយឡែកពីវិធីវាយតម្លៃសម្រាប់សិស្សនៅបឋមសិក្សា និងមធ្យមសិក្សា។ គ្រូមានតួនាទីយ៉ាងសំខាន់ក្នុងការសង្កេតតាមដាន និងវាយតម្លៃការរីកចម្រើនរបស់កុមារតាំងពីកាយ វាចា ចិត្ត ឥរិយាបថ និងការចូលរួមរបស់កុមារ។ ការតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់កុមារគួរមានបីដំណាក់កាលដូចតទៅ៖

- **ការស្តាប់ និងសង្កេតមើលកុមារ៖** ការស្តាប់ និងសង្កេតមើលដំណើរការលេង និង ការរៀនសូត្ររបស់កុមារ ដោយកំណត់ចំណុចដែលត្រូវសង្កេត និងតាមដានជាស្រេច។ សង្កេត ស្តាប់ តាមដានត្រួសៗក្រៅផ្លូវការ។ សង្កេត តាមដានផ្លូវការ គួរធ្វើឡើងជាលក្ខណៈបុគ្គល ជាដៃគូ និងជាក្រុម។ ប្រើតារាងដែលបង្ហាញពីការអភិវឌ្ឍរបស់កុមារលើចំណុចដែលបានកំណត់។ ធ្វើកំណត់ហេតុនៃការតាមដានដោយជាក់លាក់ និងសត្យានុម័ត។ ផ្តល់ព័ត៌មានត្រឡប់ជាក់លាក់ដល់អ្នកពាក់ព័ន្ធ។
- **ការជំរុញ និងផ្តល់ការណែនាំបន្ថែម៖** បន្ទាប់ពីទទួលបានព័ត៌មានជាក់លាក់ពីកុមារទៅតាមលទ្ធផលនៃការសង្កេតតាមដានរួចហើយ គ្រូបង្រៀន ឬអ្នកពាក់ព័ន្ធគប្បី៖ ជំរុញ និងលើកទឹកចិត្តកុមារទៅតាមចំណេះដឹង ទេពកោសល្យ និងការអភិវឌ្ឍរបស់កុមារដោយបង្កលក្ខណៈ និងបរិយាកាសសិក្សាដើម្បីធ្វើឱ្យសម្រេចបានលទ្ធផលល្អទៅលើចំណុចខ្វះខាតដែលបានរកឃើញ។ ធ្វើអន្តរកម្មជាមួយកុមារឱ្យកាន់តែប្រសើរឡើងដោយប្រើប្រាស់គ្រប់មធ្យោបាយ និងធនធាន ដើម្បីឱ្យកុមារចាប់យកចំណេះដឹង និងបំណិន ទៅតាមគោលការណ៍កំណត់។ បន្តជំរុញ និងលើកទឹកចិត្តឱ្យកុមារទទួល

បានចំណេះដឹង និងបំណិនថ្មីៗ ថែមទៀត ទៅតាមចំណង់ចំណូលចិត្ត ទេពកោសល្យ និងមុខវិជ្ជាសិក្សា។

- **ការវាយតម្លៃលទ្ធផលសិក្សារបស់កុមារជាផ្លូវការ៖** ដំណាក់កាលនេះ ជាដំណាក់កាលបញ្ជាក់ចុងក្រោយពីលទ្ធផលនៃការប្រែប្រួល និងការអភិវឌ្ឍរបស់កុមារ ទៅលើគោលដៅសិក្សាដែលបានកំណត់ដោយប្រមូលអង្គហេតុដែលបញ្ជាក់ដោយកិច្ចការរបស់កុមារ។ វិភាគ និងវាយតម្លៃព័ត៌មានដែលទទួលបាន។ ប្រៀបធៀបលទ្ធផលជាមួយបញ្ជីក្នុងតារាងត្រួតពិនិត្យដែលបានតាមដាន។ ឆ្លុះបញ្ចាំងទៅលើការសិក្សារៀនសូត្ររបស់កុមារ ការអនុវត្តរបស់គ្រូ សាលារៀន ធនធានបរិស្ថានសិក្សា និងយន្តការនានាក្នុងដំណើរការរៀន និងបង្រៀន។ រកវិធានការនានា ដែលមានគុណភាព និងប្រសិទ្ធភាពដើម្បីអនុវត្តបន្តប្រកបដោយទំនុកចិត្ត។

### ២.៩.៥.ចំណែកចែកម៉ោងសិក្សា

កម្មវិធីសិក្សាត្រូវបានកំណត់ឱ្យបង្រៀនចំនួន ៣៥សប្ដាហ៍ ក្នុង១ឆ្នាំសិក្សា។ សិក្សា៥ថ្ងៃ ក្នុង១សប្ដាហ៍ ៦ម៉ោងសិក្សាក្នុង១ថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល ៣០នាទី។

| ល.រ. | មុខវិជ្ជា | មត្តេយ្យសិក្សា | | |
|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ |
| ១ | ចិត្តចលភាព | ៦ | ៦ | ៦ |
| ២ | បុរេគណិត | ៣ | ៣ | ៣ |
| ៣ | ភាសាខ្មែរ | ៤ | ៤ | ៤ |
| ៤ | វិទ្យាសាស្ត្រ | ៣ | ៣ | ៣ |
| ៥ | សិក្សាសង្គម | ១៤ | ១៤ | ១៤ |
| សរុបម៉ោងប្រចាំសប្ដាហ៍ | | **៣០** | **៣០** | **៣០** |

តារាងប្រៀបធៀបម៉ោងសិក្សាប្រចាំឆ្នាំតាមមុខវិជ្ជាទាំង៣កម្រិត

| **ល.រ.** | **មុខវិជ្ជា** | **ម៉ោងក្នុង១សប្ដាហ៍** | **ម៉ោងប្រចាំឆ្នាំ** | **ភាគរយ** |
|---|---|---|---|---|
| ១ | ចិត្តចលភាព | ៦ | ៣៥×៦ = ២១០ម៉ | ២០% |
| ២ | បុរេគណិត | ៣ | ៣៥×៣ = ១០៥ម៉ | ១០% |
| ៣ | ភាសាខ្មែរ | ៤ | ៣៥×៤ = ១៤០ម៉ | ១៣% |
| ៤ | វិទ្យាសាស្ត្រ | ៣ | ៣៥×៣ = ១០៥ម៉ | ១០% |
| ៥ | សិក្សាសង្គម | ១៤ | ៣៥×១៤ = ៤៩០ម៉ | ៤៧% |
| **សរុប** | | **៣០ម៉ោង** | **១,០៥០ម៉ោង** | **១០០%** |

### ២.៩.៦.ការណែនាំអនុវត្ត

ដើម្បីអនុវត្តកម្មវិធីសិក្សាលម្អិតមត្តេយ្យសិក្សានេះប្រកបដោយគុណភាព និងប្រសិទ្ធភាព អ្នកអនុវត្តគ្រប់លំដាប់ថ្នាក់ត្រូវរៀបចំធនធាន និងយន្តការមួយចំនួនដូចជា៖

1. អភិវឌ្ឍសៀវភៅណែនាំការបង្រៀនសម្រាប់គ្រូតាមមុខវិជ្ជាស្របតាមកម្រិតនៃក្របខ័ណ្ឌកម្មវិធីសិក្សា
2. អភិវឌ្ឍសម្ភារៈបម្រើឱ្យការរៀននិងបង្រៀន និងឯកសារណែនាំប្រើប្រាស់សាមញ្ញ និងងាយស្រួលក្នុងការអនុវត្ត

3. អភិវឌ្ឍឯកសារជំនួយ និងអំណានបន្ថែមដទៃទៀត( ល្បែងសិក្សា ពាក្យបណ្តៅ សៀវភៅរឿងរូបភាព សៀវភៅរឿងនិទានងាយៗ...) ដើម្បីជួយពង្រឹងការរៀន និងបង្រៀន
4. គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងឯកជនត្រូវរៀបចំជាបន្ទប់ ឬជ្រុងសិក្សាសម្រាប់ (លេង អានសៀវភៅ សម្តែង តន្ត្រី ទុកដាក់សម្ភារៈ និទានរឿង...)
5. គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈត្រូវរៀបចំទីធ្លាប្រកបដោយបរិស្ថានល្អ មានសុវត្ថិភាពសម្រាប់ដំណើរការលេង កម្សាន្ត ល្បែង និងលំហាត់ប្រាណជាដើម
6. គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈត្រូវរៀបចំផែនការបង្រៀនប្រចាំឆ្នាំ ប្រចាំខែ និងប្រចាំថ្ងៃ ស្របតាមពេលវេលា និងកម្មវិធីសិក្សាដែលបានកំណត់
7. គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈនីមួយៗ ត្រូវរៀបចំយន្តការ និងឯកសារផ្សេងៗ ដើម្បីធ្វើអន្តរកម្មមានប្រសិទ្ធភាពរវាងសាលារៀនជាមួយមាតាបិតា អាណាព្យាបាល និងសហគមន៍
8. គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនតាមម៉ោងពេលកំណត់ និងស្របតាមខ្លឹមសារកម្មវិធីសិក្សា និងសៀវភៅណែនាំគ្រូ
9. រៀបចំធនធាន និងយន្តការថ្មីៗផ្សេងទៀត ដើម្បីពង្រឹងការអនុវត្តការងារអប់រំកុមារមត្តេយ្យសិក្សានៅកម្ពុជាប្រកបដោយការទទួលខុសត្រូវ

### ២.៩.៧.តារាងលម្អិតលទ្ធផលសិក្សា

#### ២.៩.៦.១.សម្រាប់មត្តេយ្យសិក្សាកម្រិតខ្ពស់(កុមារអាយុ៥ឆ្នាំ)

មុខវិជ្ជា ៖ ចិត្តចលភាព (២១០ម៉ោ)

| ប្រធានបទ | ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|---|
| បំណិនចលករតូច | ការហ្វឹកហាត់បង្កើនកម្លាំង និងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក | • **វិជ្ជាសម្បទា**<br>– ប្រាប់ពីរបៀបធ្វើចលនាម្រាមដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។<br>• **បំណិនសម្បទា**<br>– កំណត់ចំណុចគោលនៃចលនាដៃដោយការទប់លំនឹងនិងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ។<br>• **ចរិយាសម្បទា**<br>– មានភាពអំណត់ តស៊ូព្យាយាម និងសប្បាយរីករាយក្នុងពេលការធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ និងជោគជ័យ។ | ៣៥ម៉ |
| បំណិនចលករធំ | ការហ្វឹកហាត់បង្កើនកម្លាំងនិងការសម្របសម្រួលនៃចលនាសាច់ដុំតូចនិងសាច់ដុំធំ | • **វិជ្ជាសម្បទា**<br>– ប្រាប់ពីរបៀបវិធីដើរ រត់ វារលូន លោត ចុះនិងឡើង បោះតោងឡើង គប់ ប្រមៀល បង្វិលខ្លួន រុញ និងទាញ ទៅតាមគោលដៅ និងចម្ងាយដែលបានកំណត់។<br>• **បំណិនសម្បទា**<br>– ដើរទប់ខ្លួនឱ្យមានលំនឹងលើគំនូសខ្សែ ឬកាន់វត្ថុនានា នៅ | ៣៥ម៉ |

| | | | |
|---|---|---|---|
| | | នឹងដៃ<br>– រត់នៅមួយកន្លែង រត់យឺត រត់លឿន<br>– វារលូន ប្រមៀលខ្លួន លើកន្ទេល កម្រាលឥដ្ឋសំបកកង់<br>– គប់ចម្ងាយ គប់ចំចំណុច តោងឡើងរបារ បង្វិលខ្លួនលើដី និងជុំវិញរបស់ណាមួយរុញ និងទាញដោយប្រើរាងកាយ<br>– ដើរកាន់កែវគ្មានដៃ ដែលមានចំណុះទឹកបីភាគបួន ដោយប្រើដៃម្ខាងមិនឱ្យទឹកកំពប់ក្នុងចំងាយប្រាំម៉ែត្រ ឬលើសពីនេះ<br>– លោតខ្សែអន្ទាក់ជើងពីរដោយខ្លួនឯងចំនួន៣ជុំ ឬលើសពីនេះ<br>– ឡើង និងចុះតាមជណ្ដើរខ្សែពួរកម្ពស់២ម៉ែត្រ ឬលើសពីនេះ<br>– បោះបាល់ចំនួន ៣ដង ដោយដៃទាំងពីរ ចូលទៅក្នុង ផ្ទាំងក្រដាសរាងការេ ទំហំ ៣០សម x ៣០សម ក្នុងចម្ងាយ ៣ម៉ែត្រ ឬលើសពីនេះ។<br>• **ចរិយាសម្បទា**<br>– សប្បាយរីករាយ និងចូលចិត្តធ្វើចលនាប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាព។ | |
| ការរីកចម្រើនរាងកាយនិងចលនា | ការបង្កើនកម្លាំងនិងការប្រឈមទប់ទល់នឹងឧបសគ្គក្នុងពេលធ្វើសកម្មភាព | • **វិជ្ជាសម្បទា**<br>– បង្ហាញពីរបៀបដើរ រត់ លោត ឬលើសពីនេះ ទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពមួយ។<br>• **បំណិនសម្បទា**<br>– អនុវត្តសកម្មភាពមួយបានទន់ភ្លន់ រហ័សរហួន និងរឹងមាំដោយការផ្ដើមចេញពីចលនាមូលដ្ឋានងាយៗ ទៅលំបាកចំនួនពីរឡើងទៅ ក្នុងនោះមានការដើរ រត់ លោត ឬលើសពីនេះ តាមរយៈចលនាចរន្ត ហាត់ប្រាណតាមរឿងនិទានបទចម្រៀង បទភ្លេង និងល្បែងចលនា។<br>• **ចរិយាសម្បទា**<br>– ក្លាហាន ជឿជាក់លើសមត្ថភាព និងកម្លាំងរបស់ខ្លួន ថាមានសុវត្ថិភាព ក្នុងពេលធ្វើសកម្មភាពឆ្លងកាត់ឧបសគ្គ។ | **១៤០ ម៉** |

## ២.១០.សសរស្តម្ភទាំងប្រាំនៃគុណភាពអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ចក្ខុវិស័យនៃកំណែទម្រង់វិស័យអប់រំនៅកម្ពុជា ដោយបានដាក់ចេញនូវសសរស្តម្ភទាំង ៥ នៃគុណភាពអប់រំ ដើម្បីលើកម្ពស់ការងារគ្រប់គ្រង និងរដ្ឋបាល កម្មវិធីសិក្សា ការទទួលស្គាល់គុណភាពអប់រំផងដែរ។ សសរស្តម្ភទាំង ៥ ដើម្បីគុណភាពអប់រំ រួមមានដូចខាងក្រោម ៖

សសរស្តម្ភទី១ ៖ ការអនុវត្តសកម្មភាពគោលនយោបាយគ្រូបង្រៀន

សសរស្តម្ភទី២ ៖ ការកែលម្អកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល

សសរស្តម្ភទី៣ ៖ ការធ្វើអធិការកិច្ច

សសរស្តម្ភទី៤ ៖ ការធ្វើវង្វាយតម្លៃសិក្សា និង

សសរស្តម្ភទី៥ ៖ ការទទួលស្គាល់គុណភាពអប់រំ

(ក្រសួងអប់រំយុវជននិងកីឡា, សន្និបាតអប់រំ, ២០១៥)

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១.ព័ត៌មានទូទៅពីគម្រោងស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានរៀបចំធ្វើឡើងដោយប្រើទិន្នន័យបរិមាណវិស័យ និងគុណវិស័យ បានយកមកវិភាគដើម្បីស្វែងយល់ពីស្ថានភាពដំណើរការនៃការអនុវត្តកម្មវិធីសិក្សា សម្រាប់មត្តេយ្យសិក្សារដ្ឋ និងសារៈសំខាន់នៃកម្មវិធីសិក្សាតាមរយៈ បុរេតេស្ត តេស្តបញ្ចប់ ដើម្បីវាស់សមត្ថភាពកុមារអាយុ ៥ឆ្នាំ ដែលជាគោលដៅនៃការស្រាវជ្រាវ។

## ៣.២.ទីកន្លែងសិក្សាស្រាវជ្រាវ

ជាទូទៅនៅសាលាមត្តេយ្យសិក្សារដ្ឋជាប់ដោយឡែក ជាសាលាគោលដៅ ដែលទទួលការបំប៉នស្តីពីកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ ប៉ុន្តែកន្លងមកមិនទាន់ឃើញមានរបាយការណ៍ណាមួយ ដែលបង្ហាញពីស្ថានភាពនៃការអនុវត្តកម្មវិធីនេះ បានច្បាស់លាស់នៅឡើយទេ ដែលភាគច្រើនមានតែលទ្ធផលនៃការចុះពិនិត្យតាមដានតែប៉ុណ្ណោះ។ ការសិក្សាស្រាវជ្រាវនេះ បានជ្រើសរើសយកខេត្តកណ្តាលជាទីតាំង ហើយក្នុងនោះរួមមានស្រុកចំនួន០៧ ត្រូវបានជ្រើសរើសចេញពីក្នុងខេត្តនេះរួមមាន ៖ ក្រុងតាខ្មៅ ស្រុកកៀនស្វាយ ស្រុកអង្គស្នួល ស្រុកល្វាឯម ស្រុកខ្សាច់កណ្តាល ស្រុកស្អាង និងស្រុកកោះធំ។ ការជ្រើសរើសខេត្តកណ្តាលមកសិក្សាស្រាវជ្រាវនេះ ត្រូវបានជ្រើសរើសដោយការកំណត់របស់អ្នកសិក្សាស្រាវជ្រាវ ចេញពីក្នុងចំណោមរាជធានី/ខេត្តទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើកត្តាពេលវេលា និងធនធានមានកំណត់។ ចំពោះស្រុកដែលបានជ្រើសរើស ក៏បានប្រើវិធីដូចគ្នាដែរ។ អ្នកសិក្សាស្រាវជ្រាវ នឹងធ្វើការជ្រើសរើសយកសាលានៅក្នុងខេត្តកណ្តាល ហើយជ្រើសរើសយកតែ ១៩សាលា ក្នុងចំណោមសាលារៀន ៣០ គោលដៅស្មើនឹង ៦៣% ស្រុកចំនួន ៧ នៃស្រុកទាំង១១ ស្មើនឹង៦៤% ក្នុងខេត្តកណ្តាល ដូចជា ក្រុងតាខ្មៅ៖ សាលាមត្តេយ្យសិក្សាធនធានក្រុងតាខ្មៅ និងសាលាមត្តេយ្យសិក្សាព្រែកសំរោង ស្រុកកៀនស្វាយ៖ សាលាមត្តេយ្យសិក្សាធនធានស្ពោកន្លែង សាលាមត្តេយ្យសិក្សាទួលត្នោត សាលាមត្តេយ្យសិក្សាជីឥដ្ឋ និងសាលាមត្តេយ្យសិក្សាសេរីសោភា ស្រុកអង្គស្នួល៖ សាលាមត្តេយ្យសិក្សាធនធានថ្នល់ទទឹង សាលាមត្តេយ្យសិក្សាស្មើកុមារ សាលាមត្តេយ្យសិក្សាស្មើកុមារអ៊ុកច័ន្ទ និងសាលាមត្តេយ្យសិក្សាព្រៃពួច ស្រុកល្វាឯម៖ សាលាមត្តេយ្យសិក្សាធនធានផ្លូវត្រី និងសាលាមត្តេយ្យសិក្សាខ្មែរអមតៈ ស្រុកខ្សាច់កណ្តាល៖ សាលាមត្តេយ្យសិក្សាធនធានព្រែកតាមាក់ សាលាមត្តេយ្យសិក្សាតាឯក សាលាមត្តេយ្យសិក្សាព្រះប្រសព្វ សាលាមត្តេយ្យសិក្សាព្រែកតាកូវ និងសាលាមត្តេយ្យសិក្សាវិហារសួគ៌ ស្រុកស្អាង៖ សាលាមត្តេយ្យសិក្សាធនធានព្រែកគយ និងស្រុកកោះធំ៖ សាលាមត្តេយ្យសិក្សាសម្តេចតាទួតយាយទួត។

## ៣.៣.ក្រុមគោលដៅ

ការសិក្សានេះ បានផ្តោតទៅលើគ្រូមត្តេយ្យសិក្សារដ្ឋ ដែលបង្រៀនថ្នាក់មត្តេយ្យកម្រិតខ្ពស់ ក្នុងសាលាមត្តេយ្យសិក្សាជាប់ដោយឡែក។ ចំពោះក្រុមគោលដៅ គឺគ្រូមត្តេយ្យសិក្សារដ្ឋដែលជាបុគ្គលិកបង្រៀនចំនួន ៣៧នាក់ នាយិកាសាលាមត្តេយ្យសិក្សា ចំនួន ១៩នាក់ មាតាបិតាកុមារចំនួន ២០នាក់ និងកុមារចំនួន ៣០៣នាក់ សរុបចំនួន ៣៧៩នាក់។

**តារាង ៣.៣.១ ក្រុមគោលដៅ និងអ្នកចូលរួម**

| ល.រ | ក្រុមគោលដៅ | ចំនួនអ្នកចូលរួម |
|---|---|---|
| ១ | នាយិកាសាលា | ១៩នាក់ |
| ២ | គ្រូមត្តេយ្យសិក្សារដ្ឋ | ៣៧នាក់ |
| ៣ | មាតាបិតាកុមារ | ២០នាក់ |
| ៤ | កុមារ | ៣០៣នាក់ |
| **សរុប** | | **៣៧៩នាក់** |

### ៣.៤.ទំហំសំណាក

ភាគសំណាកសម្រាប់ការសិក្សាស្រាវជ្រាវនេះរួមមាន គ្រូបង្រៀនដែលកំពុងបង្រៀននៅថ្នាក់មត្តេយ្យសិក្សាកម្រិតខ្ពស់ ចំនួន ៣៧នាក់ នាយិកាសាលាមត្តេយ្យសិក្សាចំនួន ១៩នាក់ មាតាបិតាកុមារចំនួន ២០នាក់ និងកុមារចំនួន ៣០៣នាក់ សរុបចំនួន ៣៧៩នាក់ ដែលមានទីតាំងស្ថិតនៅក្នុងក្រុង/ស្រុក ដែលបានជ្រើសរើសមកពីក្នុងចំណោមស្រុកទាំង១១ ក្នុងខេត្តកណ្ដាលប៉ុណ្ណោះ។ ការជ្រើសរើសនាយិកាសាលា គ្រូបង្រៀន គឺយក១០០% គ្រប់សាលាទាំងអស់ក្នុងស្រុកទាំង០៧ ចំណែកការជ្រើសរើសកុមារអាយុ ៥ឆ្នាំសម្រាប់ធ្វើតេស្តមកធ្វើជាភាគសំណាកត្រូវធ្វើឡើងដោយប្រើប្រាស់កម្មវិធី (www.openepi.com) ដែលមានទំហំសំណាកច្បាស់លាស់។ ចំពោះការជ្រើសរើសទំហំសំណាក Sample Size for Frequency in a Population (n) គឺប្រើតាមកម្មវិធីសមាមាត្រ (Propotion) ដោយមានការបង្ហាញពីកម្រិតនៃភាពជឿជាក់ (Confidence Levels) រហូតទៅដល់ ៩៥% និងមានកម្រិតលំអៀងត្រឹមតែ ៥% ប៉ុណ្ណោះ។ ដូចនេះ ក្នុងចំណោមកុមារអាយុ៥ឆ្នាំសរុប ដែលរៀននៅថ្នាក់មត្តេយ្យកម្រិតខ្ពស់ នៅក្នុងសាលាទាំង៣៧ មានចំនួនសរុប ១,៤១៧នាក់ (Population) ត្រូវជ្រើសរើសយកតែ ៣០៣នាក់ មកធ្វើជាទំហំសំណាក។ ចំពោះសំណាកដែលត្រូវបានជ្រើសរើសគឺធ្វើឡើងនៅក្នុងក្រុងតាខ្មៅ៖ សាលាមត្តេយ្យសិក្សាធនជានក្រុងតាខ្មៅ (៦០នាក់/២៨នាក់) ស្រុកកៀនស្វាយ៖ សាលាមត្តេយ្យសិក្សាធនជានស្ពោកន្លែង(១០នាក់/០៨នាក់) សាលាមត្តេយ្យសិក្សាទួលត្នោត(៣០នាក់/១៥នាក់) សាលាមត្តេយ្យសិក្សាដីឥដ្ឋ(៣០នាក់/១៤នាក់) ស្រុកអង្គស្នួល៖ សាលាមត្តេយ្យសិក្សាស្នើកុមារ(២០នាក់/១០នាក់) សាលាមត្តេយ្យសិក្សាស្នើកុមារអ៊ុកច័ន្ទ (១០នាក់/០៥នាក់) និងសាលាមត្តេយ្យសិក្សាព្រៃពួច(២០នាក់/១០នាក់) ស្រុកខ្សាច់កណ្ដាល៖ សាលាមត្តេយ្យសិក្សាធនជានព្រែកតាមាក់(២៥នាក់/១២នាក់) សាលាមត្តេយ្យសិក្សាព្រែកតាកូវ(៥៩នាក់/៣២នាក់) និងសាលាមត្តេយ្យសិក្សាវិហារសួគ៌(២០នាក់/០៧នាក់) និងស្រុកស្អាង៖ សាលាមត្តេយ្យសិក្សាធនជានព្រែកគយ(២៩នាក់/១៧នាក់)។ ចំនួននាយិកា គ្រូមត្តេយ្យសិក្សា កុមារខាងលើ គឺស្ថិតក្នុងឆ្នាំសិក្សា ២០១៨-២០១៩។ ហើយការជ្រើសរើសសំណាកសម្រាប់ការសិក្សានេះ គឺអាចឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សា ព្រោះការសិក្សាស្រាវជ្រាវនេះ បានធ្វើការជ្រើសរើសយកតែគ្រូដែលកំពុងបង្រៀន នៅ

សាលាមត្តេយ្យសិក្សារដ្ឋ សម្រាប់ថ្នាក់កម្រិតខ្ពស់ទាំងអស់ ដោយមិនគិតលើគ្រូមត្តេយ្យសិក្សាថ្នាក់កម្រិតទាប និងមធ្យម នោះទេ។

**តារាង ៣.៤.១ ចំនួនកុមារអាយុ៥ឆ្នាំនៅតាមសាលាគោលដៅ (ថ្នាក់កម្រិតខ្ពស់)**

| ល.រ | ឈ្មោះសាលា | ចំនួនកុមារ | ចំនួនគិតជា(%) | ចំ.សំណាកតាមសាលា |
|---|---|---|---|---|
| ១ | ម.ត ធនធានក្រុងតាខ្មៅ | ១៥២ | ១១% | ៦០ |
| ២ | ម.ត ព្រែកសំរោង | ១៣១ | ៩% | ០ |
| ៣ | ម.ត ធនធាន ស្ពោកន្លែង | ១០៩ | ៨% | ១០ |
| ៤ | ម.ត ទួលត្នោត | ១១២ | ៨% | ៣០ |
| ៥ | ម.ត ដីឥដ្ឋ | ១១០ | ៨% | ៣០ |
| ៦ | ម.ត សេរីសោភា | ៤៥ | ៣% | ០ |
| ៧ | ម.ត ធនធានថ្នល់ទទឹង | ៦០ | ៤% | ០ |
| ៨ | ម.ត រស្មីកុមារ | ៥៥ | ៤% | ២០ |
| ៩ | ម.ត រស្មីកុមារអ៊ុកច័ន្ទ | ១៣ | ១% | ១០ |
| ១០ | ម.ត ព្រៃពួច | ៥១ | ៤% | ២០ |
| ១១ | ម.ត ធនធានព្រែកតាមាក់ | ១១២ | ៨% | ២៥ |
| ១២ | ម.ត ព្រែកតាកូវ | ១២១ | ៩% | ៥៩ |
| ១៣ | ម.ត វិហារសួគ៌ | ៤៩ | ៣% | ២០ |
| ១៤ | ម.ត តាឯក | ៦០ | ៤% | ០ |
| ១៥ | ម.ត ព្រះប្រសប់ | ៤៧ | ៣% | ០ |
| ១៦ | ម.ត ធនធាន ព្រែកគយ | ៧៤ | ៥% | ២៩ |
| ១៧ | ម.ត ស.តាទួតយាយទួត | ៤១ | ៣% | ០ |
| ១៨ | ម.ត ធនធានផ្លូវត្រី | ៥០ | ៣% | ០ |
| ១៩ | ម.ត ខ្មែរអមតៈ | ២៥ | ២% | ០ |
| | **សរុប** | **១ ៤១៧** | **១០០%** | **៣០៣** |

## ៣.៥.ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវដែលត្រូវយកមកប្រើក្នុងការប្រមូលទិន្នន័យមានកម្រងសំណួរ ដែលមានលក្ខណៈកម្រិតចម្លើយ(ទម្រង់បិទ) និងកម្រងសំណួរទម្រង់បើក។ ដើម្បីប្រមូលទិន្នន័យនេះបាន ត្រូវមានកម្រងសំណួរសម្រាប់គ្រូបង្រៀន កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា កម្រងសំណួរសម្រាប់មាតាបិតា និងតេស្តសម្រាប់កុមារអាយុ៥ឆ្នាំ។ ក្នុងការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានរៀបចំកម្រងសំណួរជាបួន(៤) ប្រភេទដែលក្នុងនោះរួមមាន (១)កម្រងសំណួរសម្រាប់សម្ភាសន៍គ្រូមត្តេយ្យសិក្សា មានចំនួន ៣៧ច្បាប់ (២)កម្រងសំណួរសម្រាប់សម្ភាសន៍នាយិកាសាលាមត្តេយ្យ មានចំនួន១៩ច្បាប់ (៣)កម្រងសំណួរសម្រាប់សម្ភាសន៍មាតាបិតាកុមារ មានចំនួន២០ច្បាប់ និង(៤)កម្រងសំណួរតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ មានចំនួន៣០៣ច្បាប់។ មុនពេលផ្តល់កម្រងសំណួរទាំងនេះ ដល់អ្នកចូលរួមផ្តល់ព័ត៌មានជាដំបូង គឺបានធ្វើការទំនាក់ទំនងជាមួយមន្ត្រីនៅមន្ទីរ ថ្នាក់ក្រុង ស្រុក និងក្រោយមកបានធ្វើការទំនាក់ទំនង

ជួបផ្ទាល់ជាមួយនាយិកាសាលា និងគ្រូមត្តេយ្យសិក្សា ដើម្បីឱ្យមានភាពងាយស្រួលក្នុងការបំពេញកម្រងសំណួរ។

### ៣.៥.១.កម្រងសំណួរសម្រាប់នាយិកាសាលា

កម្រងសំណួរសម្រាប់នាយិកាសាលា មានគោលបំណងស្វែងយល់អំពីដំណើរការនៃការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ ភាពងាយស្រួល បញ្ហាប្រឈម និងសំណូមពរពាក់ព័ន្ធនឹងការងារនេះ សរុបមានចំនួន ៤សំណួរ ជាប្រភេទសំណួរបើក។ ដោយសារតែពេលវេលាមានកំណត់ ដូច្នេះ រយៈពេលនៃការសម្ភាសជាមធ្យមពី ២០នាទី ទៅ ៣០នាទី នៅតាមសាលារៀននីមួយៗ រវាងអ្នកស្រាវជ្រាវ និងអ្នកផ្តល់ព័ត៌មាន ដោយទទួលបានការអនុញ្ញាតពីប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកផងដែរ។

### ៣.៥.២.កម្រងសំណួរសម្រាប់គ្រូបង្រៀន

កម្រងសំណួរសម្រាប់គ្រូបង្រៀន មានគោលបំណងសិក្សាពីស្ថានភាពនៃដំណើរការអនុវត្តកម្មវិធីសិក្សាលម្អិតរបស់គ្រូមត្តេយ្យសិក្សា។ កម្រងសំណួរនេះចែកចេញជាពីរផ្នែកគឺ៖ ផ្នែកទី១ ស្តីពីព័ត៌មានផ្ទាល់ខ្លួនរបស់គ្រូមត្តេយ្យសិក្សា និងផ្នែកទី២ ស្តីពីការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ។ នៅក្នុងកម្រងសំណួរនេះ មានសំណួរទម្រង់បិទ និងទម្រង់បើក ដោយបានទទួលការអនុញ្ញាតពីសាមីខ្លួន និងនាយិកាសាលាផងដែរ។

### ៣.៥.៣.កម្រងសំណួរសម្រាប់មាតាបិតា

កម្រងសំណួរសម្រាប់មាតាបិតា មានគោលបំណងសិក្សានូវការយល់ឃើញលើកម្មវិធីមត្តេយ្យសិក្សាពិសេសការប្រែប្រួលឥរិយាបថរបស់កុមារមុន និងក្រោយពេលរៀនសូត្រ សរុបមានចំនួន ៦សំណួរ ជាប្រភេទសំណួរបើក។ ដោយសារតែពេលវេលាមានកំណត់ ដូច្នេះ រយៈពេលនៃការសម្ភាសជាមធ្យមពី ២០នាទី ទៅ ៣០នាទី ដោយបានទទួលការអនុញ្ញាតពីសាមីខ្លួន កិច្ចសហការពីនាយិកាសាលា និងគ្រូមត្តេយ្យសិក្សាផងដែរ។

### ៣.៥.៤.កម្រងសំណួរតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ

កម្រងសំណួរតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ មានគោលបំណងរកឱ្យឃើញនូវលទ្ធផលសិក្សារបស់កុមារជាផ្លូវការ លទ្ធផលនៃការប្រែប្រួល និងការអភិវឌ្ឍរបស់កុមារទៅតាមគោលដៅសិក្សាដែលបានកំណត់ក្នុងកម្មវិធីសិក្សាលម្អិត។ កម្រងសំណួរនេះ ចែកចេញជាពីរផ្នែកគឺ៖ ផ្នែកទី១ ស្តីពីព័ត៌មានផ្ទាល់ខ្លួនរបស់កុមារ និងផ្នែកទី២ ស្តីពីការអនុវត្តតេស្តវាស់សមត្ថភាពកុមារ។ នៅក្នុងកម្រងសំណួរតេស្តនេះ មានសំណួរទម្រង់បិទ ទម្រង់បើក និងការអនុវត្តផ្ទាល់របស់កុមារ ដោយបានទទួលការអនុញ្ញាតពីមាតាបិតាកុមារ សាមីខ្លួន នាយិកាសាលា និងគ្រូបន្ទុកថ្នាក់ផងដែរ។ ការអនុវត្តតេស្តត្រូវបានធ្វើឡើងជាលក្ខណៈដៃគូតទល់រវាងកុមារ និងអ្នកប្រមូលទិន្នន័យ(គ្រូមត្តេយ្យសិក្សា) ចែកចេញជា៥វិស័យ មាន២០កម្រងសំណួរ ក្នុងនោះមាន៖ វិស័យទី១ ការអភិវឌ្ឍផ្នែកសុខភាពនិងរាងកាយ មានសំណួរសរុបចំនួន៦ វិស័យទី២ ការអភិវឌ្ឍផ្នែកសីលធម៌និងវប្បធម៌ មានសំណួរសរុបចំនួន៣ វិស័យទី៣ ការអភិវឌ្ឍផ្នែកសង្គមនិងអារម្មណ៍ មានសំណួរសរុបចំនួន២ វិស័យទី៤ ការអភិវឌ្ឍផ្នែកការយល់ដឹងនិងការពិចារណា មានសំណួរសរុបចំនួន៥ និងវិស័យទី៥ ការអភិវឌ្ឍផ្នែកភាសា មានសំណួរសរុបចំនួន៤។ កម្រងសំណួរតេស្ត ត្រូវបានដកស្រង់ចេញពីប្រព័ន្ធ

ពិនិត្យតាមដាននិងវាយតម្លៃ នៃនាយកដ្ឋានអប់រំកុមារតូច ក្រសួងអប់រំ យុវជន និងកីឡា។ (ក្រសួងអប់រំយុវជននិងកីឡា, ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃនាយកដ្ឋានអប់រំកុមារតូច, ២០១៦)

**តារាង 1 ៖ បញ្ជីកម្រងសំណួរទាំង២០សម្រាប់អនុវត្តតេស្តជាមួយកុមារអាយុ៥ឆ្នាំ**

| លេខសំណួរ | ខ្លឹមសារតេស្ត |
|---|---|
| Q1 | បោះបាល់ចំនួនបីដង ដោយដៃទាំងពីរ ឬដៃម្ខាងចូលក្នុងផ្ទាំងក្រដាសរាងការេនៅលើដី ចម្ងាយ ៣ម៉ែត្រ |
| Q2 | គូសតាមរាងធរណីមាត្រ រង្វង់ ការេ ចតុកោណកែង និងត្រីកោណ |
| Q3 | ធ្វើចំណាត់ថ្នាក់អាហារជាបីក្រុម |
| Q4 | ប្រាប់ពីផលប្រយោជន៍នៃការញ៉ាំអាហារ បន្លែ និង ផ្លែឈើ |
| Q5 | ប្រាប់ពីសារៈសំខាន់នៃការធ្វើអនាម័យប្រចាំថ្ងៃ |
| Q6 | ប្រាប់ពីវត្ថុ និងសម្ភារៈ ដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ |
| Q7 | ប្រាប់ពីការគោរពចំពោះមនុស្សចាស់ |
| Q8 | ប្រាប់ពីឈ្មោះសំលៀកបំពាក់ខ្មែរ និងការប្រើប្រាស់ |
| Q9 | ច្រៀងចម្រៀងគោរពទង់ជាតិ |
| Q10 | ពន្យល់នូវលទ្ធផលសកម្មភាពរបស់ខ្លួនចំពោះអ្នកដទៃ(ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់) |
| Q11 | បង្ហាញពីអារម្មណ៍តាមរយៈពាក្យសម្ដី និងទឹកមុខ រួចប្រាប់អំពីមូលហេតុដែលធ្វើឱ្យគេសប្បាយចិត្ត ពិបាកចិត្ត និងយំ |
| Q12 | បង្ហាញពីការធ្វើចលនាតាមរូបតំណាងវត្ថុ ឬសត្វ អ្វីមួយ |
| Q13 | ធ្វើប្រមាណវិធីដករបស់ជាក់ស្ដែងពីចំនួនរួម និងរាប់ចំនួននៅសល់ |
| Q14 | ប្រៀបធៀបធំនិងតូច វែងនិងខ្លី ខ្ពស់និងទាប ធ្ងន់និងស្រាល |
| Q15 | ប្រាប់អំពីភាពខុសគ្នារវាងរាង និងពណ៌ ការស្ដាប់សំឡេងរបស់វត្ថុ ក្លិន និងរសជាតិ ឈ្មោះវត្ថុតាមការស្ទាបទ្រង់ទ្រាយ |
| Q16 | គូររូបភាពតាមចំណង់ដោយផាត់ពណ៌លើរូបភាព និងពន្យល់ប្រាប់អំពីរូបដែលបានគូរ |
| Q17 | ធ្វើតាមការណែនាំដែលមាន ៤ដំណាក់កាល |
| Q18 | រៀបរាប់រឿងដោយប្រើពាក្យសម្ដីរបស់កុមារផ្ទាល់ |
| Q19 | ស្គាល់តួព្យញ្ជនៈ និងប្រាប់បានពីសូររបស់ព្យញ្ជនៈយ៉ាងតិច៥តួ |
| Q20 | បង្ហាញពីរបៀបកាន់ និងបើកសៀវភៅរឿងមើលតាមលំដាប់លំដោយ និងត្រឹមត្រូវតាំងពីដើមទំព័ររហូតដល់ចប់ទំព័រ |

## ៣.៦.វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ បានប្រើវិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យក្នុងការប្រមូលទិន្នន័យ។ របៀបប្រមូលទិន្នន័យសម្រាប់បរិមាណវិស័យគឺ ធ្វើការសម្ភាសម្នាក់ទល់នឹងម្នាក់ជាមួយគ្រូបង្រៀន ប្រើតារាងសំណួរ(Questionnaire) និងធ្វើតេស្តកុមារម្នាក់ទល់នឹងម្នាក់ និងការប្រមូលទិន្នន័យសម្រាប់គុណវិស័យគឺ

ធ្វើការសម្ភាសម្នាក់ទល់នឹងម្នាក់ជាមួយនាយិកាសាលារៀនគោលដៅ និងមាតាបិតាកុមារ ដែលបានរៀបចំទុកជាមុន ស្របតាមគោលបំណងនៃការស្រាវជ្រាវ។ តារាងសំណួរត្រូវបានរៀបចំឡើងដោយបញ្ចូលព័ត៌មានដែលត្រូវសួរដូចជា ផ្នែកទី១ស្ដីពីព័ត៌មានផ្ទាល់ខ្លួន ផ្នែកទី២ ស្ដីពីការងារប្រតិបត្តិ និងលទ្ធផលតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ។ ព័ត៌មានទាំងនេះត្រូវបានសាកសួរឆ្លើយតបទៅនឹងគោលបំណងដែលចង់ដឹងនូវស្ថានភាពនៃការអនុវត្តកម្មវិធីសិក្សា សម្រាប់មត្តេយ្យសិក្សារដ្ឋ នាពេលបច្ចុប្បន្ន មានដំណើរការយ៉ាងដូចម្ដេច និងមានភាពវិជ្ជមាន ក៏ដូចជាបញ្ហាប្រឈមយ៉ាងដូចម្ដេចខ្លះ និងសារៈប្រយោជន៍នៃកម្មវិធីសិក្សា។

## ៣.៧.ដំណើរការក្នុងការប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងដោយបានធ្វើការទំនាក់ទំនងសុំការអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្ដាល ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក ព្រមទាំងគ្រឹះស្ថានសិក្សាគោលដៅ។ ជាដំបូងអ្នកសិក្សាស្រាវជ្រាវបានចុះជួបជាមួយនឹងមន្ត្រីនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីសុំការអនុញ្ញាតសាកសួរព័ត៌មានបន្ថែមអំពីទីតាំង ដែលបានកំណត់ទុកសម្រាប់ធ្វើការស្រាវជ្រាវនេះ។ បន្ទាប់ពីបានកំណត់ទីតាំងសម្រាប់ធ្វើការសិក្សាស្រាវជ្រាវហើយ អ្នកសិក្សាស្រាវជ្រាវបានសុំជួបជាមួយនឹងប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក មន្ត្រីទទួលបន្ទុកការងារអប់រំកុមារតូចថ្នាក់ក្រុង/ស្រុក ដើម្បីសុំការអនុញ្ញាតចុះទៅដល់សាលាដែលបានកំណត់។ ក្រោយមកអ្នកសិក្សាបានជួបជាមួយនឹងនាយិកាសាលា គ្រូមត្តេយ្យសិក្សានៅតាមសាលានានា ដើម្បីជម្រាបពួកគាត់អំពីគោលបំណងនៃការចុះធ្វើការសិក្សាស្រាវជ្រាវនេះ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំនាយិកាសាលា និងគ្រូមត្តេយ្យសិក្សា ជួយសម្រួលក្នុងដំណើរការនេះ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវបានធ្វើការសម្ភាសនាយិកាសាលា គ្រូមត្តេយ្យសិក្សា និងមាតាបិតាកុមារ។ ក្រោយពីបានបំពេញរួចរាល់អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកកម្រងសំណួរនាយិកា គ្រូមត្តេយ្យសិក្សា និងមាតាបិតាកុមារ ដើម្បីយកមកវិភាគ។ ក្នុងនោះផងដែរអ្នកសិក្សាស្រាវជ្រាវបានចូលរួមធ្វើតេស្តជាមួយកុមារអាយុ៥ឆ្នាំផ្ទាល់(ភាគសំណាក) និងប្រមូលទិន្នន័យបុរេតេស្ត និងតេស្តបញ្ចប់ ពីគ្រូមត្តេយ្យសិក្សា ដើម្បីធ្វើការវិភាគផងដែរ។ ការសិក្សាស្រាវជ្រាវនេះ បានចុះទៅសិក្សាតាមទីកន្លែង ដែលបានកំណត់ជ្រើសរើសដោយបានប្រើរយៈពេលប្រហែលដប់ពីរ(១២)សប្ដាហ៍ នៃថ្ងៃបង្រៀននៅតាមសាលាដោយគិតចាប់ពីថ្ងៃទី០២ ខែឧសភា ដល់ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩។

## ៣.៨.ការវិភាគទិន្នន័យ

ដោយផ្អែកលើចម្លើយដែលបានមកពីការបំពេញកម្រងសំណួរ បូករួមទាំងព័ត៌មានដែលបានមកពីការសម្ភាសជាមួយនាយិកាសាលា គ្រូមត្តេយ្យសិក្សា និងការធ្វើតេស្តជាមួយកុមារអាយុ៥ឆ្នាំ តាមសាលានីមួយៗ ការវិភាគនេះគឺបានធ្វើឡើងដោយប្រើវិធីសាស្ត្របែបវិភាគតាមទិន្នន័យបរិមាណវិស័យ។ ការសិក្សានេះ បានអនុវត្តការវិភាគតាមបែបស្ថិតិមានដូចជា ការវិភាគបែបពណ៌នាតាមរយៈការសង់ក្រាហ្វិកដើម្បីផ្ដុំទិន្នន័យ ដើម្បីរកឃើញពីប្រសិទ្ធភាព និងស្ថានភាពនៃការអនុវត្តកម្មវិធីសិក្សា ការវិភាគបែបប្រៀបធៀបមធ្យមនៃពិន្ទុកុមារ និងសារៈប្រយោជន៍នៃកម្មវិធីសិក្សានៅតាមស្រុក សាលានានា ក្នុងពេលបច្ចុប្បន្ននេះ ដោយប្រើប្រាស់កម្មវិធី អេស ភី អេស អេស (SPSS. Version 23) និងកម្មវិធី Microsoft Excel 2010។

### ៣.៩.ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ

ដើម្បីរក្សាក្រមសីលធម៌ក្នុងការសិក្សាស្រាវ យើងបានធ្វើការណែនាំខ្លួន និងប្រាប់ពីគោលបំណង រយៈពេលសុំសម្ភាសន៍ ការសន្យាលើលក្ខខណ្ឌមួយចំនួនដូចជា រក្សាការសម្ងាត់ជូនគាត់ ព័ត៌មានដែលទទួលបានមិនត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀតឡើយ ហើយសម្រាប់ការសម្ភាសត្រូវបានសុំការអនុញ្ញាត និងមានការឯកភាពពីអ្នកត្រូវសម្ភាសន៍ផងដែរ។ ក្នុងដំណើរការសម្ភាស គឺបានជ្រើសរើសកន្លែងដែលមិនមានការរំខានពីមជ្ឈដ្ឋានខាងក្រៅ។ អ្នកសម្ភាសបានរៀបចំខ្លួនដោយមានសម្លៀកបំពាក់សមរម្យ ទឹកមុខស្រស់ស្រាយ ញញឹមរួសរាយ នឹងបង្ហាញនូវភាពស្និទ្ធស្នាល ប្រើកាយវិការទន់ភ្លន់ និងអង្គុយតាមបែបបទគោលការណ៍អ្នកសម្ភាស ជាពិសេសអ្នកសិក្សាស្រាវជ្រាវមិនធ្វើការផ្តល់យោបល់ ឬអនុសាសន៍ផ្សេងៗ ដល់អ្នកត្រូវសម្ភាសជាដាច់ខាត។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៤
# លទ្ធផលនិងការពិភាក្សា

## ៤.១.ស្ថានភាពសង្គមប្រជាសាស្ត្រ

### ៤.១.១.កម្រិតវប្បធម៌

ក្រាហ្វិក 1 ៖ កម្រិតវប្បធម៌គ្រូបង្រៀន




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

គុណវុឌ្ឍិពិតជាមាសារៈសំខាន់ណាស់សម្រាប់គ្រូបង្រៀន ដើម្បីឱ្យការបង្រៀនមានភាពច្បាស់លាស់ និងប្រកបដោយគុណភាព។ គ្រូបង្រៀនត្រូវតែមានគុណវុឌ្ឍិគ្រប់គ្រាន់ទាំងចំណេះដឹងឯកទេស និងចំណេះដឹងទូទៅ ផ្ទុយទៅវិញប្រសិនបើគុណវុឌ្ឍិរបស់គ្រូបង្រៀននៅមានកម្រិត នោះអាចនឹងធ្វើឱ្យប៉ះពាល់ដល់ការបង្រៀន និងការផ្ទេរចំណេះដឹងដល់សិស្សានុសិស្សជាក់ជាមិនខាន។ តាមរយៈក្រាហ្វិកខាងលើនេះបង្ហាញថា គ្រូបង្រៀនដែលកំពុងបង្រៀននៅសាលាមត្តេយ្យសិក្សា មានសញ្ញាបត្របឋមភូមិមានចំនួន ១៦% សញ្ញាបត្រទុតិយភូមិចំនួន ៧០% និងសញ្ញាបត្របរិញ្ញាបត្រចំនួន១៤%។ កម្រិតវប្បធម៌របស់គ្រូបង្រៀនមួយចំនួននៅមានកម្រិតទាបនៅឡើយ ហើយកម្រិតខ្ពស់ក៏នៅមានកម្រិតទាបដដែល ជាហេតុធ្វើឱ្យការយល់ដឹង និងការផ្ទេរចំណេះដឹងដល់សិស្សជំនាន់ក្រោយមិនទាន់បានល្អសមស្របទៅ នឹងភាពរីកចម្រើននៃសកលលោកបច្ចុប្បន្ន។ ដូច្នេះ គ្រូមត្តេយ្យសិក្សាគួរបង្កើនគុណវុឌ្ឍិរបស់ខ្លួនឱ្យបានខ្ពស់ជាងនេះទៀត ដើម្បីឱ្យការបង្រៀនរបស់គាត់កាន់តែល្អប្រសើរជាងមុន។

#### ៤.១.២.កម្រិតវិជ្ជាជីវៈ

ក្រាហ្វិក 2 ៖ កម្រិតវិជ្ជាជីវៈគ្រូបង្រៀន




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

តាមរយៈលទ្ធផលដែលបង្ហាញក្នុងក្រាហ្វិកទី២ បានបង្ហាញថា ក្នុងចំណោមគ្រូបង្រៀនសរុបចំនួន ១៩នាក់ មានគ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន ៨% និងគ្រូជំនាញមត្តេយ្យសិក្សាចំនួន ៩២%។ គ្រូក្របខណ្ឌមត្តេយ្យសិក្សាទាំងអស់ បានធ្វើបច្ចុប្បន្នភាពទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋានបានតិចតួចប៉ុណ្ណោះ គួរតែជំរុញឱ្យគ្រូមត្តេយ្យដែលសេសសល់បន្ថែមទៀត ដើម្បីពង្រីកចំណេះដឹងគាត់ទូលំទូលាយ និងស្វែងយល់ពីបច្ចេកទេស វិធីសាស្ត្របង្រៀនឱ្យបាន ច្រើនជាងនេះទៀត។

### ៤.២.ការអនុវត្តការងាររបស់បុគ្គលិកអប់រំ

#### ៤.២.១.បទពិសោធការងារ

ក្រាហ្វិក 3 ៖ រយៈពេលបម្រើការងារក្នុងវិស័យអប់រំ



ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

បទពិសោធការងារ គឺជាផ្នែកមួយដ៏សំខាន់ សម្រាប់ការសម្រេចបាននូវលទ្ធផលប្រកបដោយភាពជោគជ័យ។ សម្រាប់មន្ត្រីអប់រំ បទពិសោធពិតជាចាំបាច់ព្រោះការងារជាគ្រូបង្រៀន ត្រូវតែមានភាពប៉ិនប្រសប់ និងច្នៃប្រឌិត ដើម្បីទាក់ទាញនូវចំណាប់អារម្មណ៍កុមារឱ្យចាប់អារម្មណ៍លើវត្ថុបំណងនៃមេរៀន។ នៅពេលដែលគ្រូបង្រៀនមានបទពិសោធការងារកាន់តែយូរឆ្នាំ ការបង្រៀន ការផ្ទេរនូវចំណេះដឹងដល់កុមារ និងល្បិចក្នុងការរៀបចំប្លង់មេរៀន សកម្មភាពក្នុងថ្នាក់រៀន ប្រាកដជាមានភាពល្អប្រសើរជាក់ជាមិនខាន។

តាមរយៈក្រាហ្វិកទី៣ នេះបានបង្ហាញថា គ្រូបង្រៀននៅតាមសាលាគោលដៅភាគច្រើនសុទ្ធតែមានបទពិសោធការងារយូរឆ្នាំ ក្នុងនោះក៏មានគ្រូមួយចំនួនតូចប៉ុណ្ណោះ ដែលមានបទពិសោធក្រោម១០ឆ្នាំ ដែលពួកគាត់សុទ្ធតែជាគ្រូបង្រៀនទើបតែចេញបម្រើការងារ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់តាមដានលើការបង្រៀនរបស់គាត់ពីសំណាក់នាយក នាយិកាសាលា និងប្រធានក្រុមបច្ចេកទេស ដើម្បីពង្រឹងសមត្ថភាពរបស់គាត់បន្ថែមទៀត ជាពិសេស ត្រូវបង្កលក្ខណៈឱ្យគាត់បានចូលមើលម៉ោងបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ដែលមានបទពិសោធបង្រៀនយូរឆ្នាំ ដើម្បីទទួលបាននូវវិធីសាស្ត្របង្រៀន និងការគ្រប់គ្រងថ្នាក់ជាដើម។

### ៤.២.២.ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ

**ក្រាហ្វិក 4 ៖ ការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ**




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋទើបតែបានអនុវត្តរយៈពេល ០១ឆ្នាំ តែប៉ុណ្ណោះក្រោយពីបានទទួលការបំប៉នពីថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា។ តាមរយៈក្រាហ្វិចទី៤ បានបង្ហាញថាការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋបាន ៩៧% និងមិនបានអនុវត្តតែ ០៣% ដោយសារគ្រូមត្តេយ្យសិក្សា ០១នាក់ លំហែមាតុភាពមិនបានបង្រៀន។ បើកម្មវិធីសិក្សាអនុវត្តបានពេញលេញ នោះនឹងជួយឱ្យកុមារសម្រេចបាននូវគោលដៅរួមនៃការសិក្សាគឺ ការត្រិះរិះពិចារណា និងដោះស្រាយបញ្ហាចិត្តចលភាព វិទ្យាសាស្ត្រ សិក្សាសង្គម បុរេគណិត និងភាសាខ្មែរ ប្រកបដោយគុណភាព ដើម្បីកុមារត្រៀមខ្លួនជាស្រេចចូលរៀននៅកម្រិតបឋមសិក្សា។ (ក្រសួងអប់រំយុវជននិងកីឡា, កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ, ២០១៨)

### ៤.២.៣.ការរៀបចំបំណែងចែកកម្មវិធីសិក្សាលម្អិត និងផែនការបង្រៀន

ក្រាហ្វិក 5 ៖ ការរៀបចំបំណែងចែកកម្មវិធីសិក្សាលម្អិត




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

ការរៀបចំបំណែងចែកកម្មវិធីសិក្សាលម្អិតប្រចាំឆ្នាំ ខែ សប្តាហ៍ និងផែនការបង្រៀនប្រចាំថ្ងៃ ត្រូវបានរៀបចំឡើងដោយពឹងផ្អែកទៅលើលទ្ធផលរំពឹងទុកនៃមុខវិជ្ជាទាំង៥ មុខវិជ្ជាចិត្តចលភាព វិទ្យាសាស្ត្រ សិក្សាសង្គម បុរេគណិត និងមុខវិជ្ជាភាសាខ្មែរ ក្នុងសៀវភៅកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋឆ្នាំ ២០១៨ ប្រតិទិនប្រចាំឆ្នាំ ប្រតិទិនឈប់សម្រាកប្រចាំឆ្នាំរបស់មន្ត្រីរាជការ សេចក្តីណែនាំគ្រឹះស្ថានបឋមនិងមត្តេយ្យសិក្សាសាធារណៈ ខ្លឹមសារតេស្តវាស់សមត្ថភាពទៀងទាត់កុមារអាយុ៥ឆ្នាំ សៀវភៅសិក្សាគោល ឯកសារពាក់ព័ន្ធផ្សេងៗដែលទទួលបានពីវគ្គបំប៉ន/សិក្ខាសាលានានា ដើម្បីសិក្សាស្រាវជ្រាវ និងងាយស្រួលក្នុងការជ្រើសរើស កំណត់ចំនួនមេរៀន ចំណងជើងមេរៀន ក្នុងការរៀបចំបំណែងចែកកម្មវិធីសិក្សាលម្អិតប្រចាំឆ្នាំ ខែ សប្តាហ៍ និងផែនការបង្រៀនប្រចាំថ្ងៃ។

តាមរយៈក្រាហ្វិកទី៥ បានបង្ហាញថាគ្រូមត្តេយ្យសិក្សាបានរៀបចំបំណែងចែកកម្មវិធីសិក្សាលម្អិតប្រចាំឆ្នាំ ៩៥% បំណែងចែកកម្មវិធីសិក្សាលម្អិតប្រចាំខែ ៨៤% បំណែងចែកកម្មវិធីសិក្សាលម្អិតប្រចាំសប្តាហ៍ ៧៨% និងផែនការបង្រៀនប្រចាំថ្ងៃ ៧០%។ ការរៀបចំបំណែងចែកកម្មវិធីសិក្សាលម្អិត និងផែនការបង្រៀនប្រចាំថ្ងៃ មិនបានពេញលេញចន្លោះ ៥% ទៅ ៣០% មិនទាន់ឆ្លើយតបទៅនឹងកម្មវិធីសិក្សាថ្មី ជាហេតុធ្វើឱ្យដំណើរការបង្រៀននៅមិនទាន់មានភាពរលូន។ តាមរយៈចម្លើយក្នុងកម្រងសំណួរសម្ភាសន៍គ្រូបង្រៀនបានបញ្ជាក់ពីសាលាមត្តេយ្យមួយចំនួន ត្រូវធ្វើបច្ចុប្បន្នភាពឡើងវិញ ពីការរៀបចំបំណែងចែកកម្មវិធីសិក្សាលម្អិត ចំណែកការរៀបចំផែនការបង្រៀនប្រចាំថ្ងៃនៅមិនទាន់បានទៀងទាត់ ដោយសារគ្រូ

មត្តេយ្យសិក្សាត្រូវធ្វើការស្រាវជ្រាវរកសម្ភារឧបទេសថ្មីៗ បន្ថែមទៀត ជាពិសេសគ្រូមត្តេយ្យសិក្សានៅមានភាពមិនច្បាស់លាស់ពីលទ្ធផលរំពឹងទុកមួយចំនួនក្នុងសៀវភៅកម្មវិធីសិក្សា។ ដូចនេះ ដើម្បីឱ្យការធ្វើផែនការបង្រៀនបានច្បាស់លាស់និងទៀងទាត់ សាលានីមួយៗ គួរតែរៀបចំកិច្ចការទាំងនោះ តាមរយៈការប្រជុំបច្ចេកទេសទៀងទាត់រៀងរាល់សប្តាហ៍ ក្នុងការបន្តនិរន្តរភាពការអនុវត្តកម្មវិធីសិក្សាមានគុណភាព។

### ៤.២.៤.របាយម៉ោងសិក្សា

**ក្រាហ្វិក 6 ៖ របាយម៉ោងសិក្សាតាមមុខវិជ្ជាប្រចាំឆ្នាំ**




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋមាន ៥មុខវិជ្ជាគឺ ចិត្តចលភាព វិទ្យាសាស្ត្រ សិក្សាសង្គម បុរេគណិត និងភាសាខ្មែរ។ មុខវិជ្ជាចិត្តចលភាពមាន ៦ម៉ោងសិក្សា ក្នុងមួយសប្តាហ៍ ម៉ោងសិក្សាសរុបប្រចាំឆ្នាំគឺ ៣៥ គុណនឹង ៦ ស្មើ ២១០ម៉ោងសិក្សា(២០%) មុខវិជ្ជាវិទ្យាសាស្ត្រមាន ៣ម៉ោងសិក្សា ក្នុងមួយសប្តាហ៍ ម៉ោងសិក្សាសរុបប្រចាំឆ្នាំគឺ ៣៥ គុណនឹង ៣ ស្មើ ១០៥ម៉ោងសិក្សា(១០%) មុខវិជ្ជាសិក្សាសង្គមមាន ១៤ ម៉ោងសិក្សា ក្នុងមួយសប្តាហ៍ ម៉ោងសិក្សាសរុបប្រចាំឆ្នាំគឺ ៣៥ គុណនឹង ១៤ ស្មើ ៤៩០ម៉ោងសិក្សា(៤៧%) មុខវិជ្ជាបុរេគណិតមាន ៣ម៉ោងសិក្សា ក្នុងមួយសប្តាហ៍ ម៉ោងសិក្សាសរុបប្រចាំឆ្នាំគឺ ៣៥ គុណនឹង ៣ ស្មើ ១០៥ម៉ោងសិក្សា(១០%) និងមុខវិជ្ជាភាសាខ្មែរមាន ៤ម៉ោងសិក្សា ក្នុងមួយសប្តាហ៍ ម៉ោងសិក្សាសរុបប្រចាំឆ្នាំគឺ ៣៥ គុណនឹង ៤ ស្មើ ១៤០ម៉ោងសិក្សា(១៣%)។

តាមរយៈក្រាហ្វិកទី៦ បានបង្ហាញថា របាយម៉ោងសរុបប្រចាំឆ្នាំមុខវិជ្ជាចិត្តចលភាព មានភាពសមស្រប ៧៣% បុរេគណិត ៩៧% ភាសាខ្មែរ១០០% វិទ្យាស្រាស្ត្រ ៩៥% និងសិក្សាសង្គម ៧៣%។ ចំពោះមុខវិជ្ជាដែលមិនទាន់មានរបាយម៉ោងសិក្សាប្រចាំឆ្នាំមិនទាន់សមស្រប គឺមុខវិជ្ជាចិត្តចលភាព ២៧% ដោយគ្រូមត្តេយ្យសិក្សាស្នើសុំកាត់ម៉ោងមុខវិជ្ជាចិត្តចលភាព ៣៥ម៉ោងសិក្សា ក្នុងប្រធានបទបំណិនចលករតូចបញ្ចូលក្នុងមុខវិជ្ជាសិក្សាសង្គម ដែលមានច្រើនសកម្មភាព ឬមុខវិជ្ជាភាសាខ្មែរសម្រាប់ ពង្រឹងការរៀនពី

ព្យញ្ជនៈ និងស្រៈ។ ម្យ៉ាងទៀតមុខវិជ្ជាចិត្តចលភាពក្នុងកាលវិភាគសិក្សានៅថ្ងៃសៅរ៍មាន២ម៉ោងសិក្សា ស្នើសុំដក១ម៉ោងសិក្សាបញ្ចូលនៅក្នុងសកម្មភាពល្បែង ក្នុងមុខវិជ្ជាសិក្សាសង្គម។ ចំពោះរបាយម៉ោងសិក្សាប្រចាំឆ្នាំ មុខវិជ្ជាបុរេគណិតនៅមិនទាន់មានភាពសមស្រប ៣% និងមុខវិជ្ជាវិទ្យាសាស្ត្រ ៥% ដោយរបាយម៉ោងសិក្សាប្រចាំឆ្នាំតាមប្រធានបទមួយចំនួនមិនទាន់ឆ្លើយតបនឹងលទ្ធផលរំពឹងទុក របាយម៉ោងសិក្សាច្រើនតែខ្លឹមសារលទ្ធផលរំពឹងទុកតិច ឬរបាយម៉ោងសិក្សាតិចតែខ្លឹមសារលទ្ធផលរំពឹងទុកច្រើន និងរបាយម៉ោងមុខវិជ្ជាសិក្សាសង្គម ខ្វះខាតមួយចំនួនក្នុងប្រធានបទបំណិនទំនាក់ទំនង ខ្លឹមសារ បំណិនរស់នៅក្នុងសង្គម និងទំនាក់ទំនងល្អជាមួយមិត្តភក្តិដែលមានវ័យប្រហាក់ប្រហែលគ្នា។ ដូច្នេះ ក្រសួងអប់រំ យុវជន និងកីឡា គួរតែមានគោលការណ៍ណែនាំឱ្យគ្រូមត្តេយ្យសិក្សា មានភាពបត់បែន ច្នៃប្រឌិត លើរបាយម៉ោងសិក្សាតាមប្រធានបទឱ្យមានភាពស៊ីចង្វាក់គ្នាទៅនឹងលទ្ធផលរំពឹងទុក។

### ៤.២.៥.ខ្លឹមសារលទ្ធផលរំពឹងទុក

ក្រាហ្វិក 7 ៖ របាយម៉ោងសិក្សាតាមមុខវិជ្ជាប្រចាំសប្តាហ៍




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

ខ្លឹមសារលទ្ធផលរំពឹងទុក គឺផ្អែកសំខាន់សម្រាប់ការកំណត់ចំណងជើងមេរៀននៃមុខវិជ្ជាទាំង៥ ឱ្យត្រូវតាមចំនួនម៉ោងសិក្សាប្រចាំឆ្នាំ។ ការកំណត់លទ្ធផលរំពឹងទុក ចំណងជើងមេរៀន ឱ្យឆ្លើយតបនឹងលទ្ធផលសិក្សារួមក្នុងសៀវភៅកម្មវិធីសិក្សាលម្អិត ដែលត្រូវដាក់ទៅក្នុងបំណែងចែកកម្មវិធីសិក្សាលម្អិតប្រចាំខែ សប្តាហ៍ និងផែនការបង្រៀនប្រចាំថ្ងៃឱ្យបានត្រឹមត្រូវ។ ដើម្បីកំណត់ចំណងជើងមេរៀនឱ្យបានល្អប្រសើរ គឺត្រូវសិក្សាលើលទ្ធផលរំពឹងទុករួមតាមមុខវិជ្ជាក្នុងកម្មវិធីសិក្សាលម្អិតទាំង ៣កម្រិតថ្នាក់ សិក្សាលើឯកសារយោង និងបទពិសោធដែលទទួលបានពីវគ្គបំប៉ន សិក្ខាសាលា ឬការប្រជុំបច្ចេកទេស... គិតទៅលើតេស្តវាស់សមត្ថភាពទៀងទាត់របស់កុមារ (គួរដាក់ចំណងជើងមេរៀនបែបណាដែលជួយដល់ការលើកកម្ពស់គុណភាពតេស្តកុមារ) ផ្សារភ្ជាប់ទៅនឹងស្ថានភាពតំបន់ ជីវភាពរស់នៅប្រចាំថ្ងៃរបស់កុមារ តាមរដូវ វប្បធម៌

និងប្រពៃណី មេរៀនត្រូវចាប់ផ្តើមពីងាយទៅលំបាក និងមានទំនាក់ទំនងគ្នា ដោយបង្ហាញនូវការអភិវឌ្ឍតាមលំដាប់អាយុពីថ្នាក់កម្រិតទាបរហូតដល់ថ្នាក់កម្រិតខ្ពស់។

តាមរយៈក្រាហ្វិចទី៧ បានបង្ហាញថា ភាពសមស្របនៃខ្លឹមសារលទ្ធផលរំពឹងលើមុខវិជ្ជាចិត្តចលភាព ៦៨% មុខវិជ្ជាបុរេគណិត ៨១% សិក្សាសង្គម ៨៤% វិទ្យាសាស្ត្រ ៨១% និងភាសាខ្មែរ ៦៨%។ ខ្លឹមសារលទ្ធផលរំពឹងទុកមានភាពសមស្របខ្លះៗ គឺមុខវិជ្ជាចិត្តចលភាព ១៩% មុខវិជ្ជាបុរេគណិត ១៩% សិក្សាសង្គម ១៦% វិទ្យាសាស្ត្រ ១៩% និងភាសាខ្មែរ ៣២% ព្រោះខ្លឹមសារនៃលទ្ធផលរំពឹងទុកមួយចំនួនតាមមុខវិជ្ជានីមួយៗ តាមប្រធានបទមួយចំនួនពិបាករកចំណងជើងមេរៀន ឬខ្លឹមសារមិនសមស្រប ឬខ្លឹមសារស្ទួនគ្នា ឬពិបាកក្នុងការរកសម្ភារៈមកបង្រៀន។ ខ្លឹមសារលទ្ធផលរំពឹងទុកមុខវិជ្ជាចិត្តចលភាពនៅមានភាពមិនទាន់សមស្រប ១៣% ដោយក្នុងប្រធានបទបំណិនចលករតូច គួរតែស្ថិតក្នុងសកម្មភាពល្បែងក្នុងមុខវិជ្ជាសិក្សាសង្គម។ ដូចនេះ ខ្លឹមសារនៃលទ្ធផលរំពឹងទុក គួរតែពិនិត្យឡើងវិញចំពោះមុខវិជ្ជាចិត្តចលភាព ខ្លឹមសារលទ្ធផលរំពឹងទុកដែលស្ទួនគ្នា ឬពិបាកយល់ និងកំណត់ចំណងជើងមេរៀន។

### ៤.២.៦.វិធីសាស្ត្របង្រៀន

**ក្រាហ្វិក ៨ ៖ អំពីវិធីសាស្ត្របង្រៀន**




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

វិធីសាស្ត្របង្រៀន គឺជាល្បិចប្រកបដោយភាពប៉ិនប្រសប់ ច្បាស់លាស់ ក្នុងការបង្រៀនប្រកបដោយប្រសិទ្ធភាព ទទួលបាននូវលទ្ធផលល្អ ក្នុងការផ្ទេរចំណេះដឹងទៅសិស្ស ព្រមទាំងឆ្លើយតបទៅនឹងវត្ថុបំណងខ្លឹមសារមេរៀន។ វិធីសាស្ត្របង្រៀនរួមមាន ការបង្រៀនដោយប្រើគោលវិធីសិស្សមជ្ឈមណ្ឌល ការកំណត់វត្ថុបំណងមេរៀន ការប្រើសំណួរបំផុសសិស្ស ការប្រើពាក្យលើកសរសើរសិស្ស...។

តាមទិន្នន័យក្រាហ្វិកទី៨ បានបង្ហាញថា គ្រូមត្តេយ្យសិក្សាភាគច្រើនអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ៩២% គឺបង្កលក្ខណៈងាយស្រួល បត់បែន យកសកម្មភាពសិស្ស ច្រើនជាងគ្រូ។ គ្រូមត្តេយ្យខិតខំស្រាវជ្រាវរកវិធីសាស្ត្រល្អៗតាមរយៈការប្រជុំបច្ចេកទេស ប្រព័ន្ធអ៊ីនធរណេត...។ មានតែគ្រូបង្រៀន ៨% តែប៉ុណ្ណោះ ដែលនៅតែអនុវត្តគោលវិធីគ្រូមជ្ឈមណ្ឌល ធ្វើឱ្យបាត់បង់នូវទំនួលខុសត្រូវ ការកសាង

ចំណេះដឹង និងសមត្ថភាពមានស្រាប់របស់សិស្ស។ ដូច្នេះ គ្រូមត្តេយ្យសិក្សាគួរងាករកគោលវិធីណាដែលជួយឱ្យ កុមារចាប់អារម្មណ៍ បង្កើនការចូលចិត្តរៀនរបស់កុមារ និងខិតខំស្រាវជ្រាវរកវិធីសាស្ត្រថ្មីៗបន្ថែមទៀតរួមមាន Project Approach, Brain Based Learning, STEM Education, High Scope...ដើម្បីរត់ឱ្យទាន់សម័យឧស្សាហកម្មទី៤.០ និងការអប់រំបែបឌីជីថល។

ទស្សនៈរបស់លោក សូ ក្រាត (៤៦៩-៣៩៩ មុន គ.ស) លោកជាជនទី១ ដែលបានលើកឡើងពីវិធីសាស្ត្រនៃការផ្តល់ និងទទួលចំណេះដឹងរបស់មនុស្ស ដែលត្រូវផ្តើមចេញពីការត្រិះរិះពិចារណា និងបង្កើតឡើងដោយខ្លួនឯង។ លោកពោលថា "ម្តាយខ្ញុំជាឆ្មបសម្រាប់បង្កើតកូន ចំណែកខ្ញុំជាឆ្មបសម្រាប់បង្កើតគំនិត"។ លោក ប្លា តុង (៤២៧-៣៤៨ មុនគ.ស) បានលើកឡើងថា "ការអប់រំគឺធ្វើឱ្យរស់ឡើងវិញនូវសច្ចភាព សោភ័ណភាព និងកុសល" នេះមានន័យថា ការបង្រៀន គឺជួយសិស្សឱ្យបង្កើនឡើងវិញនូវចំណេះដឹងដែលមានស្រាប់ពីមុន សិល្បៈគរុកោសល្យគឺជា សិល្បៈនៃការចោទសួរ គ្រូបង្រៀនគឺត្រូវចេះចោទសួរ។ ហេតុនេះការបង្រៀនមិនមែនជា ការនាំមកនូវអ្វីៗឱ្យកុមារដោយផ្ទាល់ទេ ប៉ុន្តែកុមារត្រូវបង្ហាញឱ្យឃើញនូវអ្វីៗដែលគេមានរួចហើយផងដែរ។លោក កុងហ្វុយស៊ុល(Confusius ៥៥១-៤៧៩ មុន គ.ស) បានពោលថា "បើចង់ចេះ តែមិនមានឆន្ទៈ នោះគឺមិនរីកបញ្ញាទេ" បើចង់យល់ច្បាស់តែមិនប្រឹងប្រែងយកចិត្តទុកដាក់នោះក៏មិនដុះគំនិតដែរ។ ទន្ទឹមនឹងនេះ លោកក៏បានកំណត់ថាក្នុងលំនាំនៃការបង្រៀន គ្រូមិនត្រឹមតែធ្វើឱ្យសិស្សសប្បាយចិត្តនោះទេ តែត្រូវធ្វើឱ្យសិស្សចូលចិត្តរៀនជាមួយផងដែរ។ នៅសម័យទំនើប ទស្សនៈវិទូនៅបូរាណសម័យរក្សាអត្តិភាព និងនៅមានតម្លៃ ប្រើប្រាស់រហូតដល់ចុងសតវត្សទី១៦។ តាំងពីសតវត្សទី១៧ រហូតបច្ចុប្បន្ន ដោយរក្សា ទុកនូវទ្រឹស្តីដែលមានពីមុន ទស្សនវិទូ និងគរុកោសល្យវិទូក្នុងពិភពលោក បានបង្កើតនូវ ទ្រឹស្តីថ្មីៗបន្ថែមទៀត ដែលពាក់ព័ន្ធនឹងគោលវិធីសិស្សមជ្ឈមណ្ឌលៈ លោក ឌីស្តែក វ៉ិច (Disterveck ១៧៩០-១៨៦៦) ជាគរុវិទូជនជាតិអាល្លឺម៉ង់ ដែល បានលើកឡើងពីលំនាំនៃការបង្រៀនសង្កត់ធ្ងន់ទៅលើការពង្រីកចរិតសកម្ម និងម្ចាស់ការច្នៃប្រឌិតរបស់សិស្ស ដែលកំពុងយកចិត្តទុកដាក់ក្នុងការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌលបច្ចុប្បន្ននេះ។ លោក J.J Rousseau ១៧១២-១៧៧៨ ជាគរុវិទូបារាំងដែលបានយកចិត្តទុកដាក់ដល់ការអភិវឌ្ឍបញ្ញា និងចរិតម្ចាស់ការរបស់សិស្ស ក្នុងការរៀនសូត្រតាមចិត្តចង់របស់ ពួកគេ។ លោក ចន ឡុក John Lock ១៦៣០-១៧០៤ ជាគរុកោសល្យវិទូជាតិអង់គ្លេស បានផ្តល់ទស្សនៈពាក់ព័ន្ធនឹងគោលវិធីសិស្សមជ្ឈមណ្ឌលថា "គ្រូត្រូវផ្តល់សេរីភាពដល់សិស្សក្នុងការគិត ព្រោះគ្រូឬឪពុកម្តាយគ្រាន់តែជាអ្នកអប់រំបណ្តោះអាសន្នសម្រាប់ជួយកុមារឱ្យឈានដល់ស្វ័យអភិវឌ្ឍប៉ុណ្ណោះ។
លោក Pestalozzi ១៧៤៦-១៨២៧ ជាគរុកោសល្យវិទូជាតិស្វីស ដែលបានកំណត់ថា ការបង្រៀនត្រូវទុកសេរីភាពឱ្យសិស្សអភិវឌ្ឍ និងទុកពេលឱ្យសិស្សត្រិះរិះពិចារណា។ មធ្យោបាយសិក្សាសំខាន់របស់សិស្សគឺ "អព្ពន្តរញាណ" ដែលអាចជួយសិស្សឱ្យជួបផ្ទាល់ជាមួយវត្ថុ និងបាតុភូតជាក់ស្តែងក្នុងសង្គម។ លោក Hubert Spen Cer ១៨២០-១៩០៣ ជាគរុកោសល្យវិទូ និងទស្សនវិទូជាតិ អាល្លឺម៉ង់ បានលើកឡើងថា វិទ្យាសាស្ត្រជាចំណេះដឹងដ៏មានសារៈសំខាន់ចំពោះមនុស្ស។ គ្រូត្រូវទុកពេលឱ្យសិស្សចេះសិក្សាស្រាវជ្រាវស្វែងយល់និងរកឃើញលទ្ធផលដោយខ្លួនឯង។ គ្រូត្រូវនិយាយឱ្យបានតិច ដើម្បីទុកពេលឱ្យសិស្សធ្វើសកម្មភាពច្រើន ដើម្បីរកឱ្យឃើញដោយខ្លួនឯងតាមរយៈការធ្វើពិសោធ វិភាគ ប្រៀបធៀប... រហូតរកឃើញចំណេះដឹងវិទ្យាសាស្ត្រ ដែលមានលក្ខណៈសមហេតុផល។ ទស្សនៈនេះឆ្លុះបញ្ចាំងពីភាពម្ចាស់ ការច្នៃប្រឌិត

ស្វ័យសិក្សាដោយខ្លួនឯង ដែលសុទ្ធសឹងជាគោលការណ៍សំខាន់ៗ ក្នុងគោលវិធីសិស្សមជ្ឈមណ្ឌលបច្ចុប្បន្ននេះ៉ ។ លោក John Devey ១៨៥៩-១៩៥២ ជាគរុវិទូជាតិអាមេរិកកាំង ដែលបានបង្ហាញទស្សនៈអប់រំមានតម្លៃជាអមតៈ ដូចជា៖ សាលារៀន គឺជាបរិស្ថានអប់រំដែលត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ។ សាលារៀន ត្រូវប្រើគោលការណ៍គរុកោសល្យ ដែលតម្រូវឱ្យសិស្សបង្កើត ចំណេះដឹងដោយខ្លួនឯង។ គោលការណ៍អប់រំទាំងបីនេះ ទាមទារឱ្យគ្រូគោរពភាពម្ចាស់ការរបស់សិស្ស ឱ្យសិស្សអនុវត្តផ្ទាល់ បំផុសសិស្សឱ្យមានចំណូលចិត្តក្នុងការរៀនសូត្រ ត្រូវគិតគូពីចំណេះដឹងមានស្រាប់របស់សិស្ស ប្រើប្រាស់ពាក្យសម្ដីប្រាស្រ័យទាក់ទងប្រសើរជាងការដែល សិស្សស្ដាប់គេនិយាយ ទុកសេរីភាពឱ្យសិស្សក្នុងការអប់រំ ប្រកបដោយប្រជាធិបតេយ្យ។ លោក Carl Rogers ១៩៨៣ ជាចិត្តវិទូ និងជាគ្រូពេទ្យបានបញ្ចេញទស្សនៈថា៖

- គ្រូត្រូវទុកពេលឲ្យសិស្សពិចារណាដោយខ្លួនឯង ដើម្បីរកចម្លើយតាមបែបកសាងចំណេះដឹងផ្ទាល់ខ្លួន
- សិស្សត្រូវរកឱ្យឃើញនូវចំណេះដឹងដែលមានលក្ខណៈរស់រវើក និងមានលក្ខណៈវិទ្យាសាស្ត្រ
- សិស្សត្រូវមានទំនាក់ទំនងគ្នាដោយមិនចាំបាច់មានអ្នកដឹកនាំ ដោយត្រូវចេះ សម្របសម្រួលគ្នាហ៊ានសម្ដែងចេញដោយឥតលាក់លៀមនូវអ្វីៗដែលខ្លួន ចង់បាន
- សិស្សត្រូវចេះស្ដាប់គ្នាទៅវិញទៅមក ចេះការពារមតិខ្លួន និងគោរពមតិអ្នកដទៃតាមលក្ខណៈប្រជាធិបតេយ្យ។

និយាយជារួម ទស្សនៈជាមូលដ្ឋានខាងលើ សុទ្ធតែបង្ហាញឱ្យឃើញថា ការឱ្យតម្លៃខ្ពស់ទៅលើសកម្មភាពសិស្សក្នុងលំនាំនៃការបង្រៀន មានប្រវត្តិជាយូរលង់ណាស់មកហើយ។ ទស្សនៈទាំងនេះហើយដែលជាមូលដ្ឋានគ្រឹះធ្វើឱ្យលេចឡើងនូវគោលវិធីសិស្សមជ្ឈមណ្ឌល។

### ៤.២.៧.គោលការណ៍គ្រឹះក្នុងការបង្រៀនកុមារ

ក្រាហ្វិក 9 ៖ គោលការណ៍គ្រឹះទាំង១០ ក្នុងការបង្រៀននៅមត្តេយ្យសិក្សា



ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

គោលការណ៍គ្រឹះទាំង១០ចំណុច ត្រូវបានរៀបចំឡើងឈរលើគោលការណ៍សំខាន់ៗ ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាដែលមានការអភិវឌ្ឍ ផ្នែកកាយសម្បទា វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។ ក្រាហ្វិចទី៩ បានបង្ហាញឱ្យឃើញពីភាពល្អប្រសើរនៃការប្រើប្រាស់គោលការណ៍គ្រឹះទាំង១០ សម្រាប់អនុវត្តនៅកម្រិតមត្តេយ្យសិក្សា ដែលក្នុងនោះរួមមានគោលការណ៍ដែលមានភាគរយខ្ពស់ចន្លោះពី ៨៤% ទៅ ៩៧% មានគោលការណ៍ទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ ទី៨ និងទី៩។ មានគោលការណ៍ពីរទៀតដែលមានការអនុវត្តបានល្អ និងត្រូវបង្កើនការចូលរួមអនុវត្តបន្ថែមគឺគោលការណ៍ទី៧ បង្កើតយន្តការតាមដានការរៀនសូត្ររបស់កុមារប្រកបដោយប្រសិទ្ធភាព និងគោលការណ៍ទី១០ គឺសហគមន៍និងរដ្ឋអំណាច ដើម្បីធានាគុណភាព និងប្រសិទ្ធភាព ដែលកំពុងធ្វើបច្ចុប្បន្នភាពទៅជាការអនុវត្តការគ្រប់គ្រងតាមសាលារៀន (School Based Management)។ វិស័យអប់រំមិនមានជម្រើសផ្សេងពីការធ្វើឱ្យសាលារៀនទៅជាសាលារៀនសហគមន៍បានទេ។ សហគមន៍ជាម្ចាស់សាលារៀន ហើយសាលារៀនធ្វើអ្វីទាំងអស់ដើម្បីសហគមន៍ និងបង្កើតនូវអត្តចរិតជួយគ្នា និងថែរក្សាគ្នាទៅវិញទៅមក។ កិច្ចការនេះ អាចធ្វើបានតាមរយៈកម្មវិធីការគ្រប់គ្រងសាលារៀន។ នេះជានិន្នាការភាពប្រកបដោយគណនេយ្យភាព។ (ក្រសួងអប់រំយុវជននិងកីឡា, សៀវភៅណែនាំអនុវត្តទី១ស្តីពីការគ្រប់គ្រងសាលារៀនសម្រាប់មត្តេយ្យសិក្សាសាធារណៈ, ២០១៩, ទំព័រ ៨៥) ការអភិវឌ្ឍសាលារៀន គឺមានការចូលរួមពីកុមារ គ្រួសារ និងសហគមន៍។ សាលារៀន គ្រួសារ សហគមន៍ ត្រូវបានក្លាយជាកម្លាំងសង្គមដ៏រឹងមាំ ដែលមានបរិស្ថានចម្រុះទាំងវិជ្ជមាន ទាំងអវិជ្ជមាន ព័ទ្ធជុំវិញកុមារ ឬមនុស្សពេញវ័យដែលតម្រូវឱ្យមានទំនាក់ទំនងជិតស្និទ្ធ សំដៅរួមគ្នាកសាង ការពារ និងអភិវឌ្ឍធនធានមនុស្សឱ្យមានគុណភាពតាមស្តង់ដាកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ។ ដូចនេះ គ្រូមត្តេយ្យសិក្សាត្រូវកសាងទំនាក់ទំនងល្អ និងជិតស្និទ្ធជាមួយគ្រួសារ និងសហគមន៍ តាមរយៈសកម្មភាពផ្តល់ព័ត៌មានត្រឡប់រវាងគ្រូនិងគ្រួសារនៅពេលទទួលនិងប្រគល់កុមារ សៀវភៅតាមដានការសិក្សាកុមារ ការប្រជុំពិភាក្សាផ្លាស់ប្តូរយោបល់ពាក់ព័ន្ធនឹងការងារអប់រំកុមារតូច ការអញ្ជើញគ្រួសារកុមារឱ្យចូលរួមរៀបចំកម្មវិធីបុណ្យផ្សេងៗ របស់សាលារៀន ជាដើម។

### ៤.២.៨.កិច្ចតែងការបង្រៀន

**ក្រាហ្វិក 10 ៖ ការរៀបចំកិច្ចតែងការបង្រៀន**



ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

កិច្ចតែងការបង្រៀន គឺជាផែនទីចង្អុលផ្លូវសម្រាប់គ្រូបង្រៀន ដើម្បីឱ្យសម្រេចបាននូវវត្ថុបំណងមេរៀននីមួយៗ។ ការរៀបចំកិច្ចតែងការបង្រៀនទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ និងកំណត់វត្ថុបំណងនៃមេរៀនច្បាស់លាស់។ អាស្រ័យហេតុនេះ ទើបរាល់កិច្ចតែងការនីមួយៗ ត្រូវឱ្យមានការឯកភាពពីគណៈគ្រប់គ្រងសាលារៀន ឬប្រធានក្រុមបច្ចេកទេសផងដែរ ដើម្បីជៀសវាងនូវចំណុចខ្វះខាត។ ជាពិសេស គឺបានធ្វើឱ្យគ្រូបង្រៀនមានបម្រុងប្រយ័ត្នក្នុងការរៀបចំរដ្ឋបាលបង្រៀនបានត្រឹមត្រូវ។

តាមរយៈទិន្នន័យក្រាហ្វិចទី១០ បានបង្ហាញថា គ្រូមត្តេយ្យសិក្សាមានកិច្ចតែងការបង្រៀនគ្រប់មុខវិជ្ជា ១៩% មានកិច្ចតែងការបង្រៀនច្រើន ១១% មានកិច្ចតែងការបង្រៀនខ្លះៗ ៧០% និងមិនមានកិច្ចតែងការបង្រៀន ០%។ យើងសង្កេតឃើញថា គ្រូមត្តេយ្យសិក្សាភាគច្រើនបានធ្វើកិច្ចតែងការបង្រៀនបានតែមួយចំនួនតូចប៉ុណ្ណោះ ដូចនេះ ធ្វើឱ្យការបង្រៀនមិនទាន់ល្អប្រសើរ និងមិនមានទិសដៅច្បាស់លាស់។ គ្រូមត្តេយ្យសិក្សាមួយចំនួនបានត្អូញត្អែរថា ត្រូវរៀបចំផែនការបង្រៀនផង រកសម្ភារឧបទេសថ្មីៗផង និងស្ថិតក្នុងបរិបទថ្មីផង ធ្វើឱ្យពួកគាត់ត្រូវរត់តាមឱ្យទាន់។ ដូចនេះ គ្រូមត្តេយ្យសិក្សាគួរតែព្យាយាមរៀបចំកិច្ចតែងការឱ្យបានគ្រប់គ្រាន់ ទើបធ្វើឱ្យការបង្រៀនមានគុណភាពឆ្លើយតបនឹងគោលការណ៍ទាំង១០ ដើម្បីជានាគុណភាពលទ្ធផលសិក្សារបស់កុមារមានភាពល្អប្រសើរ។

### ៤.២.៩.សម្ភារឧបទេស

**ក្រាហ្វិក 11 ៖ សម្ភារឧបទេសសម្រាប់បង្រៀន**




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

សម្ភារឧបទេសមានសារៈសំខាន់ណាស់ គឺជាកាតាលីករជំរុញឱ្យសម្រេចបានវត្ថុបំណងនៃមេរៀនតាមរយៈការប្រើប្រាស់សម្ភារៈបានត្រឹមត្រូវតាមក្បួនគរុកោសល្យ។ ការបង្រៀនបើគ្មានសម្ភារឧបទេសទេ

ប្រៀបដូចជាទៅធ្វើស្រែដោយគ្មាននង្គ័លដូច្នឹងដែរ។ នៅកម្រិតមត្តេយ្យសិក្សា ត្រូវការសម្ភារឧបទេសដ៏ច្រើនសម្រាប់កុមារតូច ព្រោះវ័យនេះកុមារចូលចិត្តរៀនតាមរយៈការលេងជាមួយសម្ភារៈរូបី។

ក្នុងក្រាហ្វិកទី១១ យើងសង្កេតឃើញថា គ្រូមត្តេយ្យសិក្សាមានសម្ភារឧបទេសក្នុងការបង្រៀនគ្រប់គ្រាន់ ២១% មានច្រើន ២២% មានខ្លះៗ ៥៤% និងមិនមានសម្ភារឧបទេស ៣%។ ការផលិតសម្ភារឧបទេសរបស់គ្រូមត្តេយ្យសិក្សានៅមានកម្រិតនៅឡើយ គឺមិនទាន់គ្រប់គ្រាន់ឆ្លើយតបទៅនឹងមេរៀនទាំងអស់។ មួយវិញទៀតគ្រូមត្តេយ្យសិក្សាមួយចំនួនតូចមានវ័យចំណាស់ គាត់មិនបានរៀបចំ ឬប្រើតែសម្ភារឧបទេសពីមុនៗមក។ ដូចនេះ ទាមទារឱ្យគ្រូមត្តេយ្យសិក្សាខិតខំយកចិត្តទុកដាក់ចំណុចនេះឡើងវិញ។ សម្ភារឧបទេសទាំងនោះត្រូវបានផលិតដោយគ្រូមត្តេយ្យសិក្សា សម្ភារៈដែលមាននៅតាមមូលដ្ឋានច្នៃប្រឌិត ទិញវត្ថុធាតុដើមពីទីផ្សារ ដែលមានលក្ខណៈគរុកោសល្យ។

### ៤.២.១០.ឯកសារសម្រាប់បង្រៀន និងរៀន

**ក្រាហ្វិក 12 ៖ ឯកសារផ្សេងៗ ក្នុងការងារបង្រៀននិងរៀន**




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

តាមរយៈក្រាហ្វិចទី១២ បានបង្ហាញថា គ្រូមត្តេយ្យសិក្សា ៩២% បានប្រើប្រាស់ឯកសារផ្សេងៗសម្រាប់យោងក្នុងការបង្រៀនមានដូចជា សៀវភៅសិក្សាគោលនៅមត្តេយ្យសិក្សា(បុរេសំណេរ បុរេគណិត ចម្រៀងនិងតន្ត្រី គរុកោសល្យបរិស្ថានភាគ១ និងភាគ២ ចិត្តចលភាព...) សៀវភៅកម្មវិធីសិក្សាកុមារអាយុ៥ឆ្នាំ លំនាំនៃការបង្រៀន ចំណែកឯកសារនានាពីអង្គការ សមាគម និងសេចក្តីណែនាំផ្សេងៗ គ្រូមត្តេយ្យសិក្សាពុំសូវបានប្រើប្រាស់ទេ។ ម្យ៉ាងទៀតតាមរយៈការសម្ភាសគ្រូមត្តេយ្យសិក្សាមួយចំនួន ៣% បានស្រាវជ្រាវឯកសារផ្សេងៗទៀត ពីប្រព័ន្ធអ៊ីនធ័រណេត។ ដូចនេះ ក្រសួងអប់រំ យុវជន និងកីឡា គួររៀបចំសេចក្តីណែនាំផ្សេងៗ ទាក់ទងនឹងការប្រើប្រាស់សៀវភៅសិក្សាគោលទាំង៥មុខវិជ្ជា។

### ៤.២.១១.វាយតម្លៃការសិក្សាកុមារ

ក្រាហ្វិក 13 ៖ វង្វាយតម្លៃការសិក្សារបស់កុមារ




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

ក្រាហ្វិកទី១៣ បានបង្ហាញថា គ្រូមត្តេយ្យសិក្សា ៩៥% បានប្រើការវាយតម្លៃដោយការស្តាប់និងសង្កេត ជំរុញនិងផ្តល់ការណែនាំបន្ថែមដល់កុមារ។ ជាពិសេសគ្រូមត្តេយ្យសិក្សាទាំងអស់បានប្រើការវាយតម្លៃលទ្ធផលសិក្សាផ្លូវការ (តេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ) ១០០%។ គ្រូមត្តេយ្យសិក្សាមួយចំនួនទៀត ៣% បានធ្វើទំនាក់ទំនងជាមួយមាតាបិតាកុមារ ស្តីពីការសិក្សារបស់កូន តាមរយៈការជួបពួកគាត់ទាំងក្រៅផ្លូវការ និងក្នុងផ្លូវការ។

ជាទូទៅការវាយតម្លៃមានច្រើនបែបច្រើនយ៉ាង និងមានគោលបំណងផ្សេងៗគ្នា។ ដោយឡែកការវាយតម្លៃនៅមត្តេយ្យសិក្សាមានគោលបំណងវាស់កម្រិតចំណេះដឹង បំណិន ឬសមត្ថភាពរបស់សិស្សក្រោយពីបានសិក្សាចប់មេរៀន ជំពូក ប្រធានបទ ឬ កម្មវិធីសិក្សាតាមកម្រិតថ្នាក់តាមមុខវិជ្ជា ឬតាមភូមិសិក្សានីមួយៗ វាស់កម្រិតនៃការប្រែប្រួល ឬការរីកចម្រើនផ្លូវចិត្ត និងគុណតម្លៃនានា ដូចជាតម្លៃ សីលធម៌ ឥរិយាបថ សាមគ្គីភាព ព្រហ្មវិហារធម៌។ល។ ការតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់កុមារគួរមានបីដំណាក់កាលគឺ ការស្តាប់និងសង្កេតមើលកុមារ ការជំរុញនិងផ្តល់ការណែនាំបន្ថែម និងការវាយតម្លៃលទ្ធផលសិក្សារបស់កុមារជាផ្លូវការ។

ដូចនេះ គ្រូមត្តេយ្យសិក្សាសិក្សាគួរតែពង្រឹងបន្ថែម ទៅលើវង្វាយតម្លៃលទ្ធផលសិក្សាកុមារតាមរយៈមេរៀនប្រចាំថ្ងៃ ឬក្រោយបញ្ចប់មេរៀននីមួយៗ ដោយមានតារាងវាយតម្លៃតាមសូចនាករលទ្ធផលរំពឹងទុក។

## ៤.២.១២.ការប្រើប្រាស់សៀវភៅកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា

ការប្រើប្រាស់កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សាឆ្លើយតបកំណែទម្រង់ និងការអភិវឌ្ឍកម្មវិធីសិក្សាជានិន្នាការមួយស្របទៅនឹងការវិវត្តយ៉ាងលឿនក្នុងបរិបទពិភពលោក ដែលមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ ទស្សនវិជ្ជាថ្មីមានទំនោរទៅលើការកំណត់បញ្ចូលលទ្ធផលសិក្សាជាគោលបំណងចម្បង ក្នុងការអភិវឌ្ឍកម្មវិធីសិក្សា។ បញ្ញត្តិនៃកម្មវិធីសិក្សាបានធ្វើឱ្យមានការផ្លាស់ប្តូរទស្សនៈ គោលគំនិត គរុកោសល្យនិងវិធីសាស្ត្រសម័យមុន ដោយប្រែក្លាយពីការបង្រៀនមកជាការរៀន និងប្រកាន់យកសកម្មភាពសិស្សជាគោលការណ៍(គោលវិធីសិស្សមជ្ឈមណ្ឌល) ផ្ទេរពុទ្ធិមកជាការស្ថាបនាពុទ្ធិដោយខ្លួនឯង ឬសិស្សអាចសម្រេចលទ្ធផលសិក្សាបានតាមវិធីសាស្ត្រចម្រុះ ដើម្បីអភិវឌ្ឍបំណិន និងសមត្ថភាព ក្នុងគោលបំណង បណ្តុះគំនិតកុមារឱ្យស្រឡាញ់ការសិក្សាពេញមួយជីវិត ព្រមទាំងធានាបាននូវគុណភាពអប់រំក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ ឈរលើទស្សនៈខាងលើនេះ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែលម្អកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា ឱ្យមានលក្ខណៈផ្សារភ្ជាប់ទៅនឹងកម្មវិធីសិក្សានៅបឋមសិក្សាចំណេះទូទៅ។

**ក្រាហ្វិក 14 ៖ ការយល់ដឹងពីការប្រើប្រាស់សៀវភៅកម្មវិធីសិក្សាលម្អិត**




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

តាមរយៈក្រាហ្វិកទី១៤ យើងសង្កេតឃើញថា គ្រូមត្តេយ្យសិក្សាបានយល់ច្បាស់ពីការប្រើប្រាស់កម្មវិធីសិក្សាតែ ៣% ប៉ុណ្ណោះ យល់ច្រើន ២១% និងបានយល់ខ្លះៗ រហូតដល់ ៧៦%។ ទាំងនេះបញ្ជាក់ឱ្យឃើញថាគុណភាពនៃវគ្គបំប៉នគ្រូមត្តេយ្យសិក្សាស្តីពីកម្មវិធីសិក្សានៅមានកម្រិតនៅឡើយ តម្រូវឱ្យមានការបំប៉នឡើងវិញជាប្រចាំ ឬសមត្ថភាពនៃការទទួលយករបស់គ្រូមត្តេយ្យសិក្សានៅមានកម្រិត ដែលទាមទារឱ្យមានការបង្កើនសមត្ថភាពតាមរយៈបង្កើនឆ្នាំនៃការបណ្តុះបណ្តាលគ្រូ (១២+៤) ឬបង្កើនអាជ្ញាបណ្ណគ្រូបង្រៀនក្របខណ្ឌមត្តេយ្យបន្ថែមទៀត។

### ៤.២.១៣.ការពិនិត្យតាមដាននិងវាយតម្លៃពីថ្នាក់ការិយាល័យអប់រំក្រុង/ស្រុក

ការចុះពិនិត្យតាមដាន និងវាយតម្លៃ ពីថ្នាក់ការិយាល័យអប់រំក្រុង/ស្រុក (មន្ត្រីទទួលបន្ទុកការងារអប់រំកុមារតូច) គឺពិតជាមានសារៈសំខាន់ក្នុងការជួយពង្រឹងការងារដឹកនាំ គ្រប់គ្រងរបស់គណៈគ្រប់គ្រង ជាពិសេសលើការងារបច្ចេកទេសតាមសាលារៀន និងការអនុវត្តការងាររបស់គ្រូមត្តេយ្យសិក្សា។

**ក្រាហ្វិក 15 ៖ ការចុះពិនិត្យតាមដាននិងវាយតម្លៃពីថ្នាក់ការិយាល័យអប់រំក្រុង/ស្រុក**




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

យោងតាមក្រាហ្វិកទី១៥ បានបង្ហាញថា ការិយាល័យអប់រំក្រុង/ស្រុក ចុះពិនិត្យតាមដាន និងវាយតម្លៃលើការងារបច្ចេកទេសកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា ម្តងម្កាល ៤៩% និងបានទៀតទាត់ ៥១%។ នេះបញ្ជាក់ឱ្យឃើញពីការយកចិត្តទុកដាក់ក្នុងការជំរុញឱ្យការងាររៀបចំបំណែងចែកកម្មវិធីសិក្សាលម្អិត ការរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន និងការផលិតសម្ភារឧបទេស។

### ៤.២.១៤.ការសង្កេតថ្នាក់រៀនពីនាយក/នាយិកា/ប្រធានក្រុមបច្ចេកទេស

តួនាទីរបស់នាយក/នាយិកាសាលារៀន ជាអដ្ឋាធរអប់រំ ជាមន្ត្រីរដ្ឋបាល ជាទីប្រឹក្សាគរុកោសល្យ ជាអធិការអប់រំអចិន្ត្រៃយ៍ និងជាភ្នាក់ងារអភិវឌ្ឍន៍របស់សហគមន៍។ នាយក/នាយិកាសាលា ជាធិការអប់រំអចិន្ត្រៃយ៍មានសិទ្ធត្រួតពិនិត្យ និងជួយកែលម្អសកម្មភាពអប់រំគ្រប់ផ្នែក ជាពិសេសសកម្មភាពបង្រៀន និងរៀន។ ក្រោយពេលអធិការកិច្ចម្តងៗ បន្ទាប់ពីការសំណេះសំណាល ស្វែងយល់ពីគ្នាទៅវិញទៅមក អ្នកធ្វើអធិការកិច្ច តែងតែធ្វើការណែនាំមួយចំនួនដើម្បីឱ្យមានការអភិវឌ្ឍ។ នាយក/នាយិកាសាលារៀនដែលជាអធិការអប់រំអចិន្ត្រៃយ៍បន្តណែនាំឱ្យអនុវត្តជួយកែលម្អ និងវាយតម្លៃ ដើម្បីឱ្យបានសម្រេចទៅតាមស្មារតីនៃការណែនាំរបស់អ្នកអធិការកិច្ច។ ក្នុងនោះដែរបើសាលារៀនមានបុគ្គលិកច្រើន និងមានប្រធានក្រុមបច្ចេកទេស នាយក/នាយិកា ក៏អាចមានសិទ្ធិក្នុងការធ្វើអធិការកិច្ចថ្នាក់រៀនដល់ប្រធានក្រុមបច្ចេកទេស និងធ្វើរបាយការណ៍ ឬ រាយការណ៍ជូនគណៈគ្រប់គ្រងសាលារៀន។

**ក្រាហ្វិក 16 ៖ ការសង្កេតថ្នាក់រៀនពីនាយក/នាយិកា/ប្រធានក្រុមបច្ចេកទេស**




ប្រភព៖ លទ្ធផលអង្កេតនៅតាមសាលារៀនដោយប្រើកម្រងសំណួរខែមិថុនា ឆ្នាំ២០១៩

តាមរយៈក្រាហ្វិកទី១៦ បានបង្ហាញថា នាយក/នាយិកា/ប្រធានក្រុមបច្ចេកទេស បានចុះសង្កេតថ្នាក់រៀនតិចជាងបីដងក្នុងមួយខែ ៥៤% និងចុះមួយដងក្នុងមួយសប្តាហ៍ ៤៦%។ ការចុះជួយនេះបានជួយសម្របសម្រួលក្នុងការរៀបចំការងាររដ្ឋបាលថ្នាក់ បច្ចេកទេស និងការងារស្មារតីសង្គម។

### ៤.២.១៥.លទ្ធផលនៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ

**តារាង 2 ៖ លទ្ធផលពណ៌នាពីបុរេតេស្តនិងតេស្តបញ្ចប់នៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ**

| Paired Samples Statistics | | | | | |
|---|---|---|---|---|---|
| | | Mean | N | Std. Deviation | Std. Error Mean |
| Pair 1 | Post test | 18.314 | 303 | 2.2087 | .1269 |
| | Pre test | 12.548 | 303 | 4.1611 | .2390 |

តាមរយៈតារាងទី២ បានបង្ហាញថា លទ្ធផលនៃបុរេតេស្តដែលទទួលបានគឺ ១២.៥៤៨ ជាមធ្យម (តម្លៃគម្លាតស្តង់ដាស្មើ ៤.១៦១១) និងលទ្ធផលនៃតេស្តបញ្ចប់ដែលទទួលបានគឺ ១៨.៣១៤ ជាមធ្យម (តម្លៃគម្លាតស្តង់ដាស្មើ ២.២០៨៧)។

**តារាង 3 ៖ លទ្ធផលប្រៀបធៀបពិន្ទុ Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ(T-Test)**

| Paired Samples Test | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | Paired Differences | | | | | t | df | Sig. (2-tailed) |
| | | Mean | Std. Deviation | Std. Error Mean | 95% Confidence Interval of the Difference | | | | |
| | | | | | Lower | Upper | | | |
| Pair 1 | Post test – Pretest | 5.7657 | 3.5249 | .2025 | 5.3672 | 6.1642 | 28.472 | 302 | .000 |

តារាងទី៣ បង្ហាញពីលទ្ធផលនៃប្រៀបធៀបពិន្ទុ Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ។ តារាងបានបង្ហាញថាមានភាពខុសគ្នានៃមធ្យមរវាង Pre test និង Post test គឺ មានចំនួន ៥.៧៦៥៧ តម្លៃគម្លាតស្តង់ដាស្មើ ៣.៥២៤៩ ដែលមានតម្លៃ t ស្មើនឹង ២៨.៤៧២ និងមានតម្លៃ P=0.000 ។ ចំណុចនេះបង្ហាញថាមានភាពខុសគ្នាដែលគួរចាប់អារម្មណ៍ និងទុកចិត្តបានតាមរយៈស្ថិតិដោយតម្លៃ P<0.05។

**តារាង 4 ៖ លទ្ធផលពណ៌នាពីបុរេតេស្តនិងតេស្តបញ្ចប់នៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ វិស័យទី១ ការអភិវឌ្ឍផ្នែករាងកាយនិងសុខភាព(សំណួរទី១-៦)**

| Paired Samples Statistics | | | | | |
|---|---|---|---|---|---|
| | | Mean | N | Std. Deviation | Std. Error Mean |
| Pair 1 | Q_01_Post | .726 | 303 | .4467 | .0257 |
| | Q_01_Pre | .482 | 303 | .5005 | .0288 |
| Pair 2 | Q_02_Post | .941 | 303 | .2368 | .0136 |
| | Q_02_Pre | .772 | 303 | .4201 | .0241 |
| Pair 3 | Q_03_Post | .937 | 303 | .2428 | .0140 |
| | Q_03_Pre | .488 | 303 | .5007 | .0288 |
| Pair 4 | Q_04_Post | .947 | 303 | .2240 | .0129 |
| | Q_04_Pre | .581 | 303 | .4942 | .0284 |
| Pair 5 | Q_05_Post | .960 | 303 | .1953 | .0112 |
| | Q_05_Pre | .759 | 303 | .4284 | .0246 |
| Pair 6 | Q_06_Post | .924 | 303 | .2653 | .0152 |
| | Q_06_Pre | .723 | 303 | .4484 | .0258 |

បើពិនិត្យជារួមយើងឃើញថាមធ្យមនៃបុរេតេស្ត និងតេស្តបញ្ចប់ របស់សំណួរទី១ រហូតដល់ទី៦ (Q1-Q6) នៃតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ មានភាពខុសគ្នា។

**តារាង 5 ៖ លទ្ធផលប្រៀបធៀបពិន្ទុ Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ(T-Test) វិស័យទី១ ការអភិវឌ្ឍផ្នែករាងកាយនិងសុខភាព(សំណួរទី១-៦)**

| Paired Samples Test | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | Paired Differences | | | | | t | df | Sig. (2-tailed) |
| | | Mean | Std. Deviation | Std. Error Mean | 95% Confidence Interval of the Difference | | | | |
| | | | | | Lower | Upper | | | |
| Pair 1 | Q_01_Post - Q_01_Pre | .2442 | .6033 | .0347 | .1760 | .3124 | 7.046 | 302 | .000 |
| Pair 2 | Q_02_Post - Q_02_Pre | .1683 | .4322 | .0248 | .1195 | .2172 | 6.779 | 302 | .000 |
| Pair 3 | Q_03_Post - Q_03_Pre | .4488 | .5178 | .0297 | .3903 | .5074 | 15.090 | 302 | .000 |
| Pair 4 | Q_04_Post - Q_04_Pre | .3663 | .4961 | .0285 | .3102 | .4224 | 12.853 | 302 | .000 |
| Pair 5 | Q_05_Post - Q_05_Pre | .2013 | .4098 | .0235 | .1550 | .2476 | 8.551 | 302 | .000 |
| Pair 6 | Q_06_Post - Q_06_Pre | .2013 | .4484 | .0258 | .1506 | .2520 | 7.815 | 302 | .000 |

តារាងទី៥ បង្ហាញពីលទ្ធផលប្រៀបធៀបពិន្ទុបុរេតេស្ត និងតេស្តបញ្ចប់ ក្នុងផ្នែកការអភិវឌ្ឍផ្នែករាងកាយនិងសុខភាព ដែលមាន៦សំណួរ។ តារាងនេះក៏បានបង្ហាញពីភាពខុសគ្នាដែលគួរឱ្យជឿជាក់បាន។ ជារួមគេសង្កេតឃើញថា គ្រប់សំណួរទាំងអស់នៅក្នុងផ្នែកអភិវឌ្ឍរាងកាយនិងសុខភាព មានភាពខុសគ្នានៃមធ្យមភាគ (Mean Differences) ចាប់ពីតូចបំផុត .១៦៨៣ ដល់ធំបំផុតស្មើ .៤៤៨៨ ដែលមានតម្លៃ t តូចបំផុតស្មើនឹង ៦.៧៧៩ និងធំបំផុតគឺ ១៥.០៩០ ហើយ P=0.000 ឬ P=0.05។ សម្រាប់សំណួរទី១ ដល់ទី៦មានភាពខុសគ្នារវាងបុរេតេស្តនិងតេស្តបញ្ចាប់ដែលគួរឱ្យជឿជាក់បាន និងគួរយកចិត្តទុកដាក់ដោយតម្លៃ P តូចជាង 0.05(P<.05)។ នេះសរបញ្ជាក់ឱ្យឃើញពីប្រសិទ្ធភាពនៃការអន្តរាគមន៍របស់កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ។

**តារាង 6 ៖ លទ្ធផលពណ៌នាពីបុរេតេស្ត និងតេស្តបញ្ចប់ នៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ វិស័យទី២ ការអភិវឌ្ឍផ្នែកសីលធម៌ និងវប្បធម៌(សំណួរទី៧-៩)**

| Paired Samples Statistics | | | | | |
|---|---|---|---|---|---|
| | | Mean | N | Std. Deviation | Std. Error Mean |
| Pair 1 | Q_07_Post | .967 | 303 | .1789 | .0103 |
| | Q_07_Pre | .644 | 303 | .4797 | .0276 |
| Pair 2 | Q_08_Post | .891 | 303 | .3120 | .0179 |
| | Q_08_Pre | .564 | 303 | .4967 | .0285 |
| Pair 3 | Q_09_Post | .950 | 303 | .2173 | .0125 |
| | Q_09_Pre | .548 | 303 | .4985 | .0286 |

បើពិនិត្យជារួម យើងឃើញថាមធ្យមនៃបុរេតេស្ត និងតេស្តបញ្ចប់របស់សំណួរទី៧ រហូតដល់ទី៩ (Q7-Q9) នៃតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ មានភាពខុសគ្នា។

**តារាង 7 ៖ លទ្ធផលប្រៀបធៀបពិន្ទុ Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ(T-Test) វិស័យទី២ ការអភិវឌ្ឍផ្នែកសីលធម៌និងវប្បធម៌(សំណួរទី៧-៩)**

| Paired Samples Test | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | Paired Differences | | | | | t | df | Sig. (2-tailed) |
| | | Mean | Std. Deviation | Std. Error Mean | 95% Confidence Interval of the Difference | | | | |
| | | | | | Lower | Upper | | | |
| Pair 1 | Q_07_Post - Q_07_Pre | .3234 | .4756 | .0273 | .2697 | .3772 | 11.838 | 302 | .000 |
| Pair 2 | Q_08_Post - Q_08_Pre | .3267 | .5168 | .0297 | .2683 | .3852 | 11.005 | 302 | .000 |
| Pair 3 | Q_09_Post - Q_09_Pre | .4026 | .5045 | .0290 | .3456 | .4597 | 13.891 | 302 | .000 |

តារាងទី៧ បង្ហាញពីលទ្ធផលប្រៀបធៀបពិន្ទុបុរេតេស្ត និងតេស្តបញ្ចប់ ក្នុងផ្នែកការអភិវឌ្ឍផ្នែកសីលធម៌និងវប្បធម៌ ដែលមាន ៣សំណួរ។ តារាងនេះក៏បានបង្ហាញពីភាពខុសគ្នាដែលគួរឱ្យជឿជាក់បាន។ ជារួមគេសង្កេតឃើញថា គ្រប់សំណួរទាំងអស់នៅក្នុងផ្នែកអភិវឌ្ឍសីលធម៌និងវប្បធម៌ មានភាពខុសគ្នានៃមធ្យមភាគ (Mean Differences) ចាប់ពីតូចបំផុត .៣២៣៤ ដល់ធំបំផុតស្មើ .៤០២៦ ដែលមានតម្លៃ t តូចបំផុតស្មើនឹង ១១.០០៥ និងធំបំផុតគឺ ១៣.៨៩១ ហើយ P=0.000 ឬ P=0.0៥។ សម្រាប់សំណួរទី៧ ដល់ទី៩ មានភាពខុសគ្នារវាងបុរេតេស្ត និងតេស្តបញ្ចប់ ដែលគួរឱ្យជឿជាក់បាន និងគួរយកចិត្តទុកដាក់ដោយតម្លៃ P តូចជាង 0.0៥(P<.05)។ នេះសរបញ្ជាក់ឱ្យឃើញពីប្រសិទ្ធភាពនៃការអន្តរាគមន៍របស់កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ។

**តារាង 8 ៖ លទ្ធផលពណ៌នាពីបុរេតេស្ត និងតេស្តបញ្ចប់ នៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ វិស័យទី៣ ការអភិវឌ្ឍផ្នែកសង្គម និងអារម្មណ៍ (សំណួរទី១០-១១)**

| Paired Samples Statistics | | | | | |
|---|---|---|---|---|---|
| | | Mean | N | Std. Deviation | Std. Error Mean |
| Pair 1 | Q_10_Post | .941 | 303 | .2368 | .0136 |
| | Q_10_Pre | .736 | 303 | .4415 | .0254 |
| Pair 2 | Q_11_Post | .927 | 303 | .2599 | .0149 |
| | Q_11_Pre | .700 | 303 | .4592 | .0264 |

បើពិនិត្យជារួម យើងឃើញថាមធ្យមនៃបុរេតេស្ត និងតេស្តបញ្ចប់របស់សំណួរទី១០ រហូតដល់ទី១១ (Q10-Q11) នៃតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ មានភាពខុសគ្នា។

**តារាង 9 ៖ លទ្ធផលប្រៀបធៀបពិន្ទុ Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ(T-Test) វិស័យទី៣ ការអភិវឌ្ឍផ្នែកសង្គមនិងអារម្មណ៍ (សំណួរទី១០-១១)**

| Paired Samples Test | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | Paired Differences | | | | | t | df | Sig. (2-tailed) |
| | | Mean | Std. Deviation | Std. Error Mean | 95% Confidence Interval of the Difference | | | | |
| | | | | | Lower | Upper | | | |
| Pair 1 | Q_10_Post - Q_10_Pre | .2046 | .4432 | .0255 | .1545 | .2547 | 8.037 | 302 | .000 |
| Pair 2 | Q_11_Post - Q_11_Pre | .2277 | .4790 | .0275 | .1736 | .2819 | 8.276 | 302 | .000 |

តារាងទី៧ បង្ហាញពីលទ្ធផលប្រៀបធៀបពិន្ទុបុរេតេស្ត និងតេស្តបញ្ចប់ ក្នុងផ្នែកការអភិវឌ្ឍផ្នែកសង្គមនិងអារម្មណ៍ ដែលមាន២សំណួរ។ តារាងនេះក៏បានបង្ហាញពី ភាពខុសគ្នាដែលគួរឱ្យជឿជាក់បាន។ ជារួមគេសង្កេតឃើញថា គ្រប់សំណួរទាំងអស់នៅក្នុងផ្នែកអភិវឌ្ឍសង្គមនិងអារម្មណ៍ មានភាពខុសគ្នានៃមធ្យមភាគ (Mean Differences) ចាប់ពីតូចបំផុត .២០៤៦ ដល់ធំបំផុតស្មើ .២២៧៧ ដែលមានតម្លៃ t តូចបំផុតស្មើនឹង ៨.០៣៧ និងធំបំផុតគឺ ៨.២៧៦ ហើយ P=0.000 ឬ P=0.0៥។ សម្រាប់សំណួរទី១០ ដល់ទី១១ មានភាពខុសគ្នារវាងបុរេតេស្ត និងតេស្តបញ្ចប់ ដែលគួរឱ្យជឿជាក់បាន និងគួរយកចិត្តទុកដាក់ ដោយតម្លៃ P តូចជាង 0.0៥(P<.05)។ នេះសរបញ្ជាក់ឱ្យឃើញពីប្រសិទ្ធភាពនៃការអន្តរាគមន៍របស់កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ។

**តារាង 10 ៖ លទ្ធផលពណ៌នាពីបុរេតេស្ត និងតេស្តបញ្ចប់ នៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ វិស័យទី៤ ៖ ការអភិវឌ្ឍផ្នែកការយល់ដឹងនិងការពិចារណា (សំណួរទី១២-១៦)**

| Paired Samples Statistics | | | | | |
|---|---|---|---|---|---|
| | | Mean | N | Std. Deviation | Std. Error Mean |
| Pair 1 | Q_12_Post | .954 | 303 | .2103 | .0121 |
| | Q_12_Pre | .640 | 303 | .4807 | .0276 |
| Pair 2 | Q_13_Post | .914 | 303 | .2805 | .0161 |
| | Q_13_Pre | .528 | 303 | .5000 | .0287 |
| Pair 3 | Q_14_Post | .944 | 303 | .2305 | .0132 |
| | Q_14_Pre | .667 | 303 | .4722 | .0271 |
| Pair 4 | Q_15_Post | .851 | 303 | .3562 | .0205 |
| | Q_15_Pre | .591 | 303 | .4925 | .0283 |
| Pair 5 | Q_16_Post | .914 | 303 | .2805 | .0161 |
| | Q_16_Pre | .531 | 303 | .4998 | .0287 |

បើពិនិត្យជារួម យើងឃើញថាមធ្យមនៃបុរេតេស្ត និងតេស្តបញ្ចប់របស់សំណួរទី១៤ រហូតដល់ទី១៦ (Q14-Q16) នៃតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ មានភាពខុសគ្នា។

**តារាង 11 ៖ លទ្ធផលប្រៀបធៀបពិន្ទុ Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ(T-Test) វិស័យទី៤ ៖ ការអភិវឌ្ឍផ្នែកការយល់ដឹងនិងការពិចារណា (សំណួរទី១២-១៦)**

| Paired Samples Test | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | Paired Differences | | | | | t | df | Sig. (2-tailed) |
| | | Mean | Std. Deviation | Std. Error Mean | 95% Confidence Interval of the Difference | | | | |
| | | | | | Lower | Upper | | | |
| Pair 1 | Q_12_Post - Q_12_Pre | .3135 | .4924 | .0283 | .2579 | .3692 | 11.084 | 302 | .000 |
| Pair 2 | Q_13_Post - Q_13_Pre | .3861 | .5076 | .0292 | .3288 | .4435 | 13.241 | 302 | .000 |
| Pair 3 | Q_14_Post - Q_14_Pre | .2772 | .4907 | .0282 | .2218 | .3327 | 9.835 | 302 | .000 |
| Pair 4 | Q_15_Post - Q_15_Pre | .2607 | .4964 | .0285 | .2046 | .3168 | 9.144 | 302 | .000 |
| Pair 5 | Q_16_Post - Q_16_Pre | .3828 | .4936 | .0284 | .3270 | .4386 | 13.500 | 302 | .000 |

តារាងទី១១ បង្ហាញពីលទ្ធផលប្រៀបធៀបពិន្ទុបុរេតេស្ត និងតេស្តបញ្ចប់ ក្នុងផ្នែកការអភិវឌ្ឍផ្នែកការយល់ដឹងនិងការពិចារណា ដែលមាន៥សំណួរ។ តារាងនេះក៏បានបង្ហាញពីភាពខុសគ្នាដែលគួរឱ្យជឿជាក់បាន។ ជារួមគេសង្កេតឃើញថា គ្រប់សំណួរទាំងអស់នៅក្នុងផ្នែកអភិវឌ្ឍការយល់ដឹងនិងការពិចារណា មានភាពខុសគ្នានៃមធ្យមភាគ (Mean Differences) ចាប់ពីតូចបំផុត .២៦០៧ ដល់ធំបំផុតស្មើ .៣៨៦១ ដែលមានតម្លៃ t តូចបំផុតស្មើនឹង ៩.១៤៤ និងធំបំផុតគឺ ១៣.៥០០ ហើយ P=0.000 ឬ P=0.0៥។ សម្រាប់សំណួរទី១២ ដល់ទី១៦ មានភាពខុសគ្នារវាងបុរេតេស្ត និងតេស្តបញ្ចប់ ដែលគួរឱ្យជឿជាក់បាន និងគួរយកចិត្តទុកដាក់ដោយតម្លៃ P តូចជាង 0.0៥(P<.05)។ នេះសរបញ្ជាក់ឱ្យឃើញពីប្រសិទ្ធភាពនៃការអន្តរាគមន៍របស់កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ។

**តារាង 12 ៖ លទ្ធផលពណ៌នាពីបុរេតេស្ត និងតេស្តបញ្ចប់ នៃការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ វិស័យទី៥ ៖ ការអភិវឌ្ឍផ្នែកភាសា (សំណួរទី១៧-២០)**

| Paired Samples Statistics | | | | | |
|---|---|---|---|---|---|
| | | Mean | N | Std. Deviation | Std. Error Mean |
| Pair 1 | Q_17_Post | .927 | 303 | .2599 | .0149 |
| | Q_17_Pre | .739 | 303 | .4398 | .0253 |
| Pair 2 | Q_18_Post | .875 | 303 | .3317 | .0191 |
| | Q_18_Pre | .607 | 303 | .4892 | .0281 |
| Pair 3 | Q_19_Post | .875 | 303 | .3317 | .0191 |
| | Q_19_Pre | .630 | 303 | .4835 | .0278 |
| Pair 4 | Q_20_Post | .947 | 303 | .2240 | .0129 |
| | Q_20_Pre | .617 | 303 | .4869 | .0280 |

បើពិនិត្យជារួម យើងឃើញថាមធ្យមនៃបុរេតេស្ត និងតេស្តបញ្ចប់របស់សំណួរទី១៨ រហូតដល់ទី២០ (Q18-Q20) នៃតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ មានភាពខុសគ្នា។

### តារាង 13 ៖ លទ្ធផលប្រៀបធៀបពិន្ទុ Pre test និង Post test សម្រាប់ការអនុវត្តតេស្តវាស់សមត្ថភាពកុមារអាយុ៥ឆ្នាំ(T-Test) វិស័យទី៥ ៖ ការអភិវឌ្ឍផ្នែកភាសា (សំណួរទី១៧-២០)

| Paired Samples Test | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | Paired Differences | | | | | t | df | Sig. (2-tailed) |
| | | Mean | Std. Deviation | Std. Error Mean | 95% Confidence Interval of the Difference | | | | |
| | | | | | Lower | Upper | | | |
| Pair 1 | Q_17_Post - Q_17_Pre | .1881 | .4317 | .0248 | .1393 | .2369 | 7.586 | 302 | .000 |
| Pair 2 | Q_18_Post - Q_18_Pre | .2673 | .4995 | .0287 | .2109 | .3238 | 9.316 | 302 | .000 |
| Pair 3 | Q_19_Post - Q_19_Pre | .2442 | .4743 | .0272 | .1906 | .2978 | 8.964 | 302 | .000 |
| Pair 4 | Q_20_Post - Q_20_Pre | .3300 | .4916 | .0282 | .2745 | .3856 | 11.685 | 302 | .000 |

តារាងទី១៣ បង្ហាញពីលទ្ធផលប្រៀបធៀបពិន្ទុបុរេតេស្ត និងតេស្តបញ្ចប់ ក្នុងផ្នែកការអភិវឌ្ឍផ្នែកការយល់ដឹងនិងការពិចារណា ដែលមាន៤សំណួរ។ តារាងនេះក៏បានបង្ហាញពីភាពខុសគ្នាដែលគួរឱ្យជឿជាក់បាន។ ជារួមគេសង្កេតឃើញថា គ្រប់សំណួរទាំងអស់នៅក្នុងផ្នែកអភិវឌ្ឍភាសា មានភាពខុសគ្នានៃមធ្យមភាគ (Mean Differences) ចាប់ពីតូចបំផុត .១៨៨១ ដល់ធំបំផុតស្មើ .៣៣០០ ដែលមានតម្លៃ t តូចបំផុតស្មើនឹង ៧.០ និងធំបំផុតគឺ ១១.៦៨៥ ហើយ P=0.000 ឬ P=0.0៥។ សម្រាប់សំណួរទី១៧ ដល់ទី២០ មានភាពខុសគ្នារវាងបុរេតេស្ត និងតេស្តបញ្ចាប់ ដែលគួរឱ្យជឿជាក់បាន និងគួរយកចិត្តទុកដាក់ដោយតម្លៃ P តូចជាង 0.0៥(P<.05)។ នេះសរបញ្ជាក់ឱ្យឃើញពីប្រសិទ្ធភាពនៃការអន្តរាគមន៍របស់កម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ។

### តារាង 14 ៖ លទ្ធផលប្រៀបធៀបមធ្យមរវាងកុមារានិងកុមារី

| Group Statistics | | | | | |
|---|---|---|---|---|---|
| | Sex | N | Mean | Std. Deviation | Std. Error Mean |
| Deference | 1.0 | 145 | 5.8345 | 3.60750 | .29959 |
| | 2.0 | 158 | 5.7025 | 3.45768 | .27508 |

### តារាង 15 ៖ ពណ៌នាលទ្ធផល Mean Different តាមស្រុកទាំង៥

| Descriptives | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Deference | | | | | | | | |
| | N | Mean | Std. Deviation | Std. Error | 95% Confidence Interval for Mean | | Minimum | Maximum |
| | | | | | Lower Bound | Upper Bound | | |
| 11.0 | 60 | 4.0833 | 2.24206 | .28945 | 3.5041 | 4.6625 | -1.00 | 11.00 |
| 12.0 | 60 | 8.0167 | 3.39737 | .43860 | 7.1390 | 8.8943 | 2.00 | 16.00 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 13.0 | 50 | 4.8400 | 3.68870 | .52166 | 3.7917 | 5.8883 | .00 | 17.00 |
| 14.0 | 104 | 6.2308 | 3.78867 | .37151 | 5.4940 | 6.9676 | -1.00 | 14.00 |
| 15.0 | 29 | 4.5172 | 1.27113 | .23604 | 4.0337 | 5.0008 | 2.00 | 7.00 |
| Total | 303 | 5.7657 | 3.52492 | .20250 | 5.3672 | 6.1642 | -1.00 | 17.00 |

តាមរយៈតារាងទី១៤ បានបង្ហាញពី Mean different បានមកពីផលដករវាង Mean post test និង Mean pre test ។ តាមរយៈលទ្ធផលនេះបង្ហាញថា ក្នុងចំណោមស្រុកទាំង៥ ស្រុកដែលទទួលបាន Mean difference ដែលជាមធ្យមភាគខ្ពស់ជាងគេគឺស្រុកទី១២ ស្រុកកៀនស្វាយ ស្មើនឹង ៨.០១៦៧។ ហើយស្រុកដែលទទួលបាន Mean difference ទាបជាងគេ គឺស្រុកទី១១ ក្រុងតាខ្មៅ ស្មើនឹង ៤.០៨៣៣ (តារាងទី១៤ ផ្នែកខាងលើ)។

*បញ្ជាក់៖ ១១ ក្រុងតាខ្មៅ, ១២ ស្រុកកៀនស្វាយ, ១៣ ស្រុកអង្គស្នួល, ១៤ ស្រុកខ្សាច់កណ្ដាល, ១៥ ស្រុកស្អាង។*

**តារាង 16 ៖ លទ្ធផលប្រៀបធៀប Mean Different ជារួម**

| ANOVA | | | | | |
|---|---|---|---|---|---|
| Defference | | | | | |
| | Sum of Squares | df | Mean Square | F | Sig. |
| Between Groups | 626.735 | 4 | 156.684 | 15.586 | .000 |
| Within Groups | 3206.928 | 319 | 10.053 | | |
| Total | 3833.664 | 323 | | | |

**តារាង 17 ៖ លទ្ធផលប្រៀបធៀប Mean Different ពីស្រុកមួយទៅស្រុកផ្សេងៗទៀត**

| Multiple Comparisons | | | | | | |
|---|---|---|---|---|---|---|
| (I) DisID | (J) DisID | Mean Difference (I-J) | Std. Error | Sig. | 95% Confidence Interval | |
| | | | | | Lower Bound | Upper Bound |
| 11.0 | 12.0 | -3.93333* | .59528 | .000 | -5.5671 | -2.2995 |
| | 13.0 | -.75667 | .62434 | .744 | -2.4702 | .9569 |
| | 14.0 | -2.14744* | .52858 | .001 | -3.5982 | -.6967 |
| | 15.0 | -.43391 | .73740 | .977 | -2.4577 | 1.5899 |
| 12.0 | 11.0 | 3.93333* | .59528 | .000 | 2.2995 | 5.5671 |
| | 13.0 | 3.17667* | .62434 | .000 | 1.4631 | 4.8902 |
| | 14.0 | 1.78590* | .52858 | .007 | .3352 | 3.2366 |
| | 15.0 | 3.49943* | .73740 | .000 | 1.4756 | 5.5233 |
| 13.0 | 11.0 | .75667 | .62434 | .744 | -.9569 | 2.4702 |

| | | | | | | |
|---|---|---|---|---|---|---|
| | 12.0 | -3.17667* | .62434 | .000 | -4.8902 | -1.4631 |
| | 14.0 | -1.39077 | .56110 | .098 | -2.9307 | .1492 |
| | 15.0 | .32276 | .76105 | .993 | -1.7660 | 2.4115 |
| 14.0 | 11.0 | 2.14744* | .52858 | .001 | .6967 | 3.5982 |
| | 12.0 | -1.78590* | .52858 | .007 | -3.2366 | -.3352 |
| | 13.0 | 1.39077 | .56110 | .098 | -.1492 | 2.9307 |
| | 15.0 | 1.71353 | .68469 | .093 | -.1656 | 3.5927 |
| 15.0 | 11.0 | .43391 | .73740 | .977 | -1.5899 | 2.4577 |
| | 12.0 | -3.49943* | .73740 | .000 | -5.5233 | -1.4756 |
| | 13.0 | -.32276 | .76105 | .993 | -2.4115 | 1.7660 |
| | 14.0 | -1.71353 | .68469 | .093 | -3.5927 | .1656 |
| *. The mean difference is significant at the 0.05 level. | | | | | | |

ស្រុកទី១១ ធៀបស្រុក១២ និង១៤ ត្រូវបានបញ្ជាក់តាមរយៈស្ថិតិថាមានភាពខុសគ្នាដែលគួរឱ្យចាប់អារម្មណ៍និងទុកចិត្តបានដែលតម្លៃ $P<0.05$។ តែបើធៀបស្រុកទី១១ និងស្រុក១៣និង១៥ គេឃើញថា មិនមានភាពខុសគ្នាដែលគួរឱ្យចាប់អារម្មណ៍និងទុកចិត្តបានទេព្រោះតម្លៃ $P>0.05$។ តែចំណុចដែលគួរឱ្យចាប់អារម្មណ៍គឺការប្រៀបធៀបរវាងស្រុកទី១២ និងស្រុកផ្សេងៗទៀត។ លទ្ធផលបង្ហាញថារវាងស្រុកទី១២ និងស្រុកផ្សេងទៀតមានភាពខុសគ្នាដែលគួរឱ្យចាប់អារម្មណ៍និងទុកចិត្តបានដែលតម្លៃ $P<0.05$។ ហើយតារាងទី១៤ ក៏បានបង្ហាញថាមាន Mean Difference ខ្ពស់ជាងគេដែរ។

## ៤.៣.ការវិភាគទិន្នន័យលើកម្រងសំណួរបែបគុណវិស័យ

### ៤.៣.១.ទស្សនៈមន្ត្រីអប់រំ និងមាតាបិតាសិស្សចំពោះការធ្វើអនុវត្តកម្មវិធីសិក្សា និងបញ្ហាប្រឈមនានា

#### ៤.៣.១.១.នាយក/នាយិកាសាលា

នាយក/នាយិកាសាលារៀន គឺជាអធិការអចិន្ត្រៃយ៍ ដែលមានតួនាទីត្រួតពិនិត្យតាមដានរាល់ការបំពេញការងាររបស់គ្រូបង្រៀនក្រោមឱវាទ ជាពិសេសទៅលើការរៀបចំកិច្ចតែងការបង្រៀន ការផលិតសម្ភារៈសម្រាប់ជំនួយដល់ការបង្រៀន និងសកម្មភាពបង្រៀនផ្ទាល់ក្នុងថ្នាក់។ ការធ្វើអធិការកិច្ចផ្ទៃក្នុងលើម៉ោងបង្រៀន បានជួយឱ្យគ្រូបង្រៀនបង្រៀនបានត្រឹមត្រូវតាមខ្លឹមសារមេរៀន និងអាចឱ្យសិស្សទទួលបាននូវវត្ថុបំណងរបស់មេរៀន។ ការចូលធ្វើអធិការកិច្ចម៉ោងបង្រៀន គឺជាការជួយកែលម្អគ្នាទៅវិញទៅមកដើម្បីរកភាពរីកចម្រើនក្នុងអង្គភាពទាំងសមត្ថភាពវិជ្ជាជីវៈរបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្ស ដែលជាវត្ថុបំណងដ៏សំខាន់ក្នុងបេសកម្មរបស់សាលានីមួយៗ។ ការដុះខាត់សមត្ថភាព បំណិន របស់គ្រូបង្រៀនជាប្រចាំតាមរយៈការធ្វើអធិការកិច្ចផ្ទៃក្នុងលើម៉ោងបង្រៀន និងការប្រជុំបច្ចេកទេស ឬការធ្វើថ្នាក់និទស្សន៍ ជាដើម បានជួយពង្រឹង និងពង្រីកគុណវុឌ្ឍិរបស់គ្រូបង្រៀនឱ្យកាន់តែរឹងមាំឡើងបន្ថែមទៀត ក្នុងន័យនេះដែរការសិក្សារបស់សិស្សប្រាកដជាល្អប្រសើរឡើង ជាពិសេសយល់ដឹងកាន់តែច្បាស់ពីការប្រើប្រាស់កម្មវិធីសិក្សា។

តាមរយៈកិច្ចសម្ភាសនាយក/នាយិកាសាលារៀនទាំង១៩សាលាគោលដៅ ឆ្លុះបញ្ចាំងទៅលើការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សារបស់គ្រូមត្តេយ្យសិក្សារដ្ឋបានលើកឡើងថា៖

*"[...] សម្រាប់ការអនុវត្តកម្មវិធីសិក្សាមត្តេយ្យរដ្ឋ មានភាពងាយស្រួលដូចជា គឺ ១)មានការបែងចែករបាយម៉ោងសិក្សាស្រាប់ ២)មានកំណត់ម៉ោងសិក្សាសរុបប្រចាំឆ្នាំតាមមុខវិជ្ជានីមួយៗស្រាប់៣)ផែនការនេះគឺមានគោលការណ៍សំខាន់ៗក្នុងក្របខណ្ឌកម្មវិធីសិក្សាគឺអភិវឌ្ឍផ្នែកកាយសម្បទា បំណិនសម្បទា និងចរិយាសម្បទា ជាពិសេសមានលទ្ធផលរំពឹងទុករួចជាស្រេច។ ៤)កុមារចូលចិត្តរៀនព្រោះជាការសិក្សារបស់កុមារត្រូវធ្វើឡើងតាមការលេង និងសហការ។ ការរៀននិងបង្រៀនសមស្របតាមអាយុ ការរៀននិងបង្រៀនមានលក្ខណៈជាក់ស្តែង។*

*[...] ជ្រើសរើសចំណងជើងមេរៀនទៅតាមខែ និងតាមរដូវកាល កូនសិស្សងាយយល់ ឆាប់ចាប់បាន សិស្សនិងគ្រូចូលរួមយ៉ាងសកម្ម បង្កបរិយាកាសរីករាយក្នុងពេលសិក្សា សិស្សធ្វើសកម្មភាពបានច្រើន, មានភាពងាយស្រួលក្នុងការកំណត់វត្ថុបំណងមេរៀន រកសម្ភារៈជាក់ស្តែង ការសិក្សាទាក់ទងនឹងមជ្ឈដ្ឋាននៅជុំវិញខ្លួន ងាយស្រួលក្នុងការអនុវត្តវត្ថុធាតុដើម និងសម្ភារៈនានាដែលសមស្របនិងមានស្រាប់ក្នុងមូលដ្ឋាន ងាយស្រួលក្នុងការបង្រៀន និងប្រើប្រាស់សម្ភារៈបង្រៀនឱ្យបានសមស្របតាមមេរៀននីមួយៗ ងាយស្រួលបង្រៀន រៀនផងលេងផង ផ្សារភ្ជាប់មេរៀនមួយទៅមេរៀនមួយ ចំពោះកុមារអាយុ៣ឆ្នាំ ៤ឆ្នាំ ៥ឆ្នាំ ចូលចិត្តមុខវិជ្ជាសិក្សាសង្គម ដែលមានសកម្មភាព ផាត់ពណ៌ លើរូបភាពផ្សេងៗ, ផ្តល់ការបណ្តុះបណ្តាលកុមារដែលរៀននៅមត្តេយ្យសិក្សាមុនចូលបឋមសិក្សា។" (d1)*

ប៉ុន្តែទោះបីជាការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ បានជួយដល់ការបង្រៀន និងរៀនឱ្យមានការប្រែប្រួលទៅរកភាពវិជ្ជមានយ៉ាងណាក្តី ក៏ការអនុវត្តសកម្មភាពនេះ នៅមានកម្រិតនៅឡើយ។ នាយក/នាយិកាសាលា បានលើកពីបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងការអនុវត្តកម្មវិធីសិក្សាថ្មីថា៖

*"[...] ដោយសារការយល់ដឹងរបស់អ្នកគ្រូនៅមានកម្រិត ហើយគ្រូខ្វះឯកសារគោលលើមុខវិជ្ជាខ្លះ ដោយសារកម្មវិធីសិក្សាថ្មីទើបទទួលបានការបំប៉នបានមួយលើក មុខវិជ្ជាបុរេគណិត និងមុខវិជ្ជាភាសាខ្មែរ ពិបាកក្នុងការរកចំណងជើងមេរៀនឱ្យស៊ីនឹងលទ្ធផលរំពឹងទុក សម្រាប់មុខវិជ្ជាចិត្តចលភាពប្រើម៉ោងសិក្សាច្រើន [...] មេរៀនខ្លះពិបាកក្នុងការផលិតសម្ភារឧបទេស មានការបែងចែកសកម្មភាពគោល និងមុខវិជ្ជាមិនទាន់ច្បាស់លាស់ បើសិនជាអាចគួរបែងចែកមុខវិជ្ជាមួយត្រូវមានសកម្មភាពគោលអ្វីខ្លះដើម្បីភាពងាយស្រួល មានការលំបាកក្នុងការស្រាវជ្រាវរកឯកសារធ្វើកម្មវិធីសិក្សា ហើយពេលវេលាពុំមានគ្រប់គ្រាន់ក្នុងការបង្កើតបំណែងចែកកម្មវិធីសិក្សា កង្វះសម្ភារឧបទេស លំហូរថវិកាយឺត [...] មាតាបិតា ឬអាណាព្យាបាលកុមារមួយចំនួនមិនទាន់ឱ្យតម្លៃដល់អ្នកគ្រូ*

*មត្តេយ្យ គាត់ចង់ឱ្យតែកូនគាត់ចេះសរសេរអក្សរក្នុងវ័យមត្តេយ្យសិក្សា [...]។" (d3)*

ទន្ទឹមនឹងនេះដែរ នាយក/នាយិកាសាលា ក៏បានដោះស្រាយនូវបញ្ហាប្រឈមមួយចំនួន ដូចដែលបានលើកឡើងថា៖

> *"[...] យកពិភាក្សា និងដោះស្រាយនៅពេលប្រជុំថ្ងៃបច្ចេកទេស ខិតខំស្រាវជ្រាវ និងស្វះស្វែងរកឯកសារនានា [...] ពេលខ្លះហ្នឹងស្វ័យសិក្សាលើការរៀបចំកម្មវិធីសិក្សាថ្មីដែលបានណែនាំឱ្យប្រើប្រាស់អស់លទ្ធភាព ដើម្បីឱ្យការងារបង្រៀននិងរៀនមានគុណភាពល្អ ជួយដោះស្រាយសម្ភារៈដែលគ្រូបន្ទុកថ្នាក់ត្រូវផលិត (ក្រដាសកាតុង ការ កន្ត្រៃ...) និងផ្តល់បច្ចេកទេសតាមរយៈប្រជុំបច្ចេកទេស ឬជួបផ្ទាល់ ហើយខិតខំស្រាវជ្រាវរកឯកសារយោងផ្សេងៗទៀត។" (d3)*

### ៤.៣.១.២.មាតាបិតា/អាណាព្យាបាលសិស្ស

មាតាបិតា/អាណាព្យាបាលសិស្សជាកម្លាំងចលករសំខាន់ ក្នុងការចូលរួមលើកកម្ពស់គុណភាពអប់រំតាមរយៈការបញ្ជូនកូនមកសាលារៀនទៀងទាត់ ពិនិត្យតាមដានការសិក្សារបស់កូន។ មាតាបិតាកុមារគឺជាគ្រូបង្រៀនទីមួយក្នុងការចែករំលែកចំណេះដឹង ផ្តល់បទពិសោធដល់កូន ពិសេសគឺការចូលរួមអភិវឌ្ឍសាលារៀន។

តាមរយៈការផ្តល់បទសម្ភាសមាតាបិតា/អាណាព្យាបាលសិស្ស ចំនួន២០នាក់ បានបញ្ជាក់ពីចំណុចវិជ្ជមាន និងអវិជ្ជមាន ពីកូនៗមុនចូលរៀនសាលាមត្តេយ្យសិក្សាថា៖

> *"[...] កូនខ្ញុំរៀននៅសាលានេះបាន១ឆ្នាំហើយ មុនពេលចូលរៀនខ្ញុំសង្កេតឃើញកូនរបស់ខ្ញុំមិនទាន់មានចំណេះដឹងនៅឡើយទេ និយាយទៅគឺមិនទាន់ចេះដឹងពីការគោរពសំពះ ការរៀនតួអក្សរ ការរៀនចម្រៀងជាតិ ឬចម្រៀងសម្រាប់កុមារ ផាត់រូប ការរៀនធ្វើលំហាត់ប្រាណ ការរៀនរួមគ្នាជាមួយមិត្តភក្តិ [...] ក្រោយពេលបានចូលរៀននៅសាលាមត្តេយ្យសិក្សា កូនរបស់ខ្ញុំមានការប្រែប្រួលលទ្ធផលសិក្សាដូចជា ចេះដឹងពីការគោរពសំពះ ការរៀនតួអក្សរ លេខ ការរៀនចម្រៀងជាតិ ឬចម្រៀងដទៃទៀត ការរៀនផាត់ពណ៌ ការរៀនធ្វើចលនា លំហាត់ប្រាណ ការរៀនរួមគ្នាជាមួយមិត្តភក្តិនៅក្នុងថ្នាក់ និងនៅក្នុងសាលា ហើយបានចូលរួមជាមួយសហគមន៍ដោយមានភាពក្លាហាន [...] ខ្ញុំយល់ថាកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋដែលបានដាក់ឱ្យប្រើប្រាស់គឺល្អ ព្រោះសាលាមត្តេយ្យសិក្សាជាថ្នាលបណ្តុះបណ្តាលកុមារតូចៗ ដែលមានអាយុក្រោម៦ឆ្នាំ មុនឈានចូលបឋមសិក្សា។" (p1)*

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន
# និងសំណូមពរ

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១.សន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងអង្កេតនៅតាមសាលារៀន លើប្រធានបទ "**ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ" ករណីសិក្សា៖ ខេត្តកណ្តាល** អ្នកសិក្សាស្រាវជ្រាវអាចធ្វើការសន្និដ្ឋានជារួមបានថា ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ មិនទាន់អនុវត្តបានល្អប្រសើរនៅឡើយទេ ដោយការអនុវត្តសកម្មភាពនេះ បានក្នុងកម្រិតមួយល្អបង្គួរប៉ុណ្ណោះ។ ផ្អែកទៅលើលទ្ធផលនៃការសិក្សាស្រាវជ្រាវបានរកឃើញថា ការអនុវត្តកម្មវិធីសិក្សានៅមិនទាន់បានអនុវត្តល្អប្រសើរនៅឡើយ ដោយនៅមានចំណុចខ្វះខាតមួយចំនួនលើខ្លឹមសារមេរៀននិងរបាយម៉ោងសិក្សា ការរៀបចំសម្ភារឧបទេស និងការអនុវត្តរបស់គ្រូមត្តេយ្យសិក្សា៖

- ចំពោះខ្លឹមសារមេរៀន គ្រូមត្តេយ្យសិក្សានៅមិនទាន់យល់ដឹងបានច្បាស់លាស់ ពីការប្រើប្រាស់សៀវភៅកម្មវិធីសិក្សានៅឡើយទេ។ គ្រូមត្តេយ្យសិក្សាយល់ច្បាស់ពីខ្លឹមសារមេរៀន ២៤%ប៉ុណ្ណោះ ហើយនៅមិនទាន់យល់ច្បាស់ ៧៦%។ ខ្លឹមសារនៃលទ្ធផលរំពឹងទុកមួយចំនួនតាមមុខវិជ្ជានីមួយៗ និងតាមប្រធានបទមួយចំនួន ពិបាករកចំណងជើងមេរៀន ឬខ្លឹមសារមិនសមស្រប ឬខ្លឹមសារស្ទួនគ្នា ឬពិបាកក្នុងការរកសម្ភារៈមកបង្រៀន។ ខ្លឹមសារលទ្ធផលរំពឹងទុកមុខវិជ្ជាចិត្តចលភាព នៅមានភាពមិនទាន់សមស្រប ១៣%។ ចំណែករបាយម៉ោងសិក្សាក៏នៅមានបញ្ហាមួយចំនួនតូច ដែលមិនទាន់មានភាពសមស្រប លើមុខវិជ្ជាចិត្តចលភាព ២៧% និងមុខវិជ្ជាសិក្សាសង្គម ២៧%។
- ការរៀបចំសម្ភារឧបទេសរបស់គ្រូមត្តេយ្យសិក្សានៅមានកម្រិតនៅឡើយ គឺមិនទាន់ឆ្លើយតបទៅនឹងគ្រប់មេរៀនទាំងអស់ ក្នុងនោះគ្រូមត្តេយ្យសិក្សាមានសម្ភារឧបទេសក្នុងការបង្រៀនប្រមាណ ៤៣% មានខ្លះៗ ៥៤% និងមិនមានសម្ភារឧបទេស ៣%។ បើពិនិត្យទៅលើកិច្ចតែងការបង្រៀនឃើញថា គ្រូមត្តេយ្យសិក្សាមានកិច្ចតែងការបង្រៀនគ្រប់មុខវិជ្ជា ១៩% មានកិច្ចតែងការបង្រៀនភាគច្រើន ១១% មានកិច្ចតែងការបង្រៀនខ្លះៗ ៧០%។
- ការអនុវត្តការងាររបស់គ្រូក៏នៅមានចំណុចខ្វះខាតមួយចំនួនលើការរៀបចំបំណែងចែកកម្មវិធីសិក្សាលម្អិត និងផែនការបង្រៀនប្រចាំថ្ងៃ ចន្លោះពី ៥% ទៅ ៣០% មិនទាន់ឆ្លើយតបទៅនឹងកម្មវិធីសិក្សាថ្មី។ ប៉ុន្តែចំណុចដែលគួរឱ្យចាប់អារម្មណ៍នោះ គឺលទ្ធផលនៃការធ្វើតេស្តកុមារអាយុ៥ឆ្នាំ បានល្អ។ ប្រសិនបើគ្រូមត្តេយ្យសិក្សាអនុវត្តកម្មវិធីសិក្សាបានល្អប្រសើរជាងនេះ លទ្ធផលនៃការសិក្សារបស់កុមារក៏កាន់តែមានកម្រិតខ្ពស់។

សរុបមកអ្នកសិក្សាស្រាវជ្រាវបានរកឃើញថា ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ នៅមានភាពខ្វះចន្លោះមួយចំនួន និងអនុវត្តមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយទេ។ ការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋនេះ គួរត្រូវបានយកចិត្តទុកដាក់ និងដោះស្រាយរាល់បញ្ហាប្រឈមផងដែរ ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់គុណភាពអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា នាពេលបច្ចុប្បន្ននេះ។

## ៥.២.សំណូមពរ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ យើងបានរកឃើញថាការអនុវត្តកម្មវិធីសិក្សានេះ នៅមានកម្រិត និងមានបញ្ហាប្រឈមមួយចំនួន ក្នុងការដំណើរការការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋនៅតាមសាលារៀនគោលដៅ ទាំងការយល់ដឹងខ្លឹមសារមេរៀនក្នុងកម្មវិធីសិក្សា ការរៀបចំសម្ភារឧបទេស និងការអនុវត្តរបស់គ្រូ។ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមទាំងនេះ អ្នកសិក្សាស្រាវជ្រាវសូមលើកឡើងនូវគំនិតមួយចំនួន ក្នុងការរួមចំណែកដោះស្រាយបញ្ហាប្រឈមដែលបានរកឃើញ និងដើម្បីពង្រឹងការអនុវត្តកម្មវិធីសិក្សានេះឱ្យកាន់តែមានប្រសិទ្ធភាពប្រសើរឡើង។

- **ក្រសួងអប់រំ យុវជន និងកីឡា**
  - គួរពិនិត្យឡើងវិញ និងកែលម្អខ្លឹមសារលទ្ធផលរំពឹងទុកមួយចំនួន ក្នុងកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ សម្រាប់ការបោះពុម្ពបន្ទាប់
  - ពង្រឹងសមត្ថភាពបន្ថែមដល់អ្នកទទួលបន្ទុកការងារអប់រំកុមារតូចគ្រប់លំដាប់ថ្នាក់ ពិសេសអ្នកអនុវត្តផ្ទាល់ តាមរយៈការប្រជុំបច្ចេកទេស សិក្ខាសាលា ឬវគ្គបំប៉នបច្ចេកទេសផ្សេងៗ
  - ជំរុញឱ្យមានការរៀបចំសៀវភៅសិក្សាគោលទាំង៥មុខវិជ្ជា (មុខវិជ្ជាចិត្តចលភាព វិទ្យាសាស្ត្រ សិក្សាសង្គម បុរេគណិត និងមុខវិជ្ជាភាសាខ្មែរ)និងសម្ភារឧបទេសសំបូរបែប
  - ជំរុញឱ្យបង្កើនក្របខណ្ឌគ្រូមត្តេយ្យសិក្សា និងការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា១២+៤
  - ចុះពិនិត្យតាមដាន និងវាយតម្លៃ តាមសាលារៀនដើម្បីជួយតម្រង់ទិសអ្នកអនុវត្តផ្ទាល់នៅតាមមូលដ្ឋាន។
- **មន្ទីរអប់រំ យុវជន និងកីឡារាជធានី/ខេត្ត**
  - ជំរុញ និងពង្រឹងគ្រូមត្តេយ្យសិក្សាឡើងវិញ ដោយឯកភាពគ្នាតាមតំបន់លើខ្លឹមសារមេរៀនក្នុងកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ
  - រៀបចំសម្ភារឧបទេសជាគំរូសំបូរបែបដើម្បីជាទុនដល់គ្រូមត្តេយ្យសិក្សា
  - ចុះពិនិត្យតាមដាននិងវាយតម្លៃជាប្រចាំ ដោយមានរបាយការណ៍លទ្ធផលជាក់លាក់ និងសម្របសម្រួលការងារនេះ តាមរយៈការប្រជុំបច្ចេកទេស វគ្គបំប៉ន ឬវគ្គសិក្ខាសាលា។
- **ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ**
  - ពង្រឹងសមត្ថភាពគ្រូមត្តេយ្យសិក្សាបន្ថែមលើខ្លឹមសារមេរៀន តាមរយៈការប្រជុំបច្ចេកទេស ឬការចុះជួយបន្ថែមតាមសាលារៀន
  - ជួយសម្របសម្រួលគ្រូមត្តេយ្យសិក្សាក្នុងការផលិតសម្ភារឧបទេស
  - ចុះពិនិត្យតាមដាននិងវាយតម្លៃឱ្យបានញឹកញាប់តាមសាលារៀន ដើម្បីធ្វើការកែលម្អរាល់ចំណុចខ្វះចន្លោះផ្សេងៗ
- **នាយក/នាយិកាសាលា និងប្រធានក្រុមបច្ចេកទេស**
  - ធ្វើការប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ឱ្យបានទៀងទាត់

- បង្កលក្ខណៈងាយស្រួលដល់គ្រូផ្សេងៗទៀត បានចូលរួមសង្កេតការបង្រៀនរបស់គ្រូរួមសាលា គ្រូដែលមានកម្រិតថ្នាក់ខុសគ្នា និងជាពិសេសបង្កើតឱ្យមានការធ្វើថ្នាក់និទស្សន៍ ឬប្រជុំគរុកោសល្យឱ្យបាន១ដងក្នុងមួយខែ
- ជំរុញឱ្យប្រធានក្រុមបច្ចេកទេសដឹកនាំការផលិតសម្ភារឧបទេស
- ពង្រឹង និងបង្កើនការធ្វើចុះសង្កេតថ្នាក់លើម៉ោងបង្រៀនរបស់គ្រូឱ្យបានគ្រប់ៗគ្នា ក្នុងឆ្នាំសិក្សាយ៉ាងតិចបំផុតឱ្យបាន១ដង ក្នុងមួយសប្ដាហ៍។

➢ **គ្រូបង្រៀន**

- សិក្សាស្រាវជ្រាវលើខ្លឹមសារលទ្ធផលរំពឹងទុក ដើម្បីកំណត់ខ្លឹមសារមេរៀនឱ្យបានត្រឹមត្រូវ
- ពង្រឹងគុណវុឌ្ឍិគ្រូបង្រៀន និងផ្នែកគរុកោសល្យឱ្យមានភាពទូលំទូលាយ និងមានការចែករំលែក
- ស្រាវជ្រាវពីការរៀបចំសម្ភារឧបទេសថ្មីៗ បម្រើឱ្យការបង្រៀនបែបសតវត្សទី២១
- ព្យាយាមចូលរួមសង្កេតការបង្រៀន និងផ្ដល់យោបល់គ្នាវិញទៅមក
- បើកចិត្តឱ្យទូលាយ ទទួលការចុះធ្វើអធិការកិច្ចម៉ោងបង្រៀនរបស់ខ្លួន យោបល់កែលម្អផ្សេងៗ ដើម្បីជាឧត្តមប្រយោជន៍ផ្ទាល់ខ្លួន អង្គភាព និងកុមារ ដែលជាអ្នកបន្តវេនកសាងប្រទេសជាតិ។

## ៥.៣.សំណូមពរសម្រាប់ការសិក្សាបន្ត

❖ គួរពង្រីកវិសាលភាពសម្រាប់ការសិក្សាបន្តពីស្ថានភាពនៃការអនុវត្តកម្មវិធីសិក្សា
❖ គួរសិក្សាឱ្យបានស៊ីជម្រៅទៅលើខ្លឹមសារលទ្ធផលរំពឹងទុក ការរៀបចំសម្ភារឧបទេស និងការអនុវត្តការងាររបស់គ្រូមត្តេយ្យសិក្សា
❖ គួរសិក្សាពីផលប៉ះពាល់ (Impact) នៃកម្មវិធីសិក្សាមត្តេយ្យសិក្សាដែលបន្តនៅកម្រិតបឋមសិក្សា។

# ឯកសារយោង


Thailand, M. o. (2017). Early Childhood Curriculum. AKSORNTHAI PRINTING LTD., PART.

*ការអប់រំនៅកម្ពុជា.* (កក្កដាឆ្នាំ១៩៩៩).

ក្រសួងអប់រំយុវជននិងកីឡា. (២០១០, កុម្ភៈ ១៩). គោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍកុមារតូច. ភ្នំពេញ, រាជធានីភ្នំពេញ.

ក្រសួងអប់រំយុវជននិងកីឡា. (២០១៥, មីនា ២២). សន្និបាតអប់រំ.

ក្រសួងអប់រំយុវជននិងកីឡា. (២០១៦). ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃនាយកដ្ឋានអប់រំកុមារតូច.

ក្រសួងអប់រំយុវជននិងកីឡា. (២០១៨). កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ.

ក្រសួងអប់រំយុវជននិងកីឡា. (២០១៩). សៀវភៅណែនាំអនុវត្តទី១ស្តីពីការគ្រប់គ្រងសាលារៀនសម្រាប់មត្តេយ្យសិក្សាសាធារណៈ.

ក្រសួងអប់រំយុវជននិងកីឡាទំព័រទី១ .(២០១៩-២០២៣) ..

ក្រសួងអប់រំយុវជននិងកីឡា. (ឆ្នាំ២០០៥-២០០៦). គោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សា.

ក្រសួងអប់រំយុវជននិងកីឡា. (ឆ្នាំ២០០៧). កម្មវិធីសិក្សាកុមារអាយុ៥ឆ្នាំ.

ក្រសួងអប់រំយុវជននិងកីឡា. (ឆ្នាំ២០១៦). ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស. *នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា.*

ក្រសួងអប់រំយុវជននិងកីឡា. (ឆ្នាំ២០១៧, ខែមីនា ២១-២២-២៣). *សន្និបាតបូកសរុបលទ្ធផលការងារអប់រំយុវជននិងកីឡាឆ្នាំសិក្សា២០១៥-២០១៦និងទិសដៅឆ្នាំសិក្សា២០១៦-២០១៧.*

ក្រសួងអប់រំយុវជននិងកីឡា. (ឆ្នាំ២០១៩, ខែកុម្ភៈ). ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ស្តីពីការអប់រំនៅកម្ពុជា.

ក្រសួងអប់រំយុវជននិងកីឡា. (ឆ្នាំ២០១៩-២០២៣). *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ.*

ក្រសួងអប់រំយុវជននិងកីឡានិងអង្គការUnicef. (២០១០). ឯកសារធនធានអភិវឌ្ឍកុមារតូច.

ក្រសួងអប់រំវប្បធម៌កីឡាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា. (២០០៨). កម្មវិធីសិក្សាសាលាមត្តេយ្យសិក្សានៅប្រទេសជប៉ុន.

គណៈកម្មការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច. (២០១៤, សីហា ១៣). ផែនការសកម្មភាពជាតិការគាំពារនិងអភិវឌ្ឍន៍កុមារតូច. ភ្នំពេញ.

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុជនកម្ពុជាឆ្នាំ២០១១) .).

នាយកដ្ឋានអប់រំកុមារតូច. (២០១៧). ស្តង់ដាសិក្សាសម្រាប់កុមារអាយុ៥ឆ្នាំ.

នាយកដ្ឋានអប់រំកុមារតូច. (ឆ្នាំ២០១៤). *របាយការណ៍ស្តីពីដំណើរការអនុវត្តកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ.*

នាយកដ្ឋានអប់រំកុមារតូច. (ឆ្នាំ២០១៤). ឯកសារស្តង់ដាកម្មវិធីគោលសម្រាប់បំប៉នដល់គ្រូមត្តេយ្យសិក្សាសហគមន៍.

នាយកដ្ឋានអប់រំកុមារតូច. (ឆ្នាំ២០១៨). *របាយការណ៍បូកសរុបលទ្ធផលស្តីពីការចុះប្រមូលព័ត៌មាននៃការអនុវត្តកម្មវិធីសិក្សាថ្មីចំនួន៩ខេត្ត.*

នាយកដ្ឋានអប់រំកុមារតូច. (ឆ្នាំ២០១៨). *របាយការណ៍បូកសរុបលទ្ធផលស្តីពីការប្រមូលព័ត៌មាននៃការអនុវត្តសាកល្បងកម្មវិធី.*
នាយកដ្ឋានអប់រំកុមារតូច. (ឆ្នាំ២០១៨). *របាយការណ៍ស្តីពីដំណើរការនៃការរៀបចំកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា.*
នាយកដ្ឋានអប់រំកុមារតូច. (n.d.). បទបង្ហាញស្តីពីទិដ្ឋភាពទូទៅនៃកម្មវិធីសិក្សា.
នាយកដ្ឋានអប់រំកុមារតូច .(២០១៨) .*របាយការណ៍ .*
វិទ្យាស្ថានជាតិអប់រំ. (២០១៨). បទបង្ហាញស្តីពីសេចក្តីផ្តើមអំពីកម្មវិធីសិក្សា. បណ្ឌិតសៀងសុវណ្ណា.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១ ៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ [illegible] អយក.វក

ថ្ងៃ[illegible] ខែចេត្រ ឆ្នាំ[illegible] សក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមេសា ឆ្នាំ២០១៩

**ជម្រាបមក**

**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ** ៖ ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង** ៖ កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៨១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

